**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទរដ្ឋបាលនៅ ប្រទេសកម្ពុជា និងជប៉ុន

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា លឹម ស៊ីស៊ីម៉ីម៉ី**

**កញ្ញា រិន ណាលីន**

ណែនាំដោយ

**បណ្ឌិត ឌី ពុទ្ធារ៉ា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទរដ្ឋបាលនៅប្រទេសកម្ពុជា និងជប៉ុន

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា លឹម ស៊ីស៊ីម៉ីម៉ី**

**កញ្ញា រិន ណាលីន**

ណែនាំដោយ

**បណ្ឌិត ឌី ពុទ្ធារ៉ា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម នាងខ្ញុំឈ្មោះកញ្ញា **លឹម ស៊ីស៊ីម៉ីម៉ី** និងកញ្ញា **រិន ណាលីន** ជានិស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយប្រណិតប័តន៍សំដែងនូវកត្តញ្ញូតាធម៌ដឹងគុណ ចំពោះលោកឪពុក និងអ្នកម្ដាយដែលបានផ្ដល់កំណើតព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយសេចក្ដីមេត្តា ករុណា រហូតដល់កូនមានឱកាសបានសិក្សារៀនសូត្ររហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ដោយលោកទាំងពីរខិតខំពុំខ្លាច នឿយហត់ ដើម្បីផ្គត់ផ្គង់អោយកូនបានសិក្សារៀនសូត្រមានចំណេះដឹងខ្ពង់ខ្ពស់ ប្រកបដោយគន្លងធម៌បាន។ លើសពីនេះទៅទៀត នាងខ្ញុំទាំងពីរនាក់ក៏សូមសម្ដែងការគោរពដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅជូនចំពោះ

ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ **លុយ ចន្ណា** ព្រមទាំងលោក/លោកស្រីសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រង លោក/លោកស្រីសាស្ត្រាចារ្យ និងមន្ត្រីទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្រៀន ផ្ដល់នូវចំណេះដឹង និងបង្កជាបរិយាកាសងាយស្រួលក្នុងការសិក្សាស្វែងរកពុទ្ធិរហូតដល់អាចបញ្ចប់ការសិក្សាបានដោយជោគជ័យ។

ជាពិសេស លោកសាស្ត្រាចារ្យ **បណ្ឌិត ឌី ពុទ្ធារ៉ា** ដែលជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានណែនាំនាងខ្ញុំនៅក្នុងការសរសេរសារណាក្រោមប្រធានបទ "**ការដោះស្រាយវិវាទរដ្ឋបាលនៅប្រទេសកម្ពុជា និងជប៉ុន**" ដែលលោកបានចំណាយ ពេលវេលាដ៏មានតម្លៃក្នុងការណែនាំ និងតម្រង់ទិស ព្រមទាំងផ្ដល់ឯកសារព្រមទាំងបានជួយជាមតិកែលម្អក្នុងការសរសេរសារណានេះឡើងយ៉ាងយកចិត្តទុកដាក់រហូតឈានដល់ការបញ្ចប់ប្រកបដោយជោគជ័យ។

ទន្ទឹមនឹងនេះ នាងខ្ញុំក៏សូមថ្លែងអំណរគុណដល់ **មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំអំពីច្បាប់ជប៉ុន** (CJL) នៃសាកលវិទ្យាល័យណាហ្គោយ៉ា ដែលបានផ្ដល់អាហារូបករណ៍ដល់រូបនាងខ្ញុំរយៈពេលបួនឆ្នាំ ដើម្បីសិក្សាភាសាជប៉ុន និងច្បាប់ជប៉ុន។ ម្យ៉ាងទៀត យើងខ្ញុំសូមគោរពដឹងគុណចំពោះសាស្ត្រាចារ្យ និងបុគ្គលិក ព្រមទាំងសិស្សច្បង សិស្សប្អូន ដែលបានព្យាយាមបង្រៀន ណែនាំ ក៏ដូចជាចែករំលែកបទពិសោធន៍ទាំងខាងផ្នែកភាសា និងវិធីសាស្ត្រក្នុងការស្រាវជ្រាវអំពីច្បាប់ និងផ្ដល់ជាមតិយោបល់ជាច្រើនដើម្បីសម្រេចបានជាស្នាដៃមួយនេះឡើងមកបាន។

ជាចុងបញ្ចប់ នាងខ្ញុំទាំងពីររូបសូមគោរពប្រសិទ្ធពរជ័យសិរីមង្គល វិបុលសុខ គ្រប់ប្រការជូនដល់អស់លោកអ្នកមានគុណទាំងឡាយ និងសូមបួងសួងអោយលោកអ្នកមានគុណមានសុខភាពល្អមាំមួន និងសូមគោរពជូនពរអោយលោក ជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នាងខ្ញុំទាំងពីររូបមានសេចក្តីសោមនស្សរីករាយដែលមានឱកាសក្នុងការសិក្សាស្រាវជ្រាវប្រធានបទស្តីអំពី "**ការដោះស្រាយវិវាទរដ្ឋបាលនៅប្រទេសកម្ពុជា និងជប៉ុន**"។ កិច្ចការស្រាវជ្រាវនេះកើតចេញពីការខិតខំប្រឹងប្រែងរបស់នាងខ្ញុំទាំងពីររូប នៅក្រោមការដឹកនាំដោយមានការយកចិត្តទុកដាក់យ៉ាងខ្ពង់ខ្ពស់ពីសំណាក់លោកគ្រូសាស្ត្រាចារ្យ **បណ្ឌិត ឌី ពុទ្ធារ៉ា**។ នាងខ្ញុំបានខិតខំអស់ពីកម្លាំងកាយចិត្តនៅក្នុងការសិក្សាស្រាវជ្រាវរកឯកសារនានាដែលពាក់ព័ន្ធនឹងសារណាមួយនេះ។ ជាមួយនឹងការទទួលបានចំណេះដឹងពីបន្ថែមពីលោកគ្រូសាស្ត្រាចារ្យ បូករួមនឹងការឈ្វេងយល់នូវចំណេះដឹងទូទៅបន្ថែមទើបអាចធ្វើអោយស្នាដៃស្រាវជ្រាវនេះលេចជារូបរាងឡើងនាពេលនេះ។ នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះវាពុំមែនជាការងាយស្រួលនោះឡើយ។ ដោយហេតុថាការស្រាវជ្រាវទាមទារការយល់ និងប្រើប្រាស់នូវឯកសារណាដែលអាចជឿទុកចិត្តបាន ព្រមទាំងមានប្រភពច្បាស់លាស់ពីសំណាក់ សាស្ត្រាចារ្យ អ្នកនិពន្ធដែលមានស្នាដៃខ្ពស់។ សារណានេះក៏ជា ផ្លែផ្កាមួយកើតចេញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ការចង់ចេះ ចង់ដឹងអោយកាន់តែស៊ីជម្រៅបន្ថែមទៀតទៅលើការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការ មិនថាតែប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជា ព្រមជាមួយនិងប្រព័ន្ធច្បាប់របស់ប្រទេសជប៉ុនផងដែរ។

ការសម្រេចចិត្តយកប្រធានបទនេះយកមកធ្វើការស្រាវជ្រាវគឺ ក្នុងគោលបំណងសិក្សាស្វែងយល់អំពីការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា និងជប៉ុនដែលជាវិវាទកើតមានវិវាទរវាងបុគ្គលសាធារណៈ និងបុគ្គលសាធារណៈ បុគ្គលឯកជន និងបុគ្គលសាធារណៈជាយថាហេតុ។ ដែលជាទូទៅយើងសង្កេតឃើញថាវិវាទដែលងាយនឹងកើតឡើងនោះគឺ ប្រជាពលរដ្ឋជាមួយអាជ្ញាធរ ឬស្ថាប័នសាធារណៈ។ ដូច្នេះហើយទើបរដ្ឋបង្កើតអោយមានប្រព័ន្ធសម្រាប់ដោះស្រាយវិវាទរវាងបុគ្គលឯកជន និងបុគ្គលសាធារណៈ ឬបុគ្គលសាធារណៈ និងបុគ្គលសាធារណៈខ្លួនឯងផ្ទាល់ ដើម្បីការពារ និងទប់ស្កាត់ ក៏ដូចជាដោះស្រាយវិវាទដែលកើតមានឡើងនោះ ក្នុងគោលដៅជំរុញឱ្យសេវាសាធារណៈកាន់តែមានប្រសិទ្ធិភាព និងតម្លាភាព។ ប៉ុន្តែក៏នៅតែមានការមិនពេញចិត្តសំណាក់ប្រជាពលរដ្ឋទៅកាន់រដ្ឋ ឬអាជ្ញាធររដ្ឋបាលផងដែរ ដោយសារមានបញ្ហាមួយចំនួនអំពីការប្រតិបត្តិតួនាទីរបស់អាជ្ញាធរជាដើម។

ជាចុងក្រោយ ថ្វីត្បិតតែគំនិត និងការស្រាវជ្រាវសារណារបស់នាងខ្ញុំនៅមានកម្រិតនៅឡើយ ដោយមានចំណុចខ្វះខាតតិច ឬច្រើនជៀសមិនផុតដោយប្រការណាក្តី នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសារណានេះនឹងអាចជួយដល់អ្នកសិក្សារដ្ឋបាលសាធារណៈ ព្រមទាំងជាជំនួយស្មាតីដល់សិស្សប្អូនជំនាន់ក្រោយអាចទទួលបានចំណេះដឹងខ្លះៗដែលតាក់តែងនៅក្នុងសារណាមួយនេះ។

# មាតិកា

បញ្ជីអក្សរកាត់ ........ iv
សេចក្តីផ្តើម ........ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការដោះស្រាយវិវាទរដ្ឋបាលនៅកម្ពុជា

**១.១. និយមន័យ** ........ ៥
១.១.១. ឧបាស្រ័យ ........ ៥
១.១.២. ឧបាស្រ័យរដ្ឋបាល ........ ៥
១.១.៣. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........ ៥
១.១.៤. វិវាទរដ្ឋបាល ........ ៦
**១.២. ប្រភេទនៃឧបាស្រ័យរដ្ឋបាល** ........ ៦
១.២.១. ឧបាស្រ័យគ្មានវិវាទ ........ ៦
១.២.២. ឧបាស្រ័យតាមឋានានុក្រម ........ ៦
១.២.៣. ឧបាស្រ័យរដ្ឋបាលពិសេស ........ ៧
១.២.៤. ឧបាស្រ័យរដ្ឋបាលជាមុន ........ ៧
១.២.៥. ឧបាស្រ័យអន្តរការណ៏ ........ ៧
**១.៣. ស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយ** ........ ៨
១.៣.១. ស្ថាប័នថ្នាក់ជាតិ ........ ៨
១.៣.២. ស្ថាប័នថ្នាក់ក្រោមជាតិ ........ ៩
**១.៤. ទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ........ ១២
១.៤.១. ការចរចា(Negotiation) ........ ១២
១.៤.២. សន្ធានកម្ម(Mediation) ........ ១៥
១.៤.៣. មជ្ឈត្តកម្ម(Arbitration) ........ ១៩
១.៤.៤. ការផ្សះផ្សា(Conciliation) ........ ២២

**១.៥. ការដោះស្រាយវិវាទរដ្ឋបាល**..........២៣
១.៤.១. ការដោះស្រាយតាមនីតិវិធីរដ្ឋបាលក្រៅវិវាទ..........២៣
១.៤.១. ការដោះស្រាយតាមនីតិវិធីរដ្ឋបាលវិវាទ..........២៣

## ជំពូកទី២

## សញ្ញាណទូទៅនៃការដោះស្រាយវិវាទរដ្ឋបាលនៅជប៉ុន

**២.១. និយមន័យ**..........២៤
២.១.១. វិវាទរដ្ឋបាល..........២៥
២.១.២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ..........២៥
**២.២. ប្រភេទនៃបណ្តឹងរដ្ឋបាល**..........២៦
២.២.១. បណ្តឹងការទាមទារត្រួតពិនិត្យ (審査請求)..........២៦
២.២.២. បណ្តឹងការទាមទារស្រាវជ្រាវឡើងវិញ (再調査の請求)..........២៦
២.២.៣. បណ្តឹងការទាមទារត្រួតពិនិត្យឡើងវិញ (再審査請求)..........២៦
២.២.៤. បណ្តឹងត្អូញត្អែរ (苦情)..........២៧
**២.៣. ស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយ**..........២៧
២.៣.១. ស្ថាប័នថ្នាក់ជាតិ..........២៧
២.៣.២. ស្ថាប័នថ្នាក់ក្រោមជាតិ..........២៨
**២.៤. ទម្រង់នៃការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការ**..........២៩
២.៤.១. ការចរចា (和解 Compromise)..........៣១
២.៤.២. ការផ្សះផ្សា (あっせん Conciliation)..........៣២
២.៤.៣. សន្ធានកម្ម (調停 Mediation)..........៣២
២.៤.៤. មជ្ឈត្តកម្ម (仲裁 Arbitration)..........៣២

## ជំពូកទី៣

## ដំណើរការនៃការដោះស្រាយវិវាទរដ្ឋបាល

**៣.១. ករណីប្រទេសកម្ពុជា**..........៣៤
៣.១.១. ដំណើរការចរចា..........៣៤
៣.១.២. ដំណើរការសន្ធានកម្ម..........៣៦

៣.១.៣. ដំណើរការមជ្ឈត្តកម្ម..................................................................................................៣៨
៣.១.៤. ដំណើរការដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋ .............................................. ៤១
**៣.២. ករណីប្រទេសជប៉ុន** ......................................................................................................៤៣
៣.២.១. ដំណើរការការចរចា ...............................................................................................៤៣
៣.២.២. ដំណើរការសន្ធានកម្ម ............................................................................................ ៤៥
៣.២.៣. ដំណើរការមជ្ឈត្តកម្ម ............................................................................................ ៤៦
៣.២.៤. ដំណើរការដោះស្រាយដោយភ្នាក់ងារស៊ើបអង្កេតបណ្ដឹងតវ៉ា.....................................៤៧
**សេចក្តីសន្និដ្ឋាន** .................................................................................................................. ៤៩
**អនុសាសន៍** ......................................................................................................................... ៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

១. ADR ៖ Alternative Dispute Resolution ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

២. **គ.ជ.អ.ប** ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

៣. **អ.ជ.ក** ៖ អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលកំពុងនាំអោយមានការប្រែប្រួល និងតម្រូវការសង្គមកាន់តែច្រើនឡើង។ ស្របជាមួយការអភិវឌ្ឍនោះទៀតសោតក៏នាំអោយមានការប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិឯកជនក្តី និងទ្រព្យសម្បត្តិសាធារណៈក្តី ជាហេតុនាំអោយកើតមានវិវាទរវាងបុគ្គលឯកជន និងបុគ្គលសាធារណៈជាយថាហេតុ។ ហេតុដូច្នេះហើយទើបរដ្ឋបង្កើតអោយមានប្រព័ន្ធសម្រាប់ដោះស្រាយវិវាទរវាងបុគ្គលឯកជន និងបុគ្គលសាធារណៈក្នុងគោលដៅជំរុញសេវាសាធារណៈអោយកាន់តែមានប្រសិទ្ធភាព និងតម្លាភាពក៏ដូចជាជំរុញដល់ការអភិវឌ្ឍដែលមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ និងការពារការប្រើប្រាស់អំណាចសាធារណៈហួសព្រំដែនដែលនាំអោយមានការមិនពេញចិត្តពីសំណាក់ប្រជាពលរដ្ឋទៅកាន់ស្ថាប័នរដ្ឋ ឬមួយក៏រាជរដ្ឋាភិបាល នោះបណ្តាលអោយរដ្ឋនោះបាត់បង់នូវភាពជានីតិរដ្ឋ។ យោងតាមរដ្ឋធម្មនុញ្ញមាត្រា៣៩ បានចែងយ៉ាងច្បាស់ថា ប្រជាជនកម្ពុជាមានសិទ្ធពេញលេញក្នុងការប្តឹងតវ៉ា ប្តឹងបរិហារឬ ប្តឹងទាមទារសំណងការខូចខាតដែលបណ្តាលមកពីអំពើអនីត្យានុកូលរបស់អាជ្ញាធររដ្ឋបាលហើយស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយបណ្តឹងតវ៉ា និងដោះស្រាយបណ្តឹងទាមទារសំណងការខូចខាតគឺស្ថាប័នតុលាការ។ ក៏ប៉ុន្តែប្រសិនបើយើងងាកទៅមើលច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤ មាត្រា៨៧ បានចែងថាក្នុងករណីដែលមិនទាន់មានសាលាជម្រះក្តីរដ្ឋបាល សមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋបាលជាសមត្ថកិច្ចរបស់តុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និងសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់។

ជាក់ស្តែង នៅក្នុងស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្នយើងអាចសង្កេតឃើញថានៅពេលដែលមានវិវាទរវាងប្រជាពលរដ្ឋ និងអាជ្ញាធររដ្ឋបាលប្រជាពលរដ្ឋរមែងធ្វើការដាក់ពាក្យបណ្តឹងទៅចាប់ពីអាជ្ញាធរមូលដ្ឋានឡើងទៅរហូតដល់ស្នើសុំនូវការដោះស្រាយពីសំណាក់ក្រសួងស្ថាប័នផ្សេងៗដែលមានសមត្ថកិច្ចទាក់ទងទៅនឹងវិវាទនោះ។ ដោយមូលហេតុថា យុទ្ធសាស្ត្រក្នុងការដោះស្រាយវិវាទរដ្ឋបាលជាគោលការណ៍ គឺតម្រូវអោយមានការដោះស្រាយតាមនីតិវិធីរដ្ឋបាលជាមុនសិន។ ក្នុងករណីមិនពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់រដ្ឋបាលទើបអាចដាក់ពាក្យបណ្តឹងទៅតុលាការបាន។ ហេតុដូច្នេះហើយទើបរាជរដ្ឋាបាលបានបង្កើតអោយមាននូវនីតិវិធីដោះស្រាយវិវាទជូនប្រជាពលរដ្ឋតាមផ្លូវរដ្ឋបាលនៅតាមគ្រប់ស្ថាប័នសាធារណៈ និងជាពិសេសក៏បានបង្កើតអោយមានយន្តការច្រកចេញចូលតែមួយនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជាដើម ដើម្បីអោយប្រជាពលរដ្ឋអាចធ្វើការដាក់ពាក់បណ្តឹងទៅកាន់អាជ្ញាធរមូលដ្ឋានដែលមានសមត្ថកិច្ចអោយជួយសម្របសម្រួលប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងកាន់តែនៅកៀកនឹងប្រជាពលរដ្ឋ និងមានភាពឆាប់រហ័ស។

ក៏ប៉ុន្តែ បើយើងក្រឡេកមើលទៅស្ថានភាពជាក់ស្តែងការដោះស្រាយវិវាទរដ្ឋបាលជូនប្រជាជនរបស់ស្ថាប័នដោះស្រាយវិវាទនោះហាក់ដូចជាពុំសូវទទួលបាននូវការពេញចិត្តពីសំណាក់ប្រជាពលរដ្ឋនោះទេ។ ដោយហេតុថា កម្រិតនៃការដោះស្រាយនៅមានកម្រិតដែលប្រជាពលរដ្ឋមិនសូវពេញចិត្តនិងការដោះស្រាយនោះ ហើយករណីខ្លះក៏មានមតិពីសំណាក់ប្រជាពលរដ្ឋពីការទុកចោលមិនដោះស្រាយ ក៏ដូចជាការពន្យាពេលដោះស្រាយជាដើម។ ហេតុនេះហើយ អត្ថបទនេះនឹងធ្វើការបង្ហាញនូវយន្តការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា និងប្រៀបធៀបទៅនឹងប្រទេសជប៉ុន។ ក្នុងគោលបំណងសិក្សាស្វែងយល់បន្ថែមលើការផ្តល់សេវាជូនប្រជាពលរដ្ឋរបស់អាជ្ញាធររដ្ឋបាល និងស្វែករកនូវចំណុចល្អ និងចំណុចដែលនៅមានភាពខ្វះចន្លោះក៏ដូចជាចំណុចបញ្ហាផ្សេងៗដែលគួរកែតម្រូវដើម្បីអោយសេវារដ្ឋបាលនៅកម្ពុជាកាន់តែមានប្រសិទ្ធភាព សមភាព តម្លាភាព និងមានភាពឆាប់រហ័ស។ លើសពីនេះទៀត យើងសង្ឃឹមទុកថាអត្ថបទមួយនេះថ្វីបើជាកូននិក្ខេបបទតូចមួយប៉ុណ្ណោះ ក៏ប៉ុន្តែក៏អាចនិងចូលរួមចំណែកក្នុងការបញ្ចេញមតិក្នុងន័យស្ថាបនាក្នុងគោលបំណងពង្រឹងសេវារដ្ឋបាល ជាពិសេសការដោះស្រាយវិវាទរដ្ឋបាលជូនប្រជាពលរដ្ឋអោយកាន់តែមានប្រសិទ្ធភាព និងតម្លាភាព។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមលំនាំបញ្ហាខាងលើនេះបានបង្ហាញថាទោះបីជាមាននូវប្រព័ន្ធដោះស្រាយវិវាទរដ្ឋបាលហើយក្តី ក៏នៅតែបន្តមាននូវបញ្ហាផ្សេងៗដែលនាំអោយមានការមិនពេញចិត្តពីសំណាក់ប្រជាពលរដ្ឋទៅកាន់អាជ្ញាធររដ្ឋបាល ឬស្ថាប័នរដ្ឋបាលជាដើម។ ជាបន្តទៅនេះ អត្ថបទនេះនឹងសិក្សាអំពីប្រព័ន្ធដោះស្រាយវិវាទរដ្ឋបាលដែលប្រើប្រាស់នៅប្រទេសកម្ពុជា និងជប៉ុន។ ជាពិសេសនឹងធ្វើការផ្តោតទៅលើការដោះស្រាយវិវាទតាមរយៈយុត្តាធិការរដ្ឋបាល និងស្វែងរកនូវបញ្ហាស្នូលដែលជាហេតុនាំអោយមានភាពយឺតយ៉ាវនៅក្នុងការបំពេញភារកិច្ចរបស់ភ្នាក់ងារសាធារណៈ និងសិក្សាលម្អិតអំពីបញ្ហាដែលកើតមាននោះ និងលើកឡើងអំពីសញ្ញាណទូទៅនៃការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការទាំងនៅប្រទេសកម្ពុជា និងជប៉ុន ដែលអាចសបញ្ជាក់ជាឧទាហរណ៍ដល់ប្រទេសកម្ពុជានូវចំណុចណាដែលល្អអាចយកមកសិក្សាបន្ថែមទៀតបាន ក្នុងគោលបំណងស្វែងរកដំណោះស្រាយណាមួយដែលសមស្របសម្រាប់សង្គមកម្ពុជា និងជំរុញការបំពេញ កិច្ចការសាធារណៈអោយកាន់តែមានប្រសិទ្ធភាព និងតម្លាភាព។

## ៣. គោលបំណងនៃការស្រាវជ្រាវ

អត្ថបទស្រាវជ្រាវនេះមានគោលបំណង

(១)សិក្សាស្វែងយល់ពីប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា និងជប៉ុន

(២) ស្វែងយល់ពីដំណើរការនៃការដោះស្រាយវិវាទរដ្ឋបាលនៅប្រទេសកម្ពុជា និងជប៉ុន

(៣)សិក្សាស្វែងយល់ពីប្រសិទ្ធភាពនៃការដោះស្រាយដោយអាជ្ញាធររដ្ឋបាលនៅកម្ពុជា

(៤)សិក្សាស្វែងយល់ពីបញ្ហាប្រឈមអំពីនីតិវិធីនៃការដោះស្រាយនោះ

(៥) ស្វែងរកដំណោះស្រាយដែលសមស្របមួយសម្រាប់កម្ពុជា និងជំរុញការបំពេញកិច្ចការសាធារណៈរបស់រដ្ឋបាលនៅកម្ពុជាឱ្យកាន់តែមានភាពល្អប្រសើរ និងស្របទៅតាមស្ថានភាពសង្គមបច្ចុប្បន្ន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

សម្រាប់ទំហំនៃការសិក្សាស្រាវជ្រាវនេះមានដែនកំណត់ និងវិសាលភាពទាក់ទងទៅនឹងលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាល ទាក់ទងទៅនឹងការដោះស្រាយវិវាទរដ្ឋបាលនៅកម្ពុជា។ បន្ថែមពីលើនោះទៅទៀត ក៏មានបង្ហាញនូវបទបញ្ញត្តិច្បាប់មួយចំនួនដែលបង្ហាញនៅលំនាំបញ្ហាពីដើមហេតុដែលនាំអោយប្រទេសកម្ពុជាបង្កើតនូវយន្តការដោះស្រាយវិវាទរដ្ឋបាលតាមផ្លូវយុត្តាធិការរដ្ឋបាលដែលក្នុងនោះរួមមាន (១) រដ្ឋធម្មនុញ្ញ មាត្រា៣៩ (២) ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា៨៧ និងមាត្រា៨៩។ ដោយសារតែបច្ចុប្បន្ន កម្ពុជាគោរពនូវគោលការណ៍ដោះស្រាយវិវាទរដ្ឋបាលតាមនីតិវិធីរដ្ឋបាលជាមុន នោះមុននឹងឈានដល់ការដោះស្រាយវិវាទរដ្ឋបាលតាមផ្លូវតុលាការនោះ ប្រធានបទនេះនឹងផ្តោតសំខាន់លើចំណុចមួយចំនួនដូចខាងក្រោម៖

ទី១ និយមន័យ និងប្រភេទនៃបណ្តឹងរដ្ឋបាល

ទី២ ទាក់ទងនឹងវិធីនៃការដាក់ពាក្យបណ្តឹង

ទី៣ ទាក់ទងនឹងវិធីនៃការដោះស្រាយបណ្តឹងជូនប្រជាពលរដ្ឋរបស់អាជ្ញាធរមានសមត្ថកិច្ចដោះស្រាយ។

ចំពោះដែនកំណត់នៃការស្រាវជ្រាវលើប្រធានបទនេះ យើងនឹងចោទជាសំនួរថា តើការបែងចែកអោយបានច្បាស់លាស់នូវប្រភេទនៃបណ្តឹងរដ្ឋបាល និងការដោះស្រាយជូនប្រជាពលរដ្ឋដោយទំនុកចិត្ត ព្រមទាំងមានភាពច្បាស់លាស់ និងស្របទៅតាមវិធានគតិយុត្តមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះ។ ហើយថាតើក្នុងនាមយើងជានិសិត្សបញ្ញាវ័ននៃមហាវិទ្យាល័យរដ្ឋបាលគួរតែធ្វើការរែកញែក និងសិក្សាស្រាវជ្រាវបន្ថែមទៀតអំពីការផ្តល់សេវាសាធារណៈត្រង់ចំណុចណាខ្លះ និងសេវាទាំងនោះនៅមានចំណុចគួរកែលម្អយ៉ាងដូចម្តេចខ្លះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃអត្ថបទនេះផ្តោតសំខាន់ទៅលើចំណុចមួយចំនួនដូចជា៖

- មានសារៈសំខាន់ដល់សង្គមទាំងមូល ក្នុងយល់ដឹងអំពីវិវាទរដ្ឋបាល និងនីតិវិធីដោះស្រាយនាពេលបច្ចុប្បន្ន ក្នុងគោលដៅពិនិត្យមើល ក៏ដូចជាបង្ហាញពីនីត្យានុកូលភាពនៃរដ្ឋបាលសាធារណៈដែលសបង្ហាញពីនីតិរដ្ឋនៃប្រទេសនោះមួយចំណែកផងដែរ
- មានសារៈសំខាន់ចំពោះសាធារណៈ ទប់ស្កាត់ការចលាចលដោយការមិនពេញចិត្តចំពោះអំពើរដ្ឋបាលឬការដោះស្រាយរបស់អាជ្ញាធរមានសមត្ថកិច្ច

➢ មានសារៈសំខាន់ចំពោះយើងខ្ញុំផ្ទាល់ ក្នុងការពង្រឹងសមត្ថភាពស្រាវជ្រាវ ជាស្ពានមួយក្នុងការជួយចម្លងអោយបានដល់ត្រើយនៃការស្វ័យសិក្សាតាមរយៈការស្រាវជ្រាវពីប្រធានបទមួយនេះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការស្រាវជ្រាវលើប្រធានបទនេះ ដោយសារកាលវេលាមានកំណត់យើងខ្ញុំបានសិក្សាស្រាវជ្រាវដោយប្រើប្រាស់វិធីសាស្ត្របកស្រាយណែនាំក្នុងន័យទូលាយ ដោយយោងតាមបទដ្ឋានគតិយុត្ត និងសៀវភៅសិក្សាគោល ក៏ដូចជានិក្ខេបបទស្រាវជ្រាវមួយចំនួនដែលមានស្រាប់ទាំងផ្នែកភាសាខ្មែរ និងភាសាជប៉ុនយកមកបរិយាយនិងធ្វើការប្រៀបធៀប។ យើងខ្ញុំពុំមានផ្តល់ជាទិន្នន័យជាក់លាក់ណាមួយដែល ធ្វើឡើងដោយខ្លួនផ្ទាល់នោះទេ ប៉ុន្តែយើងបានលើកនូវអត្ថបទស្រាវជ្រាវមុនៗមួយចំនួន ក៏ដូចជាឯកសារផ្លូវការរបស់ក្រសួងស្ថាប័នជាដើមយកមកធ្វើជាទល្លីករណ៍ក្នុងការសរសេរអត្ថបទនេះឡើង។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះចែកចេញជា៣ជំពូករួមមាន៖

**សេចក្តីផ្តើម** ដែលបរិយាយអំពី (១) លំនាំនៃការស្រាវជ្រាវ (២) ចំណោទបញ្ហានៃការស្រាវជ្រាវ (៣) គោលបំណងនៃការស្រាវជ្រាវ (៤) ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ (៥) សារៈសំខាន់នៃការស្រាវជ្រាវ (៦) វិធីសាស្ត្រនៃការស្រាវជ្រាវ និង (៧) រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី១៖** សញ្ញាណទូទៅនៃការដោះស្រាយវិវាទរដ្ឋបាលនៅកម្ពុជា។

**ជំពូកទី២៖** សញ្ញាណទូទៅនៃការដោះស្រាយវិវាទរដ្ឋបាលនៅជប៉ុន។

**ជំពូកទី៣៖** ដំណើរការនៃការដោះស្រាយវិវាទរដ្ឋបាល។

បន្ទាប់ពីធ្វើការបកស្រាយអំពីប្រធានបទនេះរួច យើងខ្ញុំនឹងធ្វើការផ្តល់ជាការសរុបអត្ថន័យទាំងស្រុងនៃអត្ថបទដែលរួមមាន **សេចក្តីសន្និដ្ឋាន** ដែលក្តោបនូវចំណុចដែលមានលក្ខណៈខុសគ្នារវាងកម្ពុជា និងជប៉ុន និងអ្វីដែលប្រទេសកម្ពុជានៅខ្វះខាតនៅក្នុងការដោះស្រាយវិវាទរដ្ឋបាលជូនប្រជាពលរដ្ឋ។ ជាចុងបញ្ចប់យើងខ្ញុំនឹងធ្វើការផ្តល់ជា **អនុសាសន៍** ស្តីអំពីចំណុចដែលគួរកែតម្រូវជាបន្ថែមដើម្បីពង្រឹងការអនុវត្តការដោះស្រាយវិវាទរដ្ឋបាលនៅកម្ពុជា ក៏ដូចជាមតិយោបល់នានាដល់អ្នកសិក្សាស្រាវជ្រាវខាងផ្នែករដ្ឋបាលសាធារណៈនេះនៅចុងបញ្ចប់នៃអត្ថបទស្រាវជ្រាវ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការដោះស្រាយ

# វិវាទរដ្ឋបាលនៅកម្ពុជា

# ជំពូកទី១

# សញ្ញាណទូទៅនៃការដោះស្រាយវិវាទរដ្ឋបាលនៅកម្ពុជា

បើយោងទៅតាម រដ្ឋធម្មនុញ្ញមាត្រា៣៩ បានចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋរបស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ"។ ដែលយើងអាចសន្និដ្ឋានថា ប្រសិនបើមានអំពើខុសច្បាប់របស់អង្គការរដ្ឋ អង្គការសង្គម ឬបុគ្គលិកនៃអង្គការទាំងនោះប្រជាពលរដ្ឋអាចធ្វើការប្តឹងតវ៉ា ប្តឹងបរិហារ ប្តឹងទាមទារសំណងជួសជុលការខូចខាតបាន។ ក៏ប៉ុន្តែ យោងតាមមាត្រាដដែលកថាខណ្ឌទី២បណ្តឹងដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចតុលាការគឺមានតែបណ្តឹងតវ៉ា និងបណ្តឹងសំណងជួសជុលការខូចខាតតែប៉ុណ្ណោះ។ ចំណែកឯបណ្តឹងបរិហារតើប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងទៅស្ថាប័នណានោះយើងនឹងធ្វើការសិក្សាជាបន្តទៅនេះ។ ជាដំបូងយើងនឹងធ្វើការសិក្សាស្វែងយល់ថាតើបណ្តឹង(ឧបាស្រ័យ)រដ្ឋបាលចែកចេញជាប៉ុន្មានប្រភេទ។ ប៉ុន្តែ មុននឹងយើងអាចឈានដល់ ការស្វែងយល់ពីប្រភេទនៃឧបាស្រ័យរដ្ឋបាលយើងគប្បីយល់នូវអត្ថន័យនៃពាក្យគន្លឹះមួយចំនួនជាមុនសិន។

## ១.១. និយមន័យ

### ១.១.១. ឧបាស្រ័យ

តាមនិយមន័យទូទៅ "ឧបាស្រ័យ" ជាលិខិតទិទៀនតវ៉ាអ្វីមួយ ទោះបីលិខិតនេះមានប្រភេទជាអ្វីមួយក៏ដោយ (ឧទាហរណ៍ដូចជា សេចក្តីសម្រេចរដ្ឋបាល ឬសេចក្តីសម្រេចតុលាការក្តី) និងទោះបីជាអាជ្ញាធរដែលគេត្រូវតវ៉ាឡើងទៅនោះមានឋានៈជាអ្វីក៏ដោយ ( មានន័យថាទោះជាអាជ្ញាធររដ្ឋបាល ឬតុលាការក៏ដោយ)។

### ១.១.២. ឧបាស្រ័យរដ្ឋបាល

"ឧបាស្រ័យរដ្ឋបាល" គឺសំដៅដល់ការទាមទារ (ក្នុងការសុំកែប្រែ ឬសុំលុបសេចក្តីសម្រេចណាមួយ) ដែលធ្វើទៅរដ្ឋបាលដែលចេញសេចក្តីសម្រេច (ឧបាស្រ័យគ្មានវិវាទ) ឬធ្វើទៅតាមឋានានុក្រមរបស់រដ្ឋបាលដែលជាម្ចាស់លិខិត(ឧបាស្រ័យតាមឋានានុក្រម)។[១]

### ១.១.៣. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

យោងតាមនិយមន័យ "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" សំដៅដល់ការអនុវត្ត ដើម្បីឆ្លើយតបទៅនឹងការប្រើប្រាស់នីតិវិធីតុលាការដែលមានភាពស្មុគស្មាញដែលចំណាយពេលយូរ ចំណាយថវិកាច្រើន និង

[១]សៀវភៅ វិវាទរដ្ឋបាល, ឥន យឿន, ឆ្នាំ២០២២, ទំព័រទី៨០

មានភាពតានតឹង។ ជាទូទៅ ការដោះស្រាយប្រភេទនេះ ត្រូវបានគេប្រើក្នុងការដោះស្រាយវិវាទគ្រួសារ ដីធ្លី ធនធានធម្មជាតិ ការងារ និងពាណិជ្ជកម្មស៊ីវិល ព្រមទាំងករណីស៊ីវិលផ្សេងៗទៀត។

១.១.៤. វិវាទរដ្ឋបាល

យោងតាមនិយមន័យ "វិវាទរដ្ឋបាល" សំដៅដល់វិវាទដែលកើតឡើងរវាងអាជ្ញាធរសាធារណៈ និងប្រជាពលរដ្ឋ ឬរវាងនីតិបុគ្គលសាធារណៈ ឬនីតិបុគ្គលឯកជន និងនិតិបុគ្គលសាធារណៈ។ នៅក្នុងទំនាក់ទំនងអាជ្ញាធរសាធារណៈ និងប្រជាពលរដ្ឋអាចនាំឱ្យកើតមាននូវទំនាស់ជាធម្មតាពីព្រោះវាមានទំនាក់ទំនងរវាងការប្រើប្រាស់អំណាចសាធារណៈ និងការប្រើប្រាសិទ្ធិរបស់ប្រជាពលរដ្ឋ។[2]

## ១.២. ប្រភេទនៃឧបាស្រ័យរដ្ឋបាល

១.២.១. ឧបាស្រ័យគ្មានវិវាទ

ឧបាស្រ័យគ្មានវិវាទ (ជាភាសាបារាំង recours gracieux) មានន័យថាជាការតវ៉ាផ្ទាល់ទៅកាន់ អ្នកធ្វើសេចក្ដីសម្រេចរដ្ឋបាលផ្ទាល់ដោយពុំចាំបាច់មានការឆ្លងកាត់តាមលំដាប់នៃឋានានុក្រមអ្វីនោះទេ។ ឧទាហរណ៍ ប្រធានអង្គភាពមួយ បានចេញសេចក្ដីសម្រេចរដ្ឋបាលមួយ ហើយមន្ត្រីរាជការនៅក្រោមឱវាទផ្ទាល់មានការមិនពេញចិត្ត ហើយធ្វើការតវ៉ាជំទាស់ទៅនឹងសេចក្ដីសម្រេចនោះជាដើម។

ការតវ៉ានេះអាចជា ការស្នើសុំធ្វើការកែប្រែ ឬការនិរាករណ៍ ឬការដកសេចក្ដីសម្រេចមកវិញជាដើម។ ការតវ៉ានេះផងដែរ ត្រូវសម្អាងលើហេតុផលនីត្យានុកូលភាព ឬលើកាលានុវត្តភាពនៃសេចក្ដីសម្រេចរដ្ឋបាលនោះ។ ជាគោលការណ៍ គេអាចធ្វើបណ្ដឹងនេះបានដោយពុំចាំបាច់មានច្បាប់ចែងអនុញ្ញាត្តអោយច្បាស់លាស់នោះឡើយ។[៣]

១.២.២. ឧបាស្រ័យតាមឋានានុក្រម

ឧបាស្រ័យតាមឋានានុក្រម (ជាភាសាបារាំង recours hiérarchique) មានន័យថាជាការតវ៉ាដល់ចៅហ្វាយនាយរបស់អ្នកដែលធ្វើសេចក្ដីសម្រេចរដ្ឋបាល។ ឧទាហរណ៍ មន្ត្រីរាជការ តវ៉ាជំទាស់ទៅនឹងប្រធាននៃឋានានុក្រមរបស់ខ្លួនដែលបានចេញនូវសេចក្ដីសម្រេច ឬវិធានណាមួយ។ ចំណុចគួរចំណាំនោះគឺ អ្នកដែលមានឋានានុក្រមនេះ មិនសុទ្ធសឹងតែជាអ្នកដែលមានអំណាចអាចលុបសេចក្ដីសម្រេចរបស់ថ្នាក់ក្រោមជាតិបាននោះទេ។[៤]

[2] អត្ថបទ ស្ដីពី នៃការដោះស្រាយវិវាទរដ្ឋបាល, លោក ជួប បិតយេរុទ្ធី, ឆ្នាំ២០០៩, ទំព័រទី១

[៣] សៀវភៅ នីតិសាធារណៈ, សាស្ត្រាចារ្យ ហៀង សាង, បោះពុម្ពលើទី១ ឆ្នាំ២០១៧, ទំព័រទី២៨-២៩

[៤] សៀវភៅ នីតិសាធារណៈ, ទំព័រទី២៩

១.២.៣. ឧបាស្រ័យរដ្ឋបាលពិសេស

ឧបាស្រ័យរដ្ឋបាលពិសេស (ជាភាសាបារាំង recours administratif spécial) ដែលតម្រូវឱ្យធ្វើមុនគេបង្អស់។ ឧបាស្រ័យនេះ ជារបៀបនៃការតវ៉ាជំទាស់ទៅនឹងកិច្ចរដ្ឋបាលមួយដែលមានការកំណត់ពិសេសពីអត្ថបទច្បាប់ណាមួយ។ គេអាចហៅម្យ៉ាងទៀតថាជា "ឧបាស្រ័យរដ្ឋបាលបឋមជាកាតព្វកិច្ច" ឬ"ឧបាស្រ័យរដ្ឋបាលបឋមបង្ខំ" ដែលជាការតវ៉ាមួយតម្រូវអោយធ្វើតាមឧបាស្រ័យរដ្ឋបាលជាមុនសិន មុននឹងធ្វើការតវ៉ា តាមរយៈឧបាស្រ័យយុត្តាធិការ។[៥]

១.២.៤. ឧបាស្រ័យរដ្ឋបាលជាមុន

ឧបាស្រ័យរដ្ឋបាលជាមុន ឬឧបាស្រ័យរដ្ឋបាលបឋម (ជាភាសាបារាំង recours administratif préalable) គឺជាការតវ៉ាជំទាស់មួយ ដែលអាចធ្វើឧបាស្រ័យរដ្ឋបាលក៏បាន ឬអាចធ្វើឧបាស្រ័យយុត្តាធិការ ក៏បាន។[៦] មានន័យថា អ្នកដែលមានបំណងចង់ធ្វើការតវ៉ានៅនឹងសេចក្តីសម្រេចអាជ្ញាធរ ឬស្ថាប័នរដ្ឋបាល ណាមួយគេអាចធ្វើការជ្រើសរើសការធ្វើឧបាស្រ័យមួយណាក៏បាន។[៧]

១.២.៥. ឧបាស្រ័យអន្តរការណ៍

ឧបាស្រ័យអន្តរការណ៍ (ជាភាសាបារាំង recours en transaction) មានលក្ខណៈសំគាល់ដូចជាមានសញ្ញាណប្រហាក់ប្រហែលគ្នាគឺ "ការផ្សះផ្សា" (conciliation) "សន្ទានកម្ម" (mediation) និង "មជ្ឈត្តការ" (arbitration) ដែលនៅប្រទេសកម្ពុជាយើងបច្ចុប្បន្នគេហៅថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មាននូវគុណសម្បត្តិជាច្រើនដល់ប្រជាពលរដ្ឋ ក៏ដូចជាអាជ្ញាធរសាធារណៈ រួមមាន កាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ កាត់បន្ថយការចំណាយទៅលើមេធាវី ឬប្រាក់ប្រដាប់ក្តី រក្សាបាននូវការដោះស្រាយដោយមានការយល់ព្រមទទួលស្គាល់ដោយសន្តិវិធី និងមិនមានការកាត់អោយម្ខាងណាឈ្នះនោះឡើយ គឺបានន័យថាជាការដោះស្រាយដោយវិធីសាស្ត្រឈ្នះៗ ដែលគូភាគីទាំងសងខាងអាចទទួលយកបាននូវការដោះស្រាយនោះ និងមិនមានការខាតបង់ផលប្រយោជន៍ទៅកាន់ភាគីណាម្នាក់។[៨]

[៥] សៀវភៅ នីតិសាធារណៈ, ទំព័រទី២៩-៣០

[៦] សៀវភៅ នីតិសាធារណៈ, ទំព័រទី២៩

[៧] សៀវភៅ នីតិសាធារណៈ, ទំព័រទី៣០

[៨] សៀវភៅ នីតិវិវាទរដ្ឋបាលៈ សិក្ខាប័នសំរាប់មើលតាមការពន្យល់ដោយបញ្ចាំងLCD, បណ្ឌិត សាយ បូរី, ឆ្នាំ២០០៥, ទំព័រទី១៣

## ១.៣. ស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយ

### ១.៣.១. ស្ថាប័នថ្នាក់ជាតិ

គ្រប់ស្ថាប័នរដ្ឋ ដែលរួមមានក្រសួងទាំង ២៨ នៃប្រទេសកម្ពុជាមានអធិការកិច្ចក្នុងការទទួល ព្រមទាំងដោះស្រាយបណ្ដឹងបណ្ដឹងតវ៉ា បណ្ដឹងបរិហាររបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងមន្ត្រីនៅក្នុងក្របខ័ណ្ឌក្រសួង ឬស្ថាប័ននោះ។ ឧទាហរណ៍ អនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ សីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ មាត្រា៥ ស្ដីអំពីតួនាទី និងភារកិច្ចរបស់ក្រសួងមហាផ្ទៃបានចែងថា ក្រសួងមហាផ្ទៃត្រូវមានតួនាទីក្នុងការបញ្ជាដឹកនាំដល់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធ្វើអធិការកិច្ចទទួលនិងដោះស្រាយពាក្យបណ្ដឹងតវ៉ា និងបណ្ដឹងបរិហាររបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងមន្ត្រីនៅក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ។ នៅត្រង់នេះបើយើងធ្វើការក្រឡេកទៅមើលរដ្ឋធម្មនុញ្ញ មាត្រា៣៩ ហាក់ដូចជាមានការជាន់សមត្ថកិច្ចគ្នានៃស្ថាប័នរដ្ឋបាល និងស្ថាប័នតុលាការ ក៏ប៉ុន្តែដូចដែលបានលើកមកនៅចំណុចលំនាំបញ្ហារួចមកហើយ គឺគេត្រូវធ្វើឧបាស្រ័យរដ្ឋបាល (បណ្ដឹងរដ្ឋបាល) ដើម្បីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន ទើបធ្វើការបើកផ្លូវតវ៉ាមកតុលាការទៀតបាន។[៩]

ក្រៅពីនេះយោងតាមព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ថ្មីៗនេះរាជរដ្ឋាភិបាលបានបង្កើតនូវអាជ្ញាធរជាតិថ្មី គឺអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលសរសេរជាអក្សរកាត់ថា **អ.ជ.ក**។ ព្រះរាជក្រឹត្យនេះមានកំណត់អំពីការបង្កើត រៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីជាយន្តការការបំពេញបន្ថែមឱ្យមានប្រព័ន្ធដោះស្រាយវិវាទនៅព្រះរាជាណាចក្រកម្ពុជា សំដៅលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ។ ការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះ គឺដើម្បីជម្រុញការផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ ក្នុងគោលបំណងជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្ដី រួមទាំងបង្វិតសេវាដោះស្រាយវិវាទឱ្យកាន់តែកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន និងធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ។

អ.ជ.ក មានបេសកម្មដោះស្រាយក្រៅប្រព័ន្ធតុលាការនូវវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀត តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទដោយផ្អែកតាមការព្រមព្រៀងរបស់ភាគីវិវាទ ឬតាមការស្នើសុំរបស់ភាគីវិវាទ ឬដែលភាគីវិវាទយល់ព្រមទទួលយកយន្តការសម្រុះសម្រួលផ្សះផ្សាវិវាទនេះ លើកលែងតែវិវាទដែល

---

[៩] សៀវភៅ នីតិវិវាទរដ្ឋបាល៖ សិក្ខាប័នសម្រាប់មើលតាមការពន្យល់ដោយបញ្ចាំងLCD, ឆ្នាំ២០០៥, ទំព័រទី១១០-១១១

មិនអាចកម្មវត្ថុនៃការសម្រុះសម្រួលផ្សះផ្សាតាមការកំណត់របស់ពួកគេ។ នៅត្រង់ចំណុចនេះយើងអាចពិចារណាបានថា អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនមែនជាស្ថាប័នដែលធ្វើការកាត់ក្តីជំនួសតុលាការនោះទេ។ ដូច្នេះជាគោលការណ៍ នៅក្នុងការដោះស្រាយវិវាទនេះ អាចធ្វើការផ្សះផ្សាទៅបាន គឺអាស្រ័យលើការសម្រេចចិត្តរបស់គូភាគីទាំងសងខាង។ អាជ្ញាធរជាតិនេះ មិនអាចប្រើប្រាស់អំណាចឆន្ទានុសិទ្ធិ ដើម្បីសម្រេចថារឿងត្រូវដោះស្រាយយ៉ាងណានោះទេ គឺត្រូវប្រើប្រាស់នូវសិល្បៈរបស់អ្នកផ្សះផ្សាដើម្បីឱ្យភាគីទាំងពីរអាចត្រូវរ៉ូវគ្នាឡើងវិញបានដោយសន្តិវិធី។ ប៉ុន្តែការសម្រុះសម្រួលបែបនេះអាចប្រឈមមុខនឹងការបដិសេធរវាងគូភាគីវិវាទបាន ទោះបីមានលិខិតជាលាយលក្ខណ៍អក្សរស្នើសុំសម្រុះសម្រួលក៏ដោយ ក៏ភាគីម្ខាងទៀតមានសិទ្ធិបដិសេធមិនចង់សម្រុះសម្រួលបានដែល។

សម្រាប់ការដោះស្រាយវិវាទដីធ្លីនៅថ្នាក់ជាតិមាន គណៈកម្មការសុរិយោដីថ្នាក់ជាតិដែលដើរតួនាទីជាអ្នកទទួលសំណុំរឿងនៃវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់ពាក្យបណ្តឹងទាក់ទងទៅនឹងវិវាទដីធ្លី និងពិនិត្យបន្ថែមនូវរាល់ឯកសារទាំងអស់ដោយធ្វើការស៊ើបអង្កេត ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងបើកសវនាការមុនធ្វើសេចក្តីសម្រេចលើការបិទបញ្ចប់វិវាទ។ សម្រាប់ភាគីវិវាទមានសិទ្ធិពិនិត្យផ្ទែកច្បាប់លើការសម្រេចរបស់គណៈកម្មការសុរិយោដីដោយប្តឹងជាបន្តទៅតុលាការ។ ប្រសិនបើតុលាការបញ្ជូនរឿងក្តីនេះទៅគណៈកម្មការវិញដោយយោងលើហេតុផលថា គណៈកម្មការមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយវិវាទមានផលប្រយោជន៍ដល់គណៈកម្មការខ្លួនឯងផ្ទាល់ ឬដោះស្រាយដោយមិនមានហេតុផលសមស្របនោះ គណៈកម្មការត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ។[១០]

១.៣.២. ស្ថាប័នថ្នាក់ក្រោមជាតិ

យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លេខ១១១ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ដែលមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ហៅកាត់ថា **គ.ជ.អ.ប**) ដែលមានអនុគណៈកម្មាធិការចំណុះ គ.ជ.អ.ប ដូចជាៈ

១). អនុគណៈកម្មាធិការមុខងារ និងធនធាន

២). អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ

[១០] អនុក្រឹត្យ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ ៤៧ អនក្រ.បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, មាត្រា២០-២៣

៣). អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៤). អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ

៥). អនុគណៈកម្មាធិការសេវាកម្មយុត្តិធម៌។

យោងតាមអនុក្រឹត្យដដែល មាត្រា១១ អនុគណៈកម្មាធិការសេវាយុត្តិធម៌ មានតួនាទីផ្តល់យោបល់ជូន គ.ជ.អ.ប លើកិច្ចការនានាពាក់ព័ន្ធនឹងការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមានភារកិច្ចដូចជា ពិនិត្យ និងផ្តល់យោបល់លើការរៀបចំ និងការអនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារបច្ចេកទេសនានាពាក់ព័ន្ធនឹងការសម្រុះសម្រួលដោះស្រាយវិវាទរដ្ឋបាល និងវិវាទមូលដ្ឋានផ្សេងៗជាដើម។ ចំណែកការអនុវត្តនូវគោលនយោបាយនោះ គឺអាជ្ញាធរមូលដ្ឋានដែលមានដូចជា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជាដើម។

ការសម្រុះសម្រួលដោះស្រាយវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ថ្នាក់ឃុំ សង្កាត់ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ។

ការដោះស្រាយវិវាទនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាត្រូវចាត់វិធានឱ្យសមស្រប ដើម្បីដោះស្រាយវិវាទមូលដ្ឋានដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។[១១] វិវាទនៅមូលដ្ឋាន គឺជាវិវាទដែលមាននូវលក្ខណៈឯកជនរវាងប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាមួយគ្នា ឬដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាផ្សេងគ្នា។[១២] ក្រុមប្រឹក្សានេះត្រូវសម្រុះសម្រួលដោះស្រាយវិវាទដោយមធ្យោបាយណាមួយដែលអាចផ្តល់លក្ខខណ្ឌសមរម្យហើយធ្វើយ៉ាងណាអោយគូភាគីទាំងសងខាងអាចទទួលយកការដោះស្រាយនោះបាន។ ប៉ុន្តែ ក្នុងករណីមិនអាចសម្រុះសម្រួលបានទេ ត្រូវណែនាំភាគីទាំងសងខាងអំពីនីតិវិធីតាមផ្លូវច្បាប់សម្រាប់បន្តដោះស្រាយវិវាទជាបន្ត។[១៣] ប្រសិនបើមិនស្ថិតនៅដែនសមត្ថកិច្ចរបស់ខ្លួនទេនោះ ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីរាយការណ៍ទៅក្រសួង ឬស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយ។[១៤]

ម៉្យាងវិញទៀត ដើម្បីផ្តល់នូវស្វ័យភាពមួយចំនួនធំ ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាសម្រួលដល់ការដោះស្រាយវិវាទជាដើម រដ្ឋាភិបាលបានបង្កើតស្ថាប័នមួយទៀតដើម្បីដោះស្រាយវិវាទបែបសន្ទានកម្ម និង

[១១] ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា៨៩

[១២] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា៩០

[១៣] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា៩២

[១៤] ច្បាប់លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨, មាត្រា៩៣

ផ្សះផ្សា គឺមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ ដែលមានតួនាទីផ្តល់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងការសម្រុះសម្រួល និងផ្សះផ្សា ហើយក៏ជាអ្នកផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋ និងមន្ត្រីមូលដ្ឋានផងដែរ។ មិនតែប៉ុណ្ណោះ មណ្ឌលសេវាកម្មនេះក៏ជាអ្នកផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសដោះស្រាយវិវាទ និងការងារយុត្តិធម៌នៅមូលដ្ឋានផងដែរ។[១៥]

សម្រាប់ការដោះស្រាយវិវាទនៅថ្នាក់ឃុំ សង្កាត់វិញ គឺក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំជ្រើសរើសមេភូមិម្នាក់សម្រាប់ចំណុះក្នុងឃុំ សង្កាត់ ដើម្បីធានានូវសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ចាត់ចែង និងសម្របសម្រួលកិច្ចការក្នុងភូមិ ព្រមទាំងស្នើសុំទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីចាត់ចែង និងសម្របសម្រួលកិច្ចការក្នុងភូមិ។[១៦] ដូចគ្នានឹងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែរ រដ្ឋាភិបាលក៏បានបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ដែលមានតួនាទីជួយកាត់បន្ថយ និងគ្រប់គ្រងទំនាស់ដែលកើតមានឡើងនៅតាមមូលដ្ឋានដោយធ្វើការសម្រុះសម្រួលទៅដល់ភាគីទំនាស់ប្រសិនជាមានការព្រមព្រៀងឱ្យជួយដោះស្រាយ។ បន្ថែមពីនេះទៅទៀត គណៈកម្មាធិការនេះមានភារកិច្ចជួយដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ ក្នុងការពង្រឹងសមត្ថភាពដោះស្រាយទំនាស់ ព្រមទាំងផ្តល់ការពិគ្រោះយោបល់ និងផ្សព្វផ្សាយផ្នែកច្បាប់ជូនប្រជាពលរដ្ឋផងដែរ។[១៧]

សម្រាប់ការដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីដូចជានៅក្រៅតំបន់វិនិច្ឆ័យ និងក្នុងតំបន់វិនិច្ឆ័យដែលមិនអាចសម្រុះសម្រួលដោយគណៈកម្មការរដ្ឋបាលបានមានគណៈកម្មការសុរិយោដីជាអ្នកដោះស្រាយ។ គណៈកម្មការនេះចែកចេញជាបីថ្នាក់គឺ ថ្នាក់ស្រុក ខណ្ឌ ថ្នាក់ខេត្ត ក្រុង និងថ្នាក់ជាតិ។[១៨]

គណៈកម្មការសុរិយោដីស្រុក ខណ្ឌ មានតួនាទី ចុះបញ្ជី និងបើកសំណុំរឿងក្តីដែលទទួលបាន និងជួយធ្វើការសម្រុះសម្រួល ព្រមទាំងស៊ើបអង្កេតលើវិវាទដោយធ្វើការបញ្ជាក់ពីទីតាំងដែលមានវិវាទ ភាគីពាក់ព័ន្ធនឹងកម្មវត្ថុនៃវិវាទ និងប្រមូលឯកសារដែលមានចម្លើយសាក្សី ព័ត៌មានទាក់ទងនឹងវិវាទ។ ប៉ុន្តែប្រសិនបើគូភាគីវិវាទមិនធ្វើការស្រុះស្រួលគ្នាទេ វិវាទនោះនឹងត្រូវបញ្ជូនទៅគណៈកម្មការថ្នាក់ខេត្ត ក្រុង។[១៩]

---

[១៥] ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលសេវាកម្មយុត្តិធម៌, លេខ០៩០ កយ.ប្រក/១៨, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨, ប្រការ៧

[១៦] ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១, មាត្រា៣០-៣១

[១៧] សៀវភៅ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅឃុំ-សង្កាត់, គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃព្រឹទ្ធសភា និងលេខាធិការដ្ឋានអមគណៈកម្មានីតិកម្ម និងយុត្តិធម៌នៃព្រឹទ្ធសភា, បោះពុម្ពឆ្នាំ២០១៧, ទំព័រទី៤-៥

[១៨] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ៤៧ អនក្រ.បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, មាត្រា៣

[១៩] អនុក្រឹត្យ លេខ៤៧ អនក្រ.បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, មាត្រា៧-១១

គណៈកម្មការថ្នាក់ខេត្ត ក្រុង ពុំមានសិទ្ធិសម្រេចលើវិវាទករណីណាមួយទេ ប៉ុន្តែអាចបញ្ចប់វិវាទបានក្នុងករណីភាគីវិវាទទាំងអស់ព្រមព្រៀងគ្នាជាឯកច្ឆន្ទ។ ប្រសិនបើវិវាទអាចសម្រុះសម្រួលបាន ត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ដូចជាភូមិបាលស្រុក ខណ្ឌ ដើម្បីដំណើរការអនុវត្តការចុះបញ្ជីដីធ្លីដែលសម្រេចបាន។ ប៉ុន្តែក្នុងករណី មិនអាចសម្រុះសម្រួលបានទេត្រូវបញ្ជូនសំណុំរឿងវិវាទជាលាយលក្ខណ៍អក្សរទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។[២០]

## ១.៤. ទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

១.៤.១. ការចរចា(Negotiation)

"ការចរចា" ជាត្រូវបានប្រើដោយគូភាគីវិវាទដោះស្រាយវិវាទដោយសម្របសម្រួល និងដោយគ្មានជំនួយភាគីទីបីដែលបង្កើតឡើងសម្រាប់គូភាគីក្នុងការបង្កើតដំណោះស្រាយណាមួយដែលពួកគេចង់បាន។ ទម្រង់នេះមានលក្ខណៈសាមញ្ញក្នុងការដោះស្រាយជម្លោះរវាងមនុស្ស និងត្រូវបានប្រើប្រាស់ប្រចាំថ្ងៃនៅក្នុងទំនាក់ទំនងគ្រប់ប្រភេទ។ ការទំនាក់ទំនងនេះអាចជារឿងផ្ទាល់ខ្លួន សង្គមវិជ្ជាជីវៈ ឬការជួបធម្មតា ហើយពេលខ្លះអ្នកចរចាមិនដឹងថាខ្លួនកំពុងធ្វើការចរចានោះទេ។ ការចរចានេះមានវិធីសាស្ត្រច្រើនដូចជាលក្ខណៈផ្លូវការ (ការប្រជុំ ឬកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ) ឬលក្ខណៈមិនផ្លូវការ (តាមរយៈទូរស័ព្ទ សារអេឡិចត្រូនិច ឬសំបុត្រ)។

នីតិវិធីចរចា នេះកើតឡើងនៅពេលភាគីវិវាទទាំងពីរបានបង្កើតនូវដំណោះស្រាយតាមអ្វីដែលពួកគេចង់បានហើយឈានដល់កិច្ចព្រមព្រៀងរហូតដល់ភាគីទាំងសងខាងពេញចិត្ត។[២១] ការចរចាអាចធ្វើទៅបានផ្អែកលើវិធីសាស្ត្រពីរយ៉ាងគឺ ការចរចាបែងចែក និងការចរចាផ្អែកលើផលប្រយោជន៍។

### ១.៤.១.១. វិធីសាស្ត្រនៃការចរចា

ការចរចាអាចធ្វើទៅបានផ្អែកលើវិធីសាស្ត្រពីរយ៉ាងគឺ "ការចរចាបែបបែងចែក(ឈ្នះ-ចាញ់)" និង "ការចរចាផ្អែកលើផលប្រយោជន៍(ឈ្នះ-ឈ្នះ)"។

**ក. ការចរចាបែងចែក (ឈ្នះ-ចាញ់)**

ក្នុងការចរចាបែបបែងចែកអាចសន្មត់ជាមូលដ្ឋានថា មានធនធានចំនួនជាក់លាក់មួយដែលពួកគេត្រូវបែងចែករវាងគ្នា និងគ្នា។[២២] ប្រសិនបើភាគីម្ខាងទទួលបានកាន់តែច្រើនភាគីម្ខាងទៀតទទួលបានកាន់តែតិច។

[២០] អនុក្រឹត្យ លេខ៤៧ អនក្រ.បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២, មាត្រា១៥-១៦

[២១] ឯកសារស្រាវជ្រាវសង្ខេប ស្ដីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា, គុប ដារី, គណៈកម្មការទី១ ព្រឹទ្ធសភា, ទំព័រទី២

[២២] ជួបកាលគេអាចហៅបានម្យ៉ាងទៀតថា "ការតថ្លៃដោយប្រកាន់ជំហរ ឬការចរចារ ផលសរុបស្មើសូន្យ"

និយាយរួមមកធនធាន គឺសំដៅលើតម្លៃគិតជាប្រាក់។ ក្នុងអំឡុងពេលចរចាភាគីវិវាទជាអ្នកកំណត់ពីជំហររៀងៗខ្លួន។ ភាគីចុងចម្លើយដឹងពីអប្បបរមាដែលខ្លួនមានឆន្ទៈត្រូវបង់ និងភាគីជាជនរងគ្រោះដឹងពីអប្បបរមាដែលខ្លួនមានឆន្ទៈក្នុងការទទួលយក។

ភាគីនីមួយៗ ធ្វើការនិយាយតតាំងគ្នាចុះឡើងអំពីតម្លៃដែលខ្លួនស្នើ។ ជួនកាលភាគីទាំងសងខាងអាចឈានដល់ការស្រុះស្រួលព្រមព្រៀងគ្នា និងជួនកាលអាចនឹងមិនព្រមព្រៀងគ្នា។ ក្នុងការចរចានេះប្រការសំខាន់នោះគឺត្រូវព្យាយាមកំណត់តម្លៃអប្បបរមាទៅកាន់ភាគីម្ខាងទៀតឱ្យបានត្រឹមត្រូវបំផុតតាមដែលអាចធ្វើទៅបាន។ ការចរចាបែបបែងចែកហាក់មានប្រសិទ្ធភាពបំផុតនៅពេលដែលបញ្ហាមានលក្ខណៈសាមញ្ញ ប្រាក់ថ្នូរមានតម្លៃទាបសមល្មម ហើយការតថ្លៃនឹងត្រូវបានបង្ហាញ និងរំពឹងទុកយ៉ាងត្រឹមត្រូវ។

**ខ. ការចរចាផ្អែកលើផលប្រយោជន៍(ឈ្នះ-ឈ្នះ)**

ការចរចាប្រភេទនេះមានលក្ខណៈផលប្រយោជន៍ជាធំ មានន័យភាគីវិវាទមានការសហការច្រើនជាងការចរចាបែងចែក ព្រោះគេត្រូវសន្មត់ថាមានផលប្រយោជន៍សំខាន់ៗដទៃទៀតដែលគេត្រូវរកឱ្យឃើញថាវាពិតជាសមស្របនឹងតម្រូវការ។ ពោលគឺភាគីវិវាទអាចមានប្រយោជន៍មួយចំនួនរួមគ្នា ឬយ៉ាងហោចណាស់ផលប្រយោជន៍មួយចំនួនដែលបំពេញបន្ថែមឱ្យគ្នា។

### ១.៤.១.២. គុណសម្បត្តិនិងគុណវិបត្តិនៃការចរចា

**ក. គុណសម្បត្តិនៃការចរចា**

គុណសម្បត្តិនៃការចរចាមានដូចខាងក្រោម៖

- **សន្សំសំចៃការចំណាយ៖** ការចរចាត្រូវចំណាយប្រាក់តិចជាងវិធីដោះស្រាយផ្សេងទៀត។ នេះគឺជាចំណែកមួយដែលនាំឱ្យការចរចាមានប្រជាប្រិយភាព។ដោយមិនចំណាយទៅលើប្រាក់ប្រដាប់ក្តី ឬចំណាយផ្សេងៗទៀត។
- **ឯកជនភាព៖** ការចរចាអាចជាដំណើរការឯកជនភាពទាំងស្រុង ដោយគ្រាន់តែធ្វើឡើងរវាងភាគី និងភាគី ឬតំណាងរបស់ពួកគេតែប៉ុណ្ណោះ។ ដោយគ្មានការចូលរួមពីសំណាក់តុលាការ និងគ្មានវត្តមានអ្នកសារព័ត៌មាន និងគ្មានអ្នកដទៃចូលរួមទេ។
- **ភាពបត់បែន៖** ការចរចាមានភាពបត់បែនទាំងក្នុងដំណើរការ និងលទ្ធផល។ ទី១ ដំណើរការ នៃការចរចាអាចមានលក្ខណៈបត់បែនខ្លាំង ព្រោះដំណើរការអាចធ្វើឡើងក្រៅផ្លូវការ ឬតាមផ្លូវការ។ ដោយមនុស្សពីរនាក់អាចធ្វើការចរចានៅតាមផ្លូវ ឬអាចធ្វើឡើងក្រៅផ្លូវការដោយភាគីវិវាទ និងមេធាវីរបស់ពួកគេផ្ញើសំបុត្រជាលាយលក្ខណ៍អក្សរឱ្យគ្នាទៅវិញទៅមក។ ទី២ លទ្ធភាព នៃការ

ចរចាអាចមានលក្ខណៈបត់បែនយ៉ាងខ្លាំងព្រោះភាគីវិវាទផ្ទាល់ជាអ្នកឈានដល់ការស្រុះស្រួល។ ពួកគេអាចព្រមព្រៀងគ្នាទៅលើដំណោះស្រាយផ្សេងៗជាច្រើន ដែលការដោះស្រាយនេះមិនអាចធ្វើទៅបានឡើយតាមរយៈមជ្ឈត្តការ ឬបណ្តឹងតុលាការ។

- **ល្បឿន៖** ការចរចាមានសក្តានុពលអាចដោះស្រាយបញ្ហាបានឆាប់រហ័ស និងប្រសិទ្ធភាព ដោយភាគីមិនចាំបាច់ត្រូវរង់ចាំ ចៅក្រម មជ្ឈត្តករ ឬសន្ធានការី ដើម្បីធ្វើសវនការសម្រេចរឿងក្តីនោះ។ បញ្ហាត្រូវបានដោះស្រាយភ្លាមៗ ឱ្យតែភាគីឈានដល់ការស្រុះស្រួលគ្នា។
- **លទ្ធភាពនៃការគ្រប់គ្រងរបស់ភាគី៖** ការចរចាផ្តល់ឱ្យភាគីវិវាទនូវលទ្ធភាពគ្រប់យ៉ាងពេញលេញទៅលើដំណើរការ និងការបញ្ចប់។ ភាគីវិវាទជាអ្នកកំណត់ទៅលើដំណើរការថាតើ ត្រូវចរចាដោយរបៀបណា ត្រូវស្រុះស្រួលគ្នាឬទេ។ នៅក្នុងការចរចា គេមិនអាចបង្ខំភាគីណាមួយឱ្យចូលក្នុងដំណើរការចរចា ឬស្រុះស្រួលគ្នា ដោយគ្មានការព្រមព្រៀងពីភាគីនោះឡើយ។
- **ការរក្សាទំនាក់ទំនងជាបន្ត៖** ការចរចាផ្តល់លទ្ធភាពដល់ភាគីវិវាទក្នុងការរិះរកការស្រុះស្រួលមួយដែលអាចរក្សាទំនាក់ទំនងដែលពួកគេមាន។
- **ការអនុវត្តដោះស្រាយ៖** ការស្រុះស្រួលតាមរយៈការចរចាលើរឿងក្តីណាមួយត្រូវមានការកត់បញ្ចូលក្នុងនីតិវិធីតុលាការនៅចំពោះមុខចៅក្រម ហើយអនុវត្តបានដូចចៅក្រម។

### ខ. គុណវិបត្តិនៃការចរចា

ការចរចាក៏មាននូវគុណវិបត្តិមួយចំនួនដូចជា៖

- **ការពន្យាពេល៖** គុណវិបត្តិមួយនៃការចរចា គឺភាគីម្ខាងអាចធ្វើការពន្យាពេលការចរចាបាន។ ក្នុងស្ថានភាពនេះ មិនមានភាគីណាអាចបង្ខំភាគីណាដើម្បីពន្លឿនពេលដោះស្រាយបានឡើយ។ វាជាលទ្ធភាពមួយដែលភាគីអាចគេចវេសពីការស្រុះស្រួលគ្នា ឬប្រើទម្រង់នេះសម្រាប់ពន្យាពេលពី ការដោះស្រាយបញ្ហា ឬគេចវេសពីបណ្តឹងតុលាការ។
- **ភាគីគ្មានហេតុផល៖** ជាកំណត់សម្គាល់ស្រដៀងគ្នានេះ ភាគីក៏ទើបប្រទះដែរនូវលទ្ធភាពដែលភាគីម្ខាងទៀតអាចប្រកាន់ជំហរមិនសមហេតុផលនៅក្នុងការចរចាដូចដែលបានរៀបរាប់ខាងលើករណីនេះអាចដោយសារតែពួកគេមិនប្រាកដប្រជាចំពោះការចរចានោះហើយកំពុងប្រើប្រាស់មធ្យោបាយនេះដើម្បីពន្យាពេលវេលា ឬគេចវេសពីបណ្តឹងតុលាការ។
- **ការអនុវត្តការដោះស្រាយ៖** បន្ទាប់ពីការចរចា ភាគីអាចឯកភាពគ្នាលើកិច្ចព្រមព្រៀងស្រុះស្រួលមួយដែលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខា។ ប៉ុន្តែ មួយរយៈក្រោយមកភាគី

ណាមួយអាចមិនអាចគោរពតាមលក្ខខ័ណ្ឌនៃការស្រុះស្រួលនោះ។ ដោយសារការស្រុះស្រួលនោះគ្រាន់តែជាកិច្ចព្រមព្រៀងតាមរយៈការចរចា ភាគីម្ខាងទៀតគ្មាននីតិវិធីដោយផ្ទាល់ណាមួយក្នុងការដាក់អនុវត្តតាមផ្លូវតុលាការឡើយ។[២៣]

- **ភាគីម្ខាងមានអំណាចខ្លាំងពេក៖** មានកាលៈទេសៈមួយចំនួនដែលភាគីមិនមានវិសមភាពនឹងគ្នានៅក្នុងការចរចា ជាហេតុនាំឱ្យភាគីម្ខាងមានសិទ្ធិត្រួតត្រាហួសហេតុពេក។ ឧទាហរណ៍ អ្នកជំនួញដ៏ស្តុកស្តម និងមានអំណាចម្នាក់អាចខកខានមិនបានបង់ប្រាក់ឱ្យជាងជួសជុលរថយន្តម្នាក់។ ជាងជួលជុលរថយន្តអាចស្ថិតនៅក្រោមសម្ពាធ ឬការគំរាមកំហែងពីអ្នកជំនួញរូបនោះក្នុងកំឡុងពេលចរចាជាឯកជន។ វាជាលទ្ធភាពមួយដែលថាជាងជួសជុលរថយន្តនោះ នឹងចុះញ៉មចំពោះការគំរាមកំហែង ហើយព្រមទទួលយកដំណោះស្រាយមិនសមរម្យមួយ។ ក្នុងការចរចាជាលក្ខណៈឯកជនមិនមានភាគីទីបីណាមួយអាចបង្ការលទ្ធផលដ៏អយុត្តិធម៌បែបនោះឡើយ។

គុណវិបត្តិទាំងនេះទោះបីជាគួរឱ្យពិចារណាក្តី តែកម្រនឹងកើតមានឡើងណាស់។ ជាធម្មតាការចរចា គឺជាជម្រើសដំបូងដ៏ល្អបំផុត។ មុននឹងដាក់ពាក្យបណ្តឹង ឬសំអាងលើលក្ខខណ្ឌស្តីពីមជ្ឈត្តការ មេធាវីភាគច្រើនតែងសាកល្បងធ្វើការចរចា ព្រោះវាមានភាពឆាប់រហ័ស និងមានតម្លៃថោកជាងវិធីដោះស្រាយវិវាទផ្សេងទៀត។ ជាទូទៅ គ្មានអ្វីដែលត្រូវបាត់បង់ក្នុងការព្យាយាមចរចាលើវិវាទមួយនោះឡើយ។

១.៤.២. សន្ធានកម្ម(Mediation)

"សន្ធានកម្ម" អាចត្រូវបានផ្តល់និយមន័យយ៉ាងទូលំទូលាយថា ជាការចរចាដែលមានជំនួយ ឬការជួយសម្របសម្រួល។ ជាទូទៅ សន្ធានកម្មត្រូវមានភាគីវិវាទពីរ ឬច្រើនដែលព្យាយាមចរចាលើដំណោះស្រាយមួយ ដោយមានជំនួយពីភាគីទីបី គឺសន្ធានការីដែលមានអព្យាក្រឹតភាពចំពោះភាគីទាំងនោះ ក៏ដូចជាលទ្ធផលនៃដំណោះស្រាយនោះផ្ទាល់។ សន្ធានការីមិនមានសិទ្ធិអំណាចក្នុងការចាប់បង្ខំឱ្យយកដំណោះស្រាយណាមួយឡើយ។ ផ្ទុយទៅវិញ ភាគីវិវាទនៅតែមានសិទ្ធិអំណាចក្នុងការសម្រេចថាតើខ្លួនចង់ ឬមិនចង់ដោះស្រាយ។ ប្រសិនបើភាគីវិវាទមិនចង់ដោះស្រាយ ឬមិនមានការព្រមព្រៀងគ្នា នោះនឹងគ្មានដំណោះស្រាយឡើយ ទោះបីជា

[២៣] សៀវភៅ ស្តីពីទស្សនាទានសំខាន់ៗដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ស្ទីវិន អ៊ែម អូស្ទើមីឡឺ, បោះពុម្ពលើកទី២ ឆ្នាំ២០១០, ទំព័រទី១៥-១៨

[២៤] សៀវភៅ ស្តីពីទស្សនាទានសំខាន់ៗដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ស្ទីវិន អ៊ែម អូស្ទើមីឡឺ, បោះពុម្ពលើកទី២ ឆ្នាំ២០១០, ទំព័រទី១២៣

មានការខិតខំប្រឹងប្រែងរបស់សន្ធានការីយ៉ាងណាក៏ដោយ។ មិនដូចក្នុងមជ្ឈត្តការ ឬបណ្តឹងទៅតុលាការឡើយ សន្ធានការីគ្រាន់តែអាចស្នើឡើងនូវដំណោះស្រាយចំពោះភាគីតែប៉ុណ្ណោះ។

### ១.៤.២.១. តួនាទីរបស់សន្ធានការី

ជាទូទៅសន្ធានការី ត្រូវមានភាពសម្រុះសម្រួលជាមួយមនុស្សគ្រប់ប្រភេទ។ ពេលគឺជាអ្នកស្តាប់ត្រូវមានឆន្ទៈក្នុងការស្វែងយល់អំពីចំណុចខ្លាំង និងខ្សោយនៃការទាមទាររបស់ភាគីនីមួយៗ។ ជាទូទៅ សន្ធានការីត្រូវតែអព្យាក្រឹត្យមិនលម្អៀងទៅតែម្ខាងនោះទេ ត្រូវដើរតួនាទីជាអ្នកតស៊ូមតិ ផ្តោតលើការពិភាក្សា ឬផ្តល់យោបល់ជាជំនួយក្នុងការដោះស្រាយវិវាទ ព្រមទាំងស្វែងរកជម្រើសដំណោះស្រាយសមប្រកបដោយឱ្យភាគីវិវាទទាំងពីរពេញចិត្តនឹងសម្រុះសម្រួល។[២៤]

### ១.៤.២.២. គុណសម្បត្តិ និងគុណវិបត្តិនៃសន្ធានកម្ម

#### ក. គុណសម្បត្តិនៃសន្ធានកម្ម

ចំពោះគុណសម្បត្តិនៃសន្ធានកម្មមានដូចជា៖

- **ល្បឿន៖** សន្ធានកម្មអនុញ្ញាត្តអោយគូដោះស្រាយវិវាទលំបាករយៈពេលមួយដ៏ខ្លី ជាទូទៅរយៈពេលមួយថ្ងៃ ឬតិចជាងនេះ។ បណ្តឹងតុលាការ ឬមជ្ឈត្តការអាចប្រើពេលវេលាអស់ជាច្រើនខែ ឬច្រើនឆ្នាំ។ ការចរចាមានសក្តានុពលដោះស្រាយយ៉ាងឆាប់រហ័សដោយគ្មានកំណត់ពេល ប៉ុន្តែនៅពេលមានភាពបន្ទាន់វាអាចអូសបន្លាយពេលយូរបានដែរ។ ផ្ទុយមកវិញ សន្ធានកម្មជាទូទៅ គឺជាព្រឹត្តិការណ៍តែមួយដែលកើតឡើងរយៈពេលខ្លី និងដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស។
- **ការចំណាយពេល៖** ស្របពេលដែលការចរចាជាឯកជន តែងតែជាបច្ចេកទេសដោះស្រាយវិវាទដែលមានតម្លៃថោកជាងគេបំផុតនោះ ការចំណាយសម្រាប់សន្ធានកម្មក៏ច្រើនតែមានតម្លៃទាបជាងជម្រើសដទៃទៀតដូចជា បណ្តឹងតុលាការ ឬមជ្ឈត្តការដែរ។ ជាទូទៅ សន្ធានកម្មមានរយៈពេលមួយ ឬពីរថ្ងៃ ដូច្នេះថ្លៃសោហ៊ុយមេធាវី និងថ្លៃឈ្នួលមជ្ឈមណ្ឌលសន្ធានកម្មក៏មានតម្លៃទាបតាមនោះដែរ។ ចំពោះវិវាទសាមញ្ញ សន្ធានកម្មដែលធ្វើឡើងដោយមិត្តភក្តិ ឬសាច់ញាតិជាដើមនោះគឺមិនអស់ថ្លៃអ្វីទាំងអស់ ដូចជាការចរចាដូច្នោះដែរ។

[២៤] សៀវភៅ ស្តីពីទស្សនាទានសំខាន់ៗដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ស៊្វីរិន អ៊ែម អូស្ទើមីឡឺ, បោះពុម្ពលើកទី២ ឆ្នាំ២០១០, ទំព័រទី១២៣

- **ការគ្រប់គ្រងរបស់ភាគីចំពោះលទ្ធផល៖** ជាមួយសន្ធានកម្ម គូភាគីនៅតែជាអ្នកសម្រេចទៅលើលទ្ធផលដដែល។ ភាគីអាចសម្រេចថាតើនឹងមានដំណោះស្រាយដែរឬទេ និងនៅក្នុងលក្ខខណ្ឌ អ្វីខ្លះ។ ម៉្យាងទៀត ភាគីធ្វើការកំណត់ផងដែរថាតើដំណើរការនោះនាំអោយខាតពេលវេលាឬទេ ហើយគួរតែបញ្ចប់ ឬយ៉ាងណា។ គ្មាននរណាម្នាក់អាចបង្ខំភាគីសន្ធានកម្មឱ្យធ្វើអ្វីមួយនោះទេ។
- **ការរក្សាសម្ព័ន្ធភាពជាបន្តៈ** ដូចជាការចរចាដែរ សន្ធានកម្មអនុញ្ញាតឱ្យភាគីអាចធ្វើការរៀបចំដំណោះស្រាយមួយដែលអាចរក្សាសម្ព័ន្ធភាពរបស់ពួកគេជាបន្តទៅទៀត។ ប្រការនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់សង្គមខ្មែរ ក៏ព្រោះតែទំនាក់ទំនងផ្ទាល់ខ្លួនគឺជាកត្តាចាំបាច់សម្រាប់ការប្រាស្រ័យទាក់ទងនៅក្នុងសង្គម និងសកម្មភាពក្នុងវិស័យដទៃទៀត។
- **ភាពជាឯកជន៖** ដំណើរការសន្ធានកម្មតម្រូវឱ្យមានការរក្សាសម្ងាត់។ យុត្តាធិការជាច្រើនផ្តល់ការការពារដល់អ្នកដែលពាក់ព័ន្ធទៅនឹងការចរចា ឬសន្ធានកម្ម ទោះបីជាវាមិនបណ្តាលឱ្យមានការព្រមព្រៀង ហើយវិវាទនោះត្រូវបន្តការប្តឹងផ្តល់ក៏ដោយ។
- **លទ្ធភាពបត់បែន៖** ភាគីវិវាទមានលទ្ធភាពបត់បែនជាច្រើនក្នុងការរៀបចំដំណើរការសន្ធានកម្ម។ សន្ធានការីអាចដើរតួនាទីត្រឹមតែជួយសម្របសម្រួលធម្មតាដោយស្តាប់ភាគីនីមួយៗ និងធ្វើការលើកទឹកចិត្តដល់ពួកគេ។ សន្ធានការីមានតួនាទីយ៉ាងសកម្ម ក្នុងការជួបប្រជុំជាមួយភាគីនីមួយៗ ដោយឡែកពីគ្នាដើម្បីស្វែងយល់បន្ថែមអំពីផលប្រយោជន៍ និងជំហររបស់ពួកគេ ហើយនៅទីបំផុតថែមទាំងអាចស្នើឡើងនូវដំណោះស្រាយដែលអាចមានទៀតផងដែរ។
- **ការអនុវត្តដំណោះស្រាយ៖** ជាទូទៅកិច្ចព្រមព្រៀងដែលកើតពីសន្ធានកម្មដែលចំណុះឱ្យស្ថាប័នតុលាការអាចយកមកអនុវត្តដូចសាលក្រមតុលាការដែរ (មានន័យថាវាមានដំណើរការអនុវត្តឆាប់រហ័ស)។ អាស្រ័យទៅលើយុត្តាធិការនីមួយៗ កិច្ចព្រមព្រៀងចេញពីសន្ធានកម្មឯកជនដែលធ្វើឡើងនៅវេទិកាធ្វើមជ្ឈត្តកម្មគួរតែទទួលបានសិទ្ធិអនុវត្តយ៉ាងឆាប់រហ័សបែបនេះ។
- **ឱកាសខ្ពស់នៃការព្រមព្រៀង៖** កម្មវិធីសន្ធានកម្មជាច្រើនរាយការណ៍ថាមានអត្រាព្រមព្រៀងខ្ពស់។ ផ្អែកលើតួលេខនេះសន្ធានកម្មអាចមានភាពជោគជ័យក្នុងការសម្រេចបានការព្រមព្រៀងជាងការចរចា។ សន្ធានកម្មជោគជ័យជាងការចរចាដោយសារមូលហេតុមួយចំនួន។ មូលហេតុទីមួយ គឺនៅក្នុងសន្ធានកម្មភាគីវិវាទមានឱកាសពិសេសក្នុងការជួប និងស្តាប់រឿងរ៉ាវរបស់ភាគីម្ខាងទៀតនៅក្នុងក្របខ័ណ្ឌក្រៅផ្លូវការ។ មូលហេតុទីពីរ គឺការចរចាតាមរយៈមេធាវីអាចមានហានិភ័យដែលថាព័ត៌មានអាចនឹងត្រូវបំប្លែង ឬយល់ខុសនៅពេលវាត្រូវបានបញ្ជូនពីភាគី "ក" ទៅមេធាវីរបស់ភាគី "ក" នោះបន្ទាប់មកគឺពីមេធាវីរបស់ភាគី "ខ" ទៅភាគី "ខ" ផ្ទាល់។ នៅក្នុងសន្ធានកម្មការប្រាស្រ័យ

ទាក់ទងគ្នាអាចត្រូវបានធ្វើឡើងដោយផ្ទាល់ និងច្បាស់លាស់។ មូលហេតុទីបី គឺការចរចាច្រើនតែធ្វើឱ្យជម្លោះបុគ្គលិកលក្ខណៈរបស់មេធាវីចរចាពីររូបកាន់តែមានភាពធ្ងន់ធ្ងរឡើង។ ចំណែកឯសន្ធានកម្មវិញអនុញ្ញាតឱ្យភាគីអព្យាក្រឹតដោះស្រាយបញ្ហាទាំងនោះ។ មូលហេតុទីបួន គឺក្នុងករណីមានការសង្ស័យគ្នាទៅវិញទៅមក នោះសំណើរដោះស្រាយរបស់សន្ធានការីអាចត្រូវបានទទួលយកដោយគ្មានការសង្ស័យជាជាងសម្ដីដែលលើកឡើងដោយមេធាវីបដិបក្ខរបស់ភាគីខាងណាមួយ។

- **ថ្ងៃឡើងតុលាការរបស់ភាគីវិវាទ៖** វាជារឿងសំខាន់សម្រាប់ភាគីក្នុងការមានឱកាសប្រាប់ភាគីម្ខាងទៀតអំពីរឿងរ៉ាវរបស់ខ្លួន និងមានអារម្មណ៍ដូចជាខ្លួនត្រូវបានគេស្ដាប់។ ប្រការនេះអាចធ្វើឱ្យភាគីមានអារម្មណ៍ល្អប្រសើរជាងមុនបន្តិចទោះជាមានល័ក្ខខ័ណ្ឌនៃការព្រមព្រៀងបែបណាក៏ដោយ។ នៅក្នុងប្រទេសមួយចំនួន ចំណុចនេះត្រូវបានគេហៅថា "ថ្ងៃឡើងតុលាការ" ។
- **ជៀសវាងអំពើពុករលួយ៖** លក្ខណៈស្ម័គ្រចិត្តនៃដំណោះស្រាយតាមសន្ធានកម្ម ធ្វើឱ្យអ្នកចូលរួមមិនសូវរងគ្រោះនឹងអំពើពុករលួយទេ។ សន្ធានការីគ្មានសិទ្ធិក្នុងការបង្ខំឱ្យភាគីព្រមព្រៀងគ្នាតាមរយៈឧបាយកលរបស់ខ្លួន ឬការបង្ខិតបង្ខំទាមទាររកកម្រៃផ្សេងៗនោះទេ។
- **ការជ្រើសរើសការអព្យាក្រឹត៖** នៅក្នុងកិច្ចប្រជុំសន្ធានកម្ម ភាគីវិវាទធ្វើការជ្រើសរើសភាគីអព្យាក្រឹតរបស់ខ្លួន។ ពោលគឺខុសគ្នាពីដំណើរការបណ្ដឹងទៅតុលាការដែលចៅក្រមត្រូវបានចាត់តាំងឡើង។ ការជ្រើសរើសនេះអាចជួយឱ្យភាគីមានអារម្មណ៍ជឿជាក់ថាសន្ធានការីមិនលម្អៀង។

### ខ. គុណវិបត្តិនៃសន្ធានកម្ម

ចំណែកឯគុណវិបត្តិនៃសន្ធានកម្មវិញមាន៖

- **ភាគីដែលគ្មានហេតុផល៖** គ្មានភាគីណាមួយនៅក្នុងសន្ធានកម្មត្រូវបានបង្ខំលើអ្វីមួយឡើយ។ ចំណុចនេះជាគុណសម្បត្តិផង និងគុណវិបត្តិផង។ ប្រសិនបើភាគីគ្មានហេតុផល និងមិនចង់ធ្វើការដោះស្រាយនោះទេគ្មានអ្វីដែលសន្ធានការីអាចធ្វើបានឡើយ។ សន្ធានកម្មអាចនឹងក្លាយទៅជាការបំផ្លាញពេលវេលា និងលុយកាក់ឥតប្រយោជន៍ប្រសិនបើមានភាគីណាមួយ ឬភាគីទាំងពីរគ្មានហេតុផល ឬមិនមានឆន្ទៈក្នុងការដោះស្រាយ។
- **អំណាចចរចាមិនស្មើគ្នា៖** ប្រសិនបើភាគីមានអំណាចចរចាមិនស្មើភាពគ្នា សន្ធានកម្មមិនមែនជាការដោះស្រាយដែលល្អសម្រាប់ភាគីដែលខ្សោយប៉ុន្មានទេ។ ឧទាហរណ៍ ក្រុមហ៊ុនមួយមានអំណាចចរចាខ្លាំងជាង បើប្រៀបធៀបជាមួយហាងទំនិញជាលក្ខណៈគ្រួសារ។ ប្រសិនបើភាគីទាំង

ពីរធ្វើសន្ទានកម្ម ក្រុមហ៊ុនធំអាចគំរាមកំហែង ឬសម្លុតភាគីដែលទន់ខ្សោយជាងឱ្យព្រមព្រៀងលើដំណោះស្រាយដែលអយុត្តិធម៌បាន។ នៅក្នុងករណីនេះ ភាគីទន់ខ្សោយជាងអាចនឹងទទួលបានការការពារប្រសើរជាងនេះដោយវត្តមានចៅក្រម ឬមជ្ឈត្តករ។

- **ការអនុវត្តដំណោះស្រាយ៖** អាស្រ័យទៅតាមយុត្តាធិការនីមួយៗដំណោះស្រាយតាមរយៈ សន្ទានកម្មជាលក្ខណៈឯកជនខ្លះអាចមិនមានវិធានអនុវត្តន៍ឆាប់រហ័សនោះទេ។ ហេតុនេះហើយ តម្រូវអោយគូភាគីពិចារណាលើយុត្តាធិការនៅកន្លែងដែលខ្លួនចុះកិច្ចសន្យាដើម្បីធានាថាពួកគេយល់ពីវិធាននៃការអនុវត្តន៍នៅទីនោះ។
- **ការចំណាយ៖** សន្ទានកម្មមិនអស់ថវិកានោះទេ ប្រសិនបើសន្ទានការី គឺជាសមាជិកគ្រួសារ ឬជាមិត្តភក្តិរបស់ភាគីទាំងពីរនោះទេ។ ក៏ប៉ុន្តែ ប្រសិនបើវិវាទកើតឡើងក្នុងចំណោមអ្នកមិនមែនជាសាច់ញាត្តិ ឬក្រុមហ៊ុន អ្នកជាសន្ទានការី គឺជាភាគីអព្យាក្រឹតដែលយកថ្លៃឈ្នួល។
- **ឯកជន៖** ទោះបីជាការប្រាស្រ័យទាក់ទងគ្នារវាងភាគីវិវាទពាក់ព័ន្ធទៅនឹងសន្ទានកម្មត្រូវបានរក្សាជាការសម្ងាត់តាមច្បាប់ក្តី ក៏យុត្តាធិការមួយចំនួននៅប្រទេសកម្ពុជាមិនមានច្បាប់សន្ទានកម្មដែលផ្តល់ការការពារជាពិសេសដល់ការប្រាស្រ័យទាក់ទងគ្នាពាក់ព័ន្ធនឹងសន្ទានកម្មនៅឡើយទេ។ អាស្រ័យហេតុនេះភាគីមិនអាចធានាបាននូវភាពជាឯកជនបានមួយរយភាគរយឡើយ។[២៥]

១.៤.៣. មជ្ឈត្តកម្ម(Arbitration)

“មជ្ឈត្តកម្ម” គឺជាវិធីសាស្រ្តដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ចម្បងទីបី។ នៅក្នុងការធ្វើមជ្ឈត្តកម្ម គូភាគីដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបីដែលអព្យាក្រឹតមួយដែលជាទូទៅហៅថា “មជ្ឈត្តករ” ឬប្រសិនបើច្រើនជាងម្នាក់ហៅថា ក្រុមមជ្ឈត្តករ ឬវេទិកាមជ្ឈត្តករ។ ភាគីទីបីនេះពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្តីសម្រេចមួយហៅថា មជ្ឈត្តវិនិច្ឆ័យ។

នីតិវិធីនេះ ជាដំណើរការផ្លូវការក្នុងការដោះស្រាយក្រៅប្រព័ន្ធតុលាការដែលភាគីវិវាទត្រូវធ្វើការដាក់ពាក្យបណ្តឹងទៅរដ្ឋបាលទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬមជ្ឈមណ្ឌលអាជ្ញាកណ្តាល។ នៅក្នុងនីតិវិធីនេះ គូភាគីដែលពាក់ព័ន្ធនឹងវិវាទត្រូវជ្រើសរើសយកមជ្ឈត្តករដែលពួកគេជឿទុកចិត្តបានសម្រាប់ធ្វើការត្រួតពិនិត្យភស្តុតាង និងការធ្វើសេចក្តីសម្រេច។ សារៈប្រយោជន៍នៃនីតិវិធីនេះ គឺភាគីវិវាទជ្រើសរើសមជ្ឈត្តករដោយខ្លួនឯង និងអាចចូលរួមសវនាកាជាផ្លូវការដែលគ្រប់ភាគីបង្ហាញភស្តុតាងបាន។

[២៥] សៀវភៅ ស្តីពីទស្សនាទានសំខាន់ៗដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ស្ទីវិន អ៊ែម អូស្ទើមីឡឺ, បោះពុម្ពលើកទី២ ឆ្នាំ២០១០, ទំព័រទី១១២-១១៣

### ១.៤.៣.១. គុណសម្បត្តិ និងគុណវិបត្តិនៃមជ្ឈត្តកម្ម

#### ក. គុណសម្បត្តិនៃមជ្ឈត្តការ

ចំពោះមជ្ឈត្តការមានគុណសម្បត្តិជាច្រើនដូចជា៖

- **ថ្លៃចំណាយ៖** មជ្ឈត្តការចំណាយតិចជាងបណ្តឹងតុលាការ។ នេះដោយសារតែមជ្ឈត្តការមានភាពរលូនជាងបើធៀបទៅនឹងវិធានតុលាការ។ មួយវិញទៀត ក៏ដោយសារតែមជ្ឈត្តការ ជាទូទៅ ពុំមានការប្តឹងឧបាស្រ័យ។
- **ល្បឿន៖** មជ្ឈត្តការមានការដោះស្រាយវិវាទបានឆាប់រហ័សជាងបណ្តឹងតុលាការ។ ដូចដែលបានរៀបរាប់នៅខាងលើរួចហើយ មជ្ឈត្តការខុសពីបណ្តឹងតុលាការ។ ជាទូទៅគឺមិនអនុញ្ញាតឱ្យមានការប្តឹងឧបាស្រ័យឡើយ។ ផ្ទុយមកវិញ តាមរយៈដំណើរការបណ្តឹងតុលាការគូភាគីវិវាទអាចប្តឹងឧបាស្រ័យបានយ៉ាងហោចណាស់ម្តង ហើយជួនកាលច្រើនដងទៀតផង។ លើសពីនេះទៅទៀត ប្រព័ន្ធតុលាការមានរឿងក្តីដែលរង់ចាំការដោះស្រាយគរទុកយ៉ាងច្រើនដែលអាចនឹងបង្ខំឱ្យគូភាគីរង់ចាំការជំនុំជម្រះយ៉ាងយូរ។
- **លក្ខណៈស្ថាពរ៖** ដោយហេតុថាមជ្ឈត្តការមិនអាចប្តឹងឧបាស្រ័យបាន ជាទូទៅសេចក្តីសម្រេចរបស់មជ្ឈត្តការមានលក្ខណៈស្ថាពរ។ ប្រការនេះ គឺគុណសម្បត្តិធំផងចំពោះគូភាគី។
- **ការដាក់ឱ្យអនុវត្តថ្នាក់ជាតិ៖** ដោយសារតែប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នោះតុលាការកម្ពុជាអាចដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យដោយផ្ទាល់បាន។ ម៉្យាងទៀត ដំណោះស្រាយតាមការចរចា ឬសន្ធានកម្មមិនអាចដាក់ឱ្យអនុវត្តបានដោយងាយស្រួលបែបនេះនោះទេ។
- **ការដាក់ឱ្យអនុវត្តថ្នាក់អន្តរជាតិ៖** ដោយអនុលោមតាមអនុសញ្ញាក្រុងញ៉ូយកស្តីពីការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស(អនុសញ្ញាក្រុងញ៉ូយក)ដែលកម្ពុជាបានចុះហត្ថលេខាផងដែរនោះ។ មជ្ឈត្តវិនិច្ឆ័យដែលធ្វើឡើងក្នុងប្រទេសហត្ថលេខីអាចដាក់ឱ្យអនុវត្តបានដោយស្វ័យប្រវត្តិនៅក្នុងបណ្តាប្រទេសហត្ថលេខីផ្សេងទៀតទាំងអស់។[២៦] ប្រការនេះគឺគុណសម្បត្តិដ៏ធំសម្រាប់ដោះស្រាយវិវាទអន្តរជាតិដោយសារតែគ្មានប្រព័ន្ធដាក់ឱ្យអនុវត្តជាអន្តរជាតិស្រដៀងគ្នានេះសម្រាប់សេចក្តីសម្រេចរបស់តុលាការនៅឡើយ។

[២៦] មានប្រទេសជាង១៤០ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងញ៉ូវយក

- **ការរក្សាទំនាក់ទំនង៖** ទោះបីជាមជ្ឈត្តការមានទិដ្ឋភាពបដិបក្ខក៏ដោយ ជាទូទៅមជ្ឈត្តការមានភាពបដិបក្ខតិចជាងដំណើរការបណ្ដឹងតុលាការ។ កត្តានេះអាចជួយរក្សាទំនាក់ទំនងរវាងគូភាគីបាន។
- **ភាពឯកជន៖** ផ្ទុយពីដំណើរការបណ្ដឹងនៅតុលាការ ជាទូទៅមជ្ឈត្តការគឺដំណើរការជាឯកជន។ ប្រការនេះជាគុណសម្បត្តដ៏ធំប្រសិនបើគូភាគីមិនចង់ឱ្យសាធារណៈជនដឹងអំពីចំណុចលម្អិតនៃវិវាទរបស់ពួកគេ។
- **ដំណោះស្រាយអាចបត់បែនបាន៖** មជ្ឈត្តករតែងតែអាចមានភាពបត់បែនក្នុងការដាក់ចេញនូវមធ្យោបាយដោះស្រាយដែលប្រកបដោយភាពច្នៃប្រឌិតដែលតុលាការមិនអាចធ្វើបានឡើយ ដូចជាការសម្រេចឱ្យភាគីដែលឈ្នះក្ដីចេញថ្លៃមេធាវី ឬមជ្ឈត្តករជាដើម។[២៧]

### ខ. គុណវិបត្តិនៃមជ្ឈត្តការ

ថ្វីបើមជ្ឈត្តការមាននូវគុណសម្បត្តិជាច្រើនពិតមែន ប៉ុន្តែក៏នូវមានគុណវិបត្តិមួយចំនួនផងដែរ។ គុណវិបត្តិទាំងនោះរួមមាន៖

- **ថ្លៃចំណាយ៖** ទោះបីជាមជ្ឈត្តការ ជាទូទៅមានការចំណាយទាបជាងដំណើរការកាត់ក្ដីតុលាការក៏ពិតមែន ក៏មជ្ឈត្តការនៅតែអាចមានតម្លៃថ្លៃដែរ។ គូភាគីត្រូវបង់ថ្លៃសម្រាប់ពេលវេលារបស់មជ្ឈត្តករ បន្ទប់សវនការ ថ្លៃវេទិកាធ្វើមជ្ឈត្តករ ព្រមទាំងថ្លៃដំណើរការកាត់ក្ដីធម្មតាផ្សេងៗទៀតដូចជា ថ្លៃជួលមេធាវី និងចំណាយដែលពាក់ព័ន្ធដទៃទៀត។ ជាទូទៅ ដំណើរការនេះមានតម្លៃថ្លៃជាងការចរចា ហើយជួលថ្លៃជាងសន្ធាកម្មទៅទៀត។
- **ល្បឿន៖** ទោះបីជាមជ្ឈត្តការ ជាវិធីដោះស្រាយវិវាទឆាប់រហ័សជាងដំណើរការបណ្ដឹងតុលាការក៏ដោយក៏មជ្ឈត្តការអាចមានល្បឿនយឺតជាងការចរចា និងសន្ធានកម្មដែរ។ ជាធម្មតាគូភាគីត្រូវការពេលវេលាច្រើនដើម្បីរៀបចំក្ដីរបស់ខ្លួនសម្រាប់ការធ្វើមជ្ឈត្តការបើប្រៀបធៀបទៅការធ្វើសន្ធានកម្ម ឬការចរចា។
- **អនុលោមភាពមានកម្រិត៖** មជ្ឈត្តវិនិច្ឆ័យមិនមែនបានមកពីការចរចា និងការស្រុះស្រួលគ្នាទេ។ ហេតុនេះគឺអាចមានលទ្ធភាពច្រើននៃការមិនអនុលោមមជ្ឈត្តវិនិច្ឆ័យ។ ដូច្នេះគូភាគីអាចនឹងត្រូវការចំណាយថវិកាបន្ថែមកាន់តែច្រើនទៅលើថ្លៃមេធាវីដែលចាំបាច់ដើម្បីបន្តសុំការអនុវត្តដោះស្រាយតាមប្រព័ន្ធតុលាការ។

[២៧] សៀវភៅ ស្ដីពីទស្សនាទានសំខាន់ៗដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ស៊ីវិន អ៊ែម អូស្មើមីឡឺ, បោះពុម្ពលើកទី២ ឆ្នាំ២០១០, ទំព័រទី១៥០-១៥១

- **សវនការជាអសាធារណៈ៖** ស្ថានភាពខ្លះភាគីម្ខាងអាចចង់ឱ្យមានសវនការជាសាធារណៈ។ ឧទាហរណ៍ ដូចជាដើម្បីការពារខ្លួនជាសាធារណៈដើម្បីប្រឆាំងនឹងការប្ដឹងទាមទារ ឬដើម្បីដាក់ទណ្ឌកម្មភាគីម្ខាងទៀតជាដើម។ ដោយសារតែមជ្ឈត្តការមិនអនុញ្ញត្តឱ្យមានចំណុចនេះ ទើបវាជាគុណវិបត្តិដែលអាចនឹងកើតមានចំពោះគូភាគីនៅក្នុងស្ថានភាពជាក់លាក់មួយចំនួន។
- **លទ្ធផលមិនប្រាកដប្រជា៖** ប្រសិនបើមជ្ឈត្តករបំពេញតួនាទីជាអ្នកជួយសម្រុះសម្រួល ពួកគេនឹងវិនិច្ឆ័យរឿងក្ដីដោយផ្អែកលើគោលការណ៍សមភាពដោយពុំចាំបាច់ច្បាប់មកគ្រប់គ្រងឡើយ។ ប្រការនេះអាចនាំឱ្យមានភាពមិនច្បាស់លាស់។

១.៤.៤. ការផ្សះផ្សា(Conciliation)

"ការផ្សះផ្សា" ជាវិធីដែលភាគីទីបីជាអ្នកផ្សះផ្សាជួបជាមួយនឹងភាគីជម្លោះដាច់ដោយឡែកពីគ្នា (ការជួបដាច់ដោយឡែកពីគ្នាគឺខុសពីសន្ទានកម្ម)ដើម្បីស្វែងរកនូវការព្រមព្រៀងពីគូភាគីក្នុងការដោះស្រាយជម្លោះ។[២៨] ហើយអ្វីដែលបានឯកភាពគ្នានេះ គឺមិនមែនជាកាតព្វកិច្ចតាមផ្លូវច្បាប់ទេ។ ដូចគ្នាទៅនឹងនីតិវិធីសន្ទានកម្មដែរ ដោយអាស្រ័យទៅតាមវិវាទ នីតិវិធីផ្សះផ្សាវិវាទនេះធ្វើឡើងក្រៅផ្លូវការដោយភាគីទីបី ដូចជា ព្រះសង្ឃ អាចារ្យ អ្នកមានអំណាចដែលទុកចិត្តពីភាគីវិវាទ ឬព្រះមហាក្សត្រ (ជាគោលការណ៍) ហើយការផ្សះផ្សាជាផ្លូវការត្រូវបានធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាល ដែលបានចាត់តាំងដោយ រដ្ឋាភិបាល ឬអង្គចៅក្រម។[២៩]

នៅប្រទេសកម្ពុជា ដំណើរការផ្សះផ្សាដោះស្រាយវិវាទធ្វើឡើងក្នុងជីវភាពប្រចាំថ្ងៃ ហើយប្រជាពលរដ្ឋមិនដែលគិតថាវិវាទទាំងនោះជាករណី"ព្រហ្មទណ្ឌ" ឬ ករណី"រដ្ឋប្បវេណី" ឡើយ។ ប្រជាជនតែងតែប្រើរបៀបដោះស្រាយវិវាទបែបផ្សះផ្សានេះ ប្រសិនបើវិវាទទាំងនោះមិនមានផលប៉ះពាល់ធ្ងន់ធ្ងរខ្លាំងដល់ជីវភាពរបស់ពួកគេ។ នីតិវិធីនេះបានអនុញ្ញាត និងមាននៅក្នុងច្បាប់ផ្សេងៗរួមមានច្បាប់ស្ដីពីគ្រួសារ និងអាពាហ៍ពិពាហ៍ (វិវាទគ្រួសារ) ច្បាប់ការងារ (វិវាទការងារ) ច្បាប់ភូមិបាល និងបទបញ្ញត្តិ (វិវាទដីធ្លី) និងក្រមនីតិវិធីរដ្ឋប្បវេណី (បណ្ដឹងរដ្ឋប្បវេណី)។[៣០]

អ្នកផ្សះផ្សា មានតួនាទីសំខាន់ក្នុងការជួយភាគីជម្លោះដើម្បីស្វែងរកដំណោះស្រាយសម្រាប់បញ្ចប់បញ្ហារបស់ពួកគេ។ ព្រមទាំងមានតួនាទីបន្ទាប់បន្សំជាច្រើនដែលត្រូវធ្វើក្នុងពេលផ្សះផ្សា ដូចជាដើរតួនាទីអ្នកសម្របសម្រួល និងមិនមែនជាចៅក្រម ឬជាមេធាវីឱ្យភាគីណាមួយឡើយ។ ជាអ្នកអប់រំដល់ការបង្រៀនភាគីទាំងពីរឱ្យ

[២៨] ឯកសារស្រាវជ្រាវសង្ខេប, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ស៊ូ សោភា, គណៈកម្មការទី១ ព្រឹទ្ធសភា, ទំព័រទី៣

[២៩] ឯកសារស្រាវជ្រាវសង្ខេប, តុប ដារី, គណៈកម្មការទី១នៃព្រឹទ្ធសភា, ទំព័រ៣

[៣០] ឯកសារស្រាវជ្រាវសង្ខេប, តុប ដារី, គណៈកម្មការទី១នៃព្រឹទ្ធសភា, ទំព័រ៣

ដឹងពីជំហររបស់ពួកគេនីមួយៗ និងណែនាំឱ្យភាគីទាំងពីរបានដឹងពីដំណើរការនៃការផ្សះផ្សា។ ជាប្រភពព័ត៌មានដល់ភាគីនីមួយៗ ជាអ្នកសម្របសម្រួល ក្នុងការផ្តល់ឱកាស និងណែនាំឱ្យភាគីបានពិភាក្សាគ្នា។

ក្រៅពីជួយសម្របសម្រួលភាគីនីមួយៗហើយ អ្នកផ្សះផ្សាក៏ត្រូវធ្វើសេចក្តីសន្និដ្ឋាន និងបូកសរុបលើបញ្ហាទាំងឡាយដែលភាគីបានបង្ហាញហើយរៀបចំជាសំណុំឯកសារមួយឱ្យសមស្រប និងមិនធ្វើសេចក្តីសម្រេចណាមួយលើវិវាទទេ ដោយគ្រាន់តែជួយភាគីក្នុងការស្វែងរកដំណោះស្រាយ ដោយមិត្តភាពប៉ុណ្ណោះ។[៣១]

## ១.៥ ការដោះស្រាយវិវាទរដ្ឋបាល

១.៤.១. ការដោះស្រាយតាមនីតិវិធីរដ្ឋបាលក្រៅវិវាទ

"នីតិវិធីរដ្ឋបាលក្រៅវិវាទ" ជាការត្រួតពិនិត្យសេចក្តីសម្រេចអំពើ ឬសកម្មភាពរបស់រដ្ឋបាលដោយរដ្ឋបាលខ្លួនឯង។ ការត្រួតពិនិត្យនេះមានពីរបែប គឺការជួបជាមួយរដ្ឋបាលសាមី (រដ្ឋបាល/អាជ្ញាធរដែលចេញសេចក្តីសម្រេច ឬធ្វើអំពើ) និងការជួបជាមួយរដ្ឋបាល ឬអាជ្ញាធរដែលមានឋានានុក្រមខ្ពស់ជាងរដ្ឋបាលសាមី (ឧទាហរណ៍ រដ្ឋបាលសាមីជាអភិបាលស្រុកនោះរដ្ឋបាលថ្នាក់លើ គឺអភិបាលខេត្តរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬនាយករដ្ឋមន្ត្រីតែម្តង)ដើម្បីបង្ហាញការពិត ឬសុំការសម្របសម្រួល ឬសុំការកែសម្រួលដោយបញ្ជាក់ពីមូលហេតុចាំបាច់នានាដែលអាចជាភស្តុតាងមនោសញ្ចេតនា ឬក្នុងន័យមនុស្សធម៌។ល។

ការប្រើមធ្យោបាយត្រួតពិនិត្យរដ្ឋបាលអាចផ្តល់នូវគុណសម្បត្តិមួយចំនួន ដូចជា មិនចាំបាច់ចំណាយលុយលើមេធាវីមិនបាច់បង់ថ្លៃបណ្តឹងអាចបញ្ជាក់មូលហេតុចាំបាច់ក្នុងន័យមនោសញ្ចេតនា ឬមនុស្សធម៌ដែលមិនតឹងរឹងដូចផ្លូវតុលាការ ហើយមានភាពលឿនរហ័ស។ ប៉ុន្តែមធ្យោបាយនេះថ្នាក់លើអាចសម្រេចមិនចាត់ការ ឬមិនដោះស្រាយ ហើយវាគ្មានបែបបទត្រឹមត្រូវទេ។ ផ្ទុយទៅវិញយន្តការតាមតុលាការ (យុត្តាធិការ) គឺត្រូវតែមានការដោះស្រាយ និងការសម្រេចតាមផ្លូវច្បាប់គ្រាន់តែថាត្រូវចំណាយថវិកា និងប្រើពេលយូរ។ ដូចនេះយើងឃើញថា ការដោះស្រាយវិវាទរដ្ឋបាលតាមផ្លូវរដ្ឋបាល អាចធ្វើឡើងតាមពីររបៀប គឺការដោះស្រាយដោយអាជ្ញាធររដ្ឋបាលសាមី និងការដោះស្រាយដោយអាជ្ញាធររដ្ឋបាលឋានានុក្រម។

១.៤.២. ការដោះស្រាយតាមនីតិវិធីរដ្ឋបាលវិវាទ

ការដោះស្រាយតាមនីតិវិធីនេះមានពីរ គឺនីតិវិធីដោះស្រាយតាមយុត្តាធិការធម្មតា (តាមក្រមរដ្ឋប្បវេណី) និងនីតិវិធីដោះស្រាយតាមយុត្តាធិការពិសេស (ច្បាប់ដោយឡែក)។

---

[៣១] គេហទំព័រ https://uat២.ncdd.gov.kh/storage/app/public/test_library/CAT_១២៧៣_១/២០១២-out-of-Judicial%២0dispute%២0resolution.pdf, ដកស្រង់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

នីតិវិធីដោះស្រាយតាមយុត្តាធិការធម្មតាដូចបានដឹងស្រាប់ហើយថា បច្ចុប្បន្នកម្ពុជាមិនទាន់មានក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាលសម្រាប់ដោះស្រាយរឿងក្តីវិវាទរដ្ឋបាលនៅឡើយទេ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី តុលាការត្រូវតែកាត់ក្តីរឿងវិវាទរដ្ឋបាលដែលគេប្តឹងទៅខ្លួនដើម្បីជៀសវាងការចោទប្រកាន់ពីបទមិនព្រមកាត់ក្តីដែលគេហៅថា "យុត្តិនិសេធ" ដូចនេះក្នុងរឿងក្តីរដ្ឋបាលចៅក្រមមុខតែនឹងខំស្វែងរកវិធានដើម្បីកាត់ក្តីដោយយកគំរូតាមលំនាំដំណើរការរឿងក្តីរដ្ឋប្បវេណី និងតាមគោលការណ៍ច្បាប់ដែលមាននៅក្នុងប្រទេសដែលមានបទពិសោធន៍រឹងប៉ឹងខាងនីតិរដ្ឋបាល។ ម្យ៉ាងទៀតតាមរយៈយុត្តិសាស្ត្ររបស់ខ្លួនចៅក្រមអាចបង្កើតគោលការណ៍ច្បាប់ដែលនឹងមានតម្លៃ រហូតដល់មានច្បាប់ថ្មីមកកែប្រែ។ ដូចនេះសំអាងលើមូលហេតុខាងលើនេះចៅក្រមអាចប្រើប្រាស់ក្រមនីតិ វិធីរដ្ឋប្បវេណីថ្មី (ឆ្នាំ២០០៦) ដើម្បីធ្វើជាមូលដ្ឋាននៃនីតិវិធីសម្រាប់ការដោះស្រាយវិវាទតាមយុត្តាធិការធម្មតា។ សម្រាប់នីតិវិធីដោះស្រាយតាមយុត្តាធិការពិសេស នៅទីនេះគឺលើកតែបីករណីប៉ុណ្ណោះនោះគឺ (១) វិវាទទាក់ទងនឹងការបោះឆ្នោត (២) វិវាទទាក់ទងនឹងពាណិជ្ជកម្ម (៣) វិវាទអគ្គីសនី។

# ជំពូកទី២
# សញ្ញាណទូទៅនៃការដោះស្រាយ
# វិវាទរដ្ឋបាលនៅជប៉ុន

# ជំពូកទី២
# សញ្ញាណទូទៅនៃការដោះស្រាយវិវាទរដ្ឋបាលនៅជប៉ុន

នៅប្រទេសជប៉ុន ក្នុងករណីមានការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់មន្ត្រីរាជការណាម្នាក់ ឬអំពើណាមួយបណ្តាលមកពីការបំពេញកាតព្វកិច្ច នោះអ្នកដែលត្រូវរងការខូចខាតអាចធ្វើការប្តឹងទាមទារសំណងពីរដ្ឋ ឬរដ្ឋបាលតំបន់ដែលគេហៅថា "សំណងរដ្ឋ" នោះតាមរយៈបណ្តឹងរដ្ឋប្បវេណីបាន។ ចំណែកឯការប្តឹងមាន២របៀបគឺ ការប្តឹងមិនពេញចិត្តតាមយុត្តាធិការរដ្ឋបាល និងការដាក់ពាក្យបណ្តឹងតាមយុត្តាធិការតុលាការ។[៣២] ចំណុចនេះវាមានលក្ខណៈស្រដៀងគ្នាទៅនឹងប្រទេសកម្ពុជាដែរ។ ក៏ប៉ុន្តែនៅតែមានលក្ខណៈខុសគ្នាមួយចំនួនដែលយើងខ្ញុំនឹងធ្វើការរៀបរាប់ដូចតទៅនេះ។ នៅប្រទេសជប៉ុន ការប្តឹងមិនពេញចិត្តអំពើរដ្ឋបាល គេមានច្បាប់ទូទៅមួយសម្រាប់អនុវត្ត ដែលគេហៅថា ច្បាប់ស្តីពីការត្រួតពិនិត្យបណ្តឹងរដ្ឋបាល (ដែលជាភាសាជប៉ុនគេហៅថា 行政不服審査法)[៣៣] ដែលនៅក្នុងជំពូកនេះយើងនឹងធ្វើការលើកឡើងអំពីលក្ខណៈនៃវិវាទរដ្ឋបាលនៅប្រទេសជប៉ុនដែលគេមានបែងចែកទៅតាមប្រភេទនៃវិវាទនីមួយៗក៏ដូចជាលក្ខខណ្ឌមួយចំនួនផ្សេងទៀតទាក់ទងទៅនឹងការដាក់ពាក្យបណ្តឹងរដ្ឋបាលតាមរយៈច្បាប់មួយចំនួនដូចជាច្បាប់ស្តីពីនីតិវិធីវិវាទរដ្ឋបាល ច្បាប់ស្តីពីសំណងរដ្ឋ និងច្បាប់ស្តីពីការត្រួតពិនិត្យការមិនពេញចិត្តអំពើរដ្ឋបាលជាដើម។ ក្រៅពីនេះក៏មានច្បាប់ស្តីពីការជម្រុញការអនុវត្តការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(裁判外紛争解決手続きの利用の促進に関する法律)ផងដែរ។ ប៉ុន្តែច្បាប់នេះត្រូវបានគេអនុវត្តតែនៅក្នុងករណីវិវាទរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ចំពោះការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការ គឺមានច្បាប់ដោយឡែកទៅតាមប្រភេទ និងផ្នែកនៃវិវាទ។

## ២.១. និយមន័យ

បើយើងមើលទៅច្បាប់ទូទៅទាំង៣ដែលទាក់ទងនឹងវិវាទរដ្ឋបាល គឺគ្មានការអោយអត្ថន័យណាមួយច្បាស់លាស់ស្តីអំពីពាក្យថាវិវាទរដ្ឋបាលនោះទេ។ ប៉ុន្តែនៅក្នុងច្បាប់ទាំង៣មានបែងចែកយ៉ាងច្បាស់លាស់ពីប្រភេទនៃវិវាទ និងអត្ថន័យរបស់ប្រភេទនីមួយៗ។

---

[៣២] សៀវភៅ នីតិរដ្ឋបាលមូលដ្ឋាន, តូស៊ីយូគី អ៊ីស៊ីកាវ៉ា, ស៊ីហ្ស៊ូអូ ហ្វូជីវ៉ារ៉ា, ហ៊ីរ៉ូយូគី អូវនូគី, ណូរីកុ អ៊ូគូប៊ុ, ហ្គូជិ ស៊ីម៉ូអិ (ជប៉ុន៖ យ៉ឺហ៊ីកាគុ, បោះពុម្ពលើកទី៤, ឆ្នាំ២០១៨), ទំព័រទី១៥៧-១៥៨（石川敏行、藤原静雄、大貫裕之、大久保規子、下井康史『はじめての行政法』（有斐閣、第 4 版、2018 年）157 頁 158 頁）

[៣៣] ច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការដោះស្រាយវិវាទរដ្ឋបាលក្រៅពី ច្បាប់ស្តីពីការត្រួតពិនិត្យបណ្តឹងរដ្ឋបាល (ជាភាសាជប៉ុនហៅថា "行政不服審査法") នោះគឺនៅមាន ច្បាប់ស្តីពីបណ្តឹងវិវាទរដ្ឋបាល (ជាភាសាជប៉ុនហៅថា"行政事件訴訟法") និងច្បាប់នីតិវិធីរដ្ឋបាល(ជាភាសាជប៉ុនហៅថា "行政手続法") ផងដែរ

២.១.១. វិវាទរដ្ឋបាល

នៅក្នុងន័យទូលាយ វិវាទរដ្ឋបាល សំដៅដល់ពេលដែលអំពើរបស់រដ្ឋបាលបង្កអោយមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជន ឬអំពើនោះជាអំពើខុសច្បាប់ នាំអោយប្រជាជនមានការមិនពេញចិត្តហើយដាក់ពាក្យបណ្តឹងទៅតុលាការ។[៣៤] ដែលអត្ថន័យនេះហាក់ដូចជាសអោយឃើញថា វិវាទរដ្ឋបាលអាចធ្វើការដោះស្រាយបានតែនៅយុត្តាធិការតុលាការតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ នៅប្រទេសជប៉ុនក៏មាននីតិវិធីដោះស្រាយតាមយុត្តាធិការរដ្ឋបាលដូចនៅកម្ពុជាយើងដែរ។ ការដោះស្រាយតាមយុត្តាធិការរដ្ឋបាលមានដូចជា ប្រព័ន្ធបណ្តឹងរដ្ឋបាល (行政紛争制度) ដែលគេចែកវាចេញជាពីរគឺ "បណ្តឹងរដ្ឋបាល (行政不服申立て)[៣៥]" និង "បណ្តឹងរឿងក្តីរដ្ឋបាល (行政事件訴訟)"។[៣៦] ប៉ុន្តែ ការស្រាវជ្រាវនេះមិនលើកឡើងអំពីបណ្តឹងរឿងក្តីរដ្ឋបាល (行政事件訴訟) ដែលទាក់ទងនឹងយុត្តាធិការតុលាការឡើយ។ បន្ថែមពី បណ្តឹងរដ្ឋបាល (行政不服申立て) ក៏មានយន្តការដោះស្រាយបណ្តឹងរដ្ឋបាល (行政上の苦情処理) ផងដែរ។

២.១.២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

អត្ថន័យនៃពាក្យថា "ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" គឺចង់សំដៅទៅដល់ប្រព័ន្ធដោះស្រាយវិវាទរដ្ឋប្បវេណីដោយមិនធ្វើតាមយុត្តាធិការតុលាការនោះទេ គឺគ្រាន់តែទទួលបាននូវការធ្វើមជ្ឈត្តកម្ម[៣៧] (仲裁) សន្ធានកម្ម[៣៨] (調停) និងការសម្រុះសម្រួល[៣៩] (あっせん)ជាដើមពីសំណាក់ភាគីទី៣ដោយសុក្រិត។ ប្រសិនបើការដោះស្រាយដំណើរការដោយផ្នែករដ្ឋបាលនោះយើងអាចហៅបានថាជាការដោះស្រាយតាមបែបរដ្ឋបាល (行政型 ADR)។[៤០]

---

[៣៤] គេហទំព័រ ឯកសារសំណួរចម្លើយរបស់តុលាការជប៉ុន https://www.courts.go.jp/vc-files/courts/file2/20911003.pdf, ដកស្រង់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤

[៣៥] បណ្តឹងរដ្ឋបាល ក្នុងន័យនេះគឺចង់សំដៅដល់បណ្តឹងរដ្ឋបាលនៅយុត្តាធិការរដ្ឋបាល

[៣៦] បណ្តឹងរឿងក្តីរដ្ឋបាល ក្នុងន័យនេះគឺសំដៅដល់បណ្តឹងរដ្ឋបាលនៅយុត្តាធិការតុលាការ

[៣៧] 仲裁 ជាភាសាអង់គ្លេស Arbitration ជាភាសាខ្មែរ មជ្ឈត្តកម្ម

[៣៨] 調停 ជាភាសាអង់គ្លេស Conciliation ឬ Mediation ជាភាសាខ្មែរ សន្ធានកម្ម

[៣៩] あっせん ជាភាសាអង់គ្លេស Mediation ជាភាសាខ្មែរ អាចបកប្រែមកថាជា ការសម្រុះសម្រួល ឬការផ្សះផ្សា(បើនៅក្នុងប្រព័ន្ធខ្មែរយើង) និងមានឯកសារខ្លះ មានពាក្យថា Wakai（和解）ដែលមានន័យថា ការចរចា ដែលយើងនឹងធ្វើការរៀបរាប់នៅអត្ថបទ

[៤០] សៀវភៅ នីតិរដ្ឋបាលជាក់ស្តែង, កាស្សឹយ៉ា អ៊ីឈិហាស៊ី, ហ៊ីដេណូរី សាកាគីបារ៉ា, តាគី ហុងដា, កាហ៊្សុស្សុ អ៊ីណាបា, គេនហ្គូ យ៉ាម៉ាដា, កាហ៊្សូអ៊ីឈី ហ៊ីរ៉ាតា, (ជប៉ុន៖ក្រុមហ៊ុនវប្បធម៌ច្បាប់, បោះពុម្ពលើកទី៣, ឆ្នាំ២០២៣), ទំព័រទី២០៨（市橋克哉、榊原秀訓、本多滝夫、稲葉一将、山田健吾、平田和一『アクチュアル行政法』(法律文化社、第 3 版、2023 年)、208 頁 ）

## ២.២. ប្រភេទនៃបណ្តឹងរដ្ឋបាល

ប្រភេទនៃបណ្តឹងរដ្ឋបាល (不服申立て) មានបីប្រភេទបើតាមច្បាប់ស្តីពីការត្រួតពិនិត្យការមិនពេញចិត្តអំពើរដ្ឋបាលគឺ ការទាមទារត្រួតពិនិត្យ (審査請求) ការទាមទារស្រាវជ្រាវឡើងវិញ (再調査の請求) និងការទាមទារត្រួតពិនិត្យឡើងវិញ(再審査請求)។ នៅក្នុងចំណោមការទាមទារទាំងបីនេះ ការទាមទារត្រួតពិនិត្យត្រូវបានគេយកមកអនុវត្តជាមូលដ្ឋាន។ ការទាមទារស្រាវជ្រាវឡើងវិញ និងការទាមទារត្រួតពិនិត្យឡើងវិញអាចអនុវត្តបានតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់ដោយឡែកតែប៉ុណ្ណោះ។

២.២.១. បណ្តឹងការទាមទារត្រួតពិនិត្យ（審査請求）

ការទាមទារត្រួតពិនិត្យ សំដៅដល់ការប្តឹងមិនពេញចិត្ត (不服申立て) ទៅកាន់ស្ថាប័នត្រួតពិនិត្យអំពីអំពើស្ថាប័នរដ្ឋបាល[៤១] (行政庁の処分) និងការមិនអនុវត្តកាតព្វកិច្ចរដ្ឋបាល (不作為)។

២.២.២. បណ្តឹងការទាមទារស្រាវជ្រាវឡើងវិញ (再調査の請求)

ការទាមទារស្រាវជ្រាវឡើងវិញ សំដៅដល់នីតិវិធីកែតម្រូវអំពើរដ្ឋបាល (処分) ដើម្បីអោយស្ថាប័នត្រួតពិនិត្យអំពើរដ្ឋបាល (処分庁) ខ្លួនឯងផ្ទាល់អាចធ្វើការស្រាវជ្រាវទំនាក់ទំនងការពិតអោយកាន់តែមានភាពរលូន។

២.២.៣. បណ្តឹងការទាមទារត្រួតពិនិត្យឡើងវិញ (再審査請求)

ការទាមទារត្រួតពិនិត្យឡើងវិញ សំដៅដល់នីតិវិធីនៃការប្តឹងមួយដំណាក់កាលទៀត ចំពោះសេចក្តីសម្រេចរបស់ការទាមទារត្រួតពិនិត្យ ដោយសារមានការមិនពេញចិត្តចំពោះសេចក្តីសម្រេចនោះ។ ម៉្យាងទៀតអាចធ្វើទៅបានតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់ដោយឡែកតែប៉ុណ្ណោះ។ បើក្នុងករណីដែលមានច្បាប់ដោយឡែកដែលមានចែងអំពីការទាមទារស្រាវជ្រាវឡើងវិញ នោះប្រជាជនមានសិទ្ធនៅក្នុងការសម្រេចថាតើធ្វើការទាមទារត្រួតពិនិត្យ ឬក៏ធ្វើការទាមទារស្រាវជ្រាវឡើងវិញ។

---

[៤១] 行政庁の処分 ភាសាអង់គ្លេសសំដៅដល់ Administrative act ភាសាខ្មែរសំដៅដល់ អំពើរដ្ឋបាល ដែលភាសាជប៉ុនពាក្យ 行政庁 មានន័យថាស្ថាប័នរដ្ឋបាល និងពាក្យ 処分 ក្នុងរដ្ឋបាលសាធារណៈសំដៅដល់ផ្នែកមួយនៅក្នុងសកម្មភាពរដ្ឋបាលដែលគេហៅជាភាសាជប៉ុនថា 行政行為

ម៉្យាងទៀត នៅពេលដែលធ្វើការទាមទារស្រាវជ្រាវឡើងវិញរួច ជាគោលការណ៍លុះត្រាតែសេចក្តីសម្រេច (決定) នៃការទាមទារស្រាវជ្រាវឡើងវិញនោះបានដាក់ចេញមករួចហើយ ទើបអាចធ្វើការទាមទារត្រួតពិនិត្យបាន។[៤២]

២.២.៤. បណ្តឹងត្អូញត្អែរ(苦情)

បន្ថែមពីប្រភេទនៃបណ្តឹង៣ខាងលើនេះក៏មាននូវយន្តការដោះស្រាយបណ្តឹងរដ្ឋបាល (行政上の苦情処理(អាចហៅថាជាយន្តការដោះស្រាយបណ្តឹងត្អូញត្អែរ)) ដែលវាមានលក្ខណៈស្រដៀងទៅនឹងយន្តការដោះស្រាយបណ្តឹងនៅច្រកចេញចូលតែមួយនៅការិយាល័យប្រជាពលរដ្ឋរបស់កម្ពុជាយើងផងដែរ។ យន្តការដោះស្រាយបណ្តឹងរដ្ឋបាលនេះសំដៅដល់ស្ថាប័នរដ្ឋបាលដែលបង្កើតឡើងដើម្បីទទួល និងធ្វើការដោះស្រាយបណ្តឹងរដ្ឋបាលនានា។ ឧទាហរណ៍ រាល់បណ្តឹងទាំងឡាយដែលពាក់ព័ន្ធនឹងភាពអយុត្តិធម៌ពីសំណាក់ស្ថាប័នរដ្ឋបាល ឬអាជ្ញាធររដ្ឋបាល ការមិនពេញចិត្តទៅកាន់ស្ថាប័នរដ្ឋបាលនិងការទាមទារអោយស្ថាប័នរដ្ឋបាលបំពេញនូវកាតព្វកិច្ចណាមួយជាដើម។[៤៣]

## ២.៣. ស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយ

២.៣.១. ស្ថាប័នថ្នាក់ជាតិ

ចំពោះយន្តការដោះស្រាយបណ្តឹងរដ្ឋបាល ក្នុងករណីដែលមានបណ្តឹងមិនពេញចិត្តទៅកាន់ស្ថាប័នណាមួយនោះថ្នាក់ដឹកនាំ ឬអ្នកទទួលខុសត្រូវក្នុងស្ថាប័នសមីនោះត្រូវដោះស្រាយដោយស្របទៅតាមស្ថានភាពជាក់ស្តែងនៃបណ្តឹងនោះដោយពុំចាំបាច់ឆ្លងកាត់នីតិវិធីច្បាប់នោះទេ។ ប្រសិនបើមានពីពាក្យបណ្តឹងសំណាក់ប្រជាពលរដ្ឋទៅកាន់ក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុង ឬអង្គភាព ឬក៏មានវិវាទកើតឡើងនៅក្នុងក្រសួង ឬអង្គភាពនោះ គឺអ្នកទទួលខុសត្រូវនៅក្នុងការិយាល័យរដ្ឋបាលផ្ទាល់នៃស្ថាប័ននោះត្រូវដោះស្រាយទៅតាមស្ថានភាពជាក់ស្តែងនៃវិវាទនោះ។ ចំណុចនេះក៏វាពុំសូវមានភាពខុសគ្នាអ្វីពីប្រទេសកម្ពុជាដែរ។ ឧទាហរណ៍ថាប្រសិនបើមានវិវាទរដ្ឋបាលកើតឡើងនៅក្នុងវិសាលភាពនៃក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុងនោះគឺអ្នកដែលទទួលខុសត្រូវលើការដោះស្រាយនោះគឺ នាយកដ្ឋានវាយតម្លៃរដ្ឋបាល (行政評価局) នៃក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុងនោះ ដោយនាយកដ្ឋាននេះមានភារកិច្ចអនុវត្តការធ្វើសន្ទានកម្មតាមការចាំបាច់ដើម្បីដោះស្រាយបណ្តឹងដែលទទួលបានពីសំណាក់ពលរដ្ឋ។ នាយកដ្ឋានវាយតម្លៃរដ្ឋបាលនៃក្រសួងទំនាក់ទំនង និងកិច្ច

[៤២] សៀវភៅ នីតិរដ្ឋបាល, គេយកុ សាគុយ៉ី, ហ៊ីរ៉ូយូគី ហាស៊ីម៉ូតុ (ជប៉ុន៖ កូប៊ុនដូ, បោះពុម្ពលើកទី៦, ឆ្នាំ២០១៩), ទំព័រទី២៣១ (惠子桜井、博之橋本『行政法』(弘文堂、第 6 版、2019 年) 231 頁 )

[៤៣] សៀវភៅ កាស៊ូយ៉ា អ៊ីឈិហាស៊ី, ទំព័រទី២០៧ (市橋克哉、前掲書 207 頁)

ការផ្ទៃក្នុងនេះមិនត្រឹមតែដោះស្រាយបណ្តឹងដែលនៅក្នុងដែនវិសាលភាពរបស់ក្រសួងតែមួយនោះទេ គឺមានសមត្ថកិច្ចទទួលយករាល់នូវមតិរិះគន់ គំនិត ក៏ដូចជាការទាមទាររបស់ប្រជាពលរដ្ឋ និងជំរុញការអនុវត្ត និងដោះស្រាយរាល់បណ្តឹងទៅកាន់ស្ថាប័នរដ្ឋបាលរបស់រដ្ឋទាំងមូលផងដែរ។ ក្រសួងនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជាយើងដែរ ដោយគ្រាន់តែពុំមានវត្តមាននៃកងកម្លាំងប្រដាប់អាវុធ ប៉ូលីសដូចនៅកម្ពុជានោះទេ។ ម្យ៉ាងទៀត នៅប្រទេសជប៉ុនមានភាពតឹងរឹងទាក់ទងទៅនឹងការរក្សាឯកជនភាពបុគ្គល នោះបណ្តឹងដែលទាក់ទងទៅនឹងឯកជនភាពបុគ្គល គឺតម្រូវអោយថ្នាក់ដឹកនាំស្ថាប័នរដ្ឋបាលផ្ទាល់ដោះស្រាយដោយមានគណនេយ្យភាព និងភាពឆាប់រហ័សព្រមទាំងស្របទៅតាមច្បាប់ផងដែរ។[៤៤]

២.៣.២. ស្ថាប័នថ្នាក់ក្រោមជាតិ

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា (ombudsman) ដែលមានប្រភពដើមមកពីភាសាស៊ុយអែត មានន័យថាជាអ្នកតំណាង។ ភ្នាក់ងារនេះមានមុខងារចម្បង២នៅក្នុងរដ្ឋបាល គឺមុខងារសង្គ្រោះបណ្តឹង (គូញ្ញោ) (苦情救済機能) និងមុខងារអង្កេតរដ្ឋបាល (行政監察機能)។ ភ្នាក់ងារនេះចែកជាពីរទម្រង់ គឺទម្រង់នៃការបង្កើត និងតែងតាំងដោយសភា និងទម្រង់នៃការបង្កើតដោយរាជរដ្ឋាភិបាល ដែលមានបែងចែកវិសាលភាពនៃអំណាចច្បាស់លាស់ជាពីរថ្នាក់ គឺភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាទូទៅ (行政全般を管轄) និងភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាពិសេស (特定の行政領域を管轄[៤៥])។[៤៦] ភ្នាក់ងារនេះចែកចេញជាពីរ គឺភ្នាក់ងារដែលបង្កើតដោយរដ្ឋ ហៅថាភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាសាធារណៈ និងភ្នាក់ងារដែលបង្កើតដោយឯកជន (公的オンブズマン) ហៅថាភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាឯកជន (私的オンブズマン)។ គេបែងចែកភ្នាក់ងារដែលបង្កើតដោយរដ្ឋជាពីរថ្នាក់ទៀត គឺភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាថ្នាក់ជាតិ (国政オンブズマン) និងភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាថ្នាក់ក្រោមជាតិ (地方オンブズマン)។[៤៧]

---

[៤៤] សៀវភៅ កាស្សឹយ៉ា អ៊ីឈិហាស៊ី, ទំព័រទី២០៧

[៤៥] ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាពិសេសនេះមានដូចជា ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាប៉ូលីស ភ្នាក់ស៊ើបអង្កេតបណ្តឹងតវ៉ាអគ្គីភ័យជាដើម

[៤៦] សៀវភៅ កាស្សឹយ៉ា អ៊ីឈិហាស៊ី, ទំព័រទី២០៨, ២០៩ （市橋克哉、前掲書 208 頁 、209 頁）

[៤៧] សៀវភៅ ប្រព័ន្ធភ្នាក់ងារស៊ើបអង្កេត, ហាយ៉ាស៊ីយ៉ា រេអ៊ីជិ, (ជប៉ុន៖ អ៊ីវ៉ាណាមីស្សូទែន, ឆ្នាំ២០០២), ទំព័រទី៧（林屋礼二『オンブズマン制度』（岩波書店 2002 年）7 頁）, ឯកសារមូលដ្ឋាន គណៈកម្មការការពារសិទ្ធមនុស្សនិងទីស្នាក់ការកណ្តាលស្ថាប័នតុលាការ/ប្រព័ន្ធភ្នាក់ងារស៊ើបអង្កេតបណ្តឹង, លេខាធិការដ្ឋានគណៈកម្មាធិការស្រាវជ្រាវរដ្ឋធម្មនុញ្ញនៃរដ្ឋសភា, (ជប៉ុន៖ ឯកសារលេខ៤, ឆ្នាំ២០០៤)(［衆議院憲法調査会事務局、「人権擁護委員会その他の準司法機関・ オンブズマン制度」に関する 基礎的資料」、2004 年 3 月、衆憲資第 42 号］)

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងនេះជាស្ថាប័នឯករាជ្យ មានតួនាទីក្នុងការខ្លមមើលរាល់អំពើដែលខុសច្បាប់របស់រាជរដ្ឋាភិបាល ឬស្ថាប័នរដ្ឋបាលក្នុងគោលដៅការពារផលប្រយោជន៍ ក៏ដូចជាការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងស្រាវជ្រាវថាតើមានការបំពានពិតប្រាកដដែរឬទេ។ ក្នុងករណីដែលមានការបំពាន ឬប៉ះពាល់ដល់ផលប្រយោជន៍ និងសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនោះភ្នាក់ងារនេះមានតួនាទីផ្តល់ជាដំណោះស្រាយណាមួយដល់ស្ថាប័នរដ្ឋបាលនោះ និងធ្វើការសម្របសម្រួលអោយបានឆាប់រហ័ស ទាន់ពេលវេលា និងផ្តល់នូវការដោះស្រាយងាយស្រួលដើម្បីការពារប្រជាពលរដ្ឋពីការបំពានទាំងនោះ។[៤៨]

ភ្នាក់ងារនេះគឺមានលក្ខណៈដូចគ្នាទៅនឹង ការិយាល័យប្រជាពលរដ្ឋ នៅប្រទេសកម្ពុជាយើងដែលមានតួនាទីក្នុងការទទួល និងដោះស្រាយរាល់បណ្តឹងទាក់ទងនឹងវិវាទរដ្ឋបាលដែលរួមមានការមិនពេញចិត្តនូវសេវាសាធារណៈពីអាជ្ញាធររដ្ឋបាលជាដើមនោះជូនប្រជាពលរដ្ឋអោយបានទាន់ពេលវេលាក្នុងគោលដៅការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងរក្សានូវតម្លាភាពក៏ដូចជានីតិរដ្ឋនៃប្រទេស។

ម៉្យាងទៀតនៅប្រទេសជប៉ុនក៏មាននូវគណៈកម្មការពិភាក្សាផ្នែករដ្ឋបាល(行政相談委員) នៅទូទាំងប្រទេស យ៉ាងហោចណាស់មានម្នាក់នៅតាមគ្រប់ក្រុង ស្រុក ភូមិ។ គណៈកម្មការនេះមានតួនាទី ផ្តល់យោបល់ពិភាក្សាជាមួយនឹងប្រជាពលរដ្ឋដែលមានការមិនពេញចិត្តទៅលើសកម្មភាព ឬអំពើរដ្ឋរបស់រដ្ឋបាលផ្តល់ជាការលួងលោម លើកទឹកចិត្តដល់អ្នកដែលបានមកដាក់ពាក្យបណ្តឹង ជាដើម។[៤៩]

## ២.៤. ទម្រង់នៃការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសជប៉ុនមាន"ច្បាប់ស្តីពីការជម្រុញការអនុវត្តការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (裁判外紛争解決手続きの利用の促進に関する法律) មួយសម្រាប់អនុវត្ត។ ក៏ប៉ុន្តែ ច្បាប់នេះមិនត្រូវយកមកអនុវត្តទេចំពោះការដោះស្រាយតាមបែបរដ្ឋបាលដែលវាមាន

---

[៤៨] ឯកសារមូលដ្ឋាន ស្តីអំពីគណៈកម្មការការពារសិទ្ធមនុស្សចំណុះស្ថាប័នតុលាការ/ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា, គេហទំព័រ, https://www.shugiin.go.jp/internet/itdb_kenpou.nsf/html/kenpou/chosa/shukenshi042.pdf/$File/shukenshi042.pdf, ដកស្រង់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៤

[៤៩] គេហទំព័រ https://www.gender.go.jp/kaigi/senmon/kujou/siryo/pdf/ku07-1.pdf, ដកស្រង់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤, ឯកសារ ស្តីពីប្រព័ន្ធពិភាក្សាផ្នែករដ្ឋបាល, នាយកដ្ឋានវាយតម្លៃរដ្ឋបាលនៃក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុង (ជប៉ុន៖ ឆ្នាំ២០០១) ទំព័រទី១, （総務省行政評価局「行政相談制度」1 頁（2001 年 10 月））

គេហទំព័រhttps://www.gender.go.jp/kaigi/senmon/kujou/houkoku/pdf/hku01s-8.pdf, ដកស្រង់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤, ឯកសារ ស្តីពីប្រព័ន្ធពិភាក្សារដ្ឋបាលនៃក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុង, ក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុង, ទំព័រទី១ （総務省、「総務省の行政相談制度について」1 頁）

ច្បាប់ដោយឡែកសម្រាប់អនុវត្ត។[៥០]ស្ថាប័នដោះស្រាយតាមបែបរដ្ឋបាលមានដូចជា គណៈកម្មាធិការរៀបចំដោះស្រាយការបំពុលបរិស្ថាន គណៈកម្មាធិការកណ្តាលផ្នែកការងារ និងគណៈកម្មការកណ្តាលផ្នែកការដ្ឋាននិងការសាងសង់ជាដើម។ ឧទាហរណ៍ គណៈកម្មាធិការកណ្តាល មានតួនាទី និងភារកិច្ចដោះស្រាយលើវិវាទទាក់ទងទៅនឹងការបំពុលបរិស្ថានដោយយោងទៅតាម"ច្បាប់ស្តីពីការដោះស្រាយវិវាទស្តីពីការបំពុលបរិស្ថាន (公害紛争処理法)។

ចំពោះបណ្តឹងរដ្ឋបាល (行政不服申立て) មានលក្ខណៈផ្ទុយគ្នាពីបណ្តឹងរឿងក្តីរដ្ឋបាល (行政事件訴訟) ដែលស្ថិតនៅដែនសមត្ថកិច្ចរបស់ស្ថាប័នតុលាការ និងខុសពីយន្តការដោះស្រាយបណ្តឹងរដ្ឋបាល (行政上の苦情処理)ដែលគ្រាន់តែដោះស្រាយត្រួតពិនិត្យ និងខ្លួមមើលរដ្ឋបាលដោយពុំយោងទៅតាមគោលការណ៍ច្បាប់។[៥១]ទាក់ទងទៅនឹងបណ្តឹងរដ្ឋបាលជប៉ុនមាននូវច្បាប់ទូទៅមួយសម្រាប់ដោះស្រាយ គឺ "ច្បាប់ស្តីពីការត្រួតពិនិត្យការមិនពេញចិត្តអំពើរដ្ឋបាល"។[៥២] ច្បាប់នេះ ត្រូវបានគេធ្វើវិសោធនកម្មលើកចុងក្រោយនៅឆ្នាំ២០១៤ ក្នុងគោលបំណងលើកកម្ពស់នីតិវិធីអនុវត្តអោយបានត្រឹមត្រូវតាមច្បាប់ និងសម្រួលអោយប្រជាជនកាន់តែងាយយល់ពីប្រព័ន្ធនេះ។[៥៣]

ការដោះស្រាយតាមយុត្តាធិការរដ្ឋបាលមានអត្ថប្រយោជន៍មួយចំនួនដូចជា៖

- ការសិទ្ធិរបស់ប្រជាជនមានភាពងាយស្រួល និងឆាប់រហ័ស
- រក្សាបាននូវការដោះស្រាយស្ថិតក្រោមដែនសមត្ថកិច្ចរបស់រដ្ឋបាល
- មិនត្រឹមតែត្រួតពិនិត្យលើភាពត្រឹមត្រូវ (ស្របច្បាប់ឬផ្ទុយច្បាប់) នៃការអនុវត្តច្បាប់នោះទេ គឺអាចត្រួតពិនិត្យដល់ភាពត្រឹមត្រូវ (សមស្របឬមិនសមស្រប)នៃគោលបំណងរួមដើម្បីផលប្រយោជន៍សាធារណៈដែលស្ថិតនៅក្នុងវិសាលភាពនៃអំណាចឆន្ទានុសិទ្ធិរបស់រដ្ឋបាលបានដែរ
- ប្រសិនបើក្នុងករណីវិវាទដែលមានកំណត់ជាក់លាក់ (定型的紛争) នោះអាចដោះស្រាយត្រឹមយុត្តាធិការរដ្ឋបាលបានជួយកាត់បន្ថយបន្ទុកស្ថាប័នតុលាការបានមួយកម្រិតជាដើម។[៥៤]

---

[៥០] សៀវភៅ, កាស៊ីយ៉ា អ៊ីឈិហាស៊ី, ទំព័រទី២០៨（市橋克哉、前掲書 208 頁）

[៥១] សៀវភៅ នីតិរដ្ឋបាល, គេយកុ សាគុរ៉ៃ, ហ៊ីរ៉ូយូគី ហាស៊ីម៉ូតុ (ជប៉ុន៖ កូប៊ុនដូ, បោះពុម្ពលើកទី៦, ២០១៩), ទំព័រទី២២៩（恵子桜井、博之橋本『行政法』(弘文堂、第 6 版、2019 年）229 頁 ）

[៥២] សៀវភៅ, តូស៊ីយូគី, ទំព័រទី១៣៦（石川敏行、前掲書 136 項）

[៥៣] សៀវភៅ, សាគូរ៉ៃ, ទំព័រទី២៣០（恵子桜井、前掲書 230 頁）

[៥៤] សៀវភៅ, សាគូរ៉ៃ, ទំព័រទី២២៩（同上 229 頁）

ចំពោះយន្តការដោះស្រាយបណ្តឹងរដ្ឋបាល (行政上の苦情処理)[៥៥] ការដោះស្រាយគឺស្របទៅតាមស្ថានភាពជាក់ស្តែងនៃបណ្តឹងនោះដោយពុំចាំបាច់ឆ្លងកាត់នីតិវិធីច្បាប់នោះទេ។

អត្ថប្រយោជន៍នៃយន្តការនេះគឺមានលក្ខណៈពិសេសត្រង់៖

- ការអាចដោះស្រាយដោយពុំចាំបាច់យកគោលការណ៍ច្បាប់ដែលមានភាពស្មុគស្មាញ
- ចំណេញពេលវេលា មានភាពត្រឹមត្រូវ និងឆាប់រហ័ស
- មិនតម្រូវអោយចំណាយថវិការនោះឡើយ។ល។[៥៦]

ទោះបីជាយ៉ាងនេះក្តីយើងខ្ញុំសូមចោទជាសំណួរថា ប្រសិនបើអំពើរដ្ឋបាល អនុវត្តដោយរដ្ឋបាល និងដោះស្រាយដោយរដ្ឋបាល តើអាចនឹងមានលក្ខណៈលំអៀងក្នុងការដោះស្រាយដែរឬទេ។ សំណួរនេះចោទសួរឡើងដោយគ្មានបំណងអ្វីក្រៅពីការចង់ដឹងបន្ថែមក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវនោះឡើយ ដោយហេតុថាយើងខ្ញុំពុំអាចរកចម្លើយណាមួយបានទាក់ទងនឹងសំណួរមួយនេះបាន។ ម៉្យាងទៀត មិនមែនតែក្នុងករណីប្រទេសជប៉ុននោះទេ តែនៅប្រទេសកម្ពុជាក៏ស្រដៀងគ្នាដែរ ហេតុនេះចម្ងល់មួយនេះអាចនឹងក្លាយទៅជាប្រធានបទដែលអាចអោយអ្នកសិក្សាជំនាន់ក្រោយយកមកពិភាក្សា ក៏ដូចជាសិក្សាបន្ថែមទៀត ដើម្បីអាចរក្សានូវភាពជានីតិរដ្ឋនៃប្រទេសមួយបានមួយកម្រិតបន្ថែមទៀតផងដែរ។

ចំណែកឯទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនោះគឺមានលក្ខណៈស្រដៀងគ្នាទៅនឹងប្រទេសកម្ពុជាដែរគ្រាន់តែមានចំណុចខុសគ្នាមួយចំនួនដែលនឹងមានរៀបរាប់ដូចតទៅ៖

### ២.៤.១. ការចរចា (和解 Compromise)

ការចរចា គឺជាការដោះស្រាយដោយមានការព្រមព្រៀងរវាងគូភាគីក្នុងគោលដៅស្វែងរកដំណោះស្រាយដែលល្អមួយ។ ការដោះស្រាយនេះគឺត្រូវធ្វើឡើងដោយមានការណែនាំពីចៅក្រម និងធ្វើឡើងនៅតុលាការ។[៥៧] បន្ថែមពីនេះទៅទៀតទោះបីជា ត្រូវធ្វើការដោះស្រាយដោយមានការណែនាំពីតុលាការ និងធ្វើសាលក្រមនៅតុលាការក៏ដោយ ការចរចានេះអាចធ្វើឡើងដោយយោងតាម ឬមិនយោងទៅតាមនីតិវិធីច្បាប់ក៏បាន។ ត្រង់ចំណុចនេះយើងសង្កេតឃើញថាវាមានលក្ខណៈបត់បែនពិសេសខុសប្លែកខ្លាំងពី ការចរចា (ភាសាអង់គ្លេស៖ Negotiation) នៅកម្ពុជាយើង។

---

[៥៥] ពាក្យ 苦情 ជាភាសាអង់គ្លេស Complaint ភាសាខ្មែរមានន័យថា ការត្អូញត្អែរ ដែលយើងខ្ញុំសូមសន្និដ្ឋានថាស្មើរនឹង ការមិនពេញចិត្ត ការដាក់ពាក្យបណ្តឹង

[៥៦] សៀវភៅ, កាស៊ឺយ៉ា អ៊ីឈិហាស៊ី, ទំព័រទី២០៧ （市橋克哉、前掲書 207 頁）

[៥៧] គេហទំព័រ file:///C:/Users/TRC/Downloads/ssrn-458001.pdf, ដកស្រង់ថ្ងៃ២៣ ខែមេសា ឆ្នាំ២០២៤ (Katja Funken, "Alternative Dispute Resolution in Japan")

២.៤.២. ការផ្សះផ្សា (あっせん Conciliation)

ការផ្សះផ្សា សំដៅដល់ប្រព័ន្ធដោះស្រាយមួយដែលអោយគូភាគីដែលមានជម្លោះអាចមានឱកាសចរចាគ្នាដោយមានភាគីទី៣ចូលរួមធ្វើការសាកសួរ និងស្តាប់នូវការលើកឡើង និងបញ្ជាក់ពីតម្រូវការរបស់ភាគីម្ខាងៗ រួចធ្វើការដោះស្រាយនូវការយល់ច្រឡំនោះ និងធ្វើការណែនាំបញ្ចប់ជម្លោះនោះ។ ការផ្សះផ្សា គឺមានគោលដៅក្នុងការដោះស្រាយដោយវិធីចរចាដូចជាសន្ទានកម្មដែរត្រង់ចំណុចចូលរួមជួយជម្រុញការដោះស្រាយរវាងភាគីទាំងសងខាង។ ក៏ប៉ុន្តែដោយសារតែ ការផ្សះផ្សាពុំតម្រូវអោយមានការធ្វើទៅតាមនីតិវិធីច្បាប់ ឬមួយក៏នីតិវិធីបែបបច្ចេកទេសប៉ុន្មាននោះទេ ហេតុនេះហើយក៏ពុំចាំបាច់តម្រូវអោយដាក់ចេញនូវលិខិតស្តីពីការចរចា (あっせん案) ដល់ភាគីនោះទេ។[៥៤]

២.៤.៣. សន្ទានកម្ម(調停 Mediation)

សន្ទានកម្ម សំដៅដល់ប្រព័ន្ធដោះស្រាយមួយដែលអោយគូភាគីដែលមានជម្លោះអាចមានឱកាសធ្វើការចរចាគ្នា និងមានការចូលរួមសហការដោះស្រាយជម្លោះនោះ។ ក្នុងករណីខ្លះនឹងមានការដាក់ចេញនូវលិខិតស្តីពីសន្ទានកម្ម (調停案) រួចត្រូវធ្វើការដោះស្រាយដោយយោងទៅតាមសេចក្តីណែនាំនៅក្នុងលិខិតនោះ។

សន្ទានកម្ម មានលក្ខណៈពិសេសខុសប្លែកពីការផ្សះផ្សាត្រង់ចំណុចដែលមានត្រឹមតែធ្វើការជួយជម្រុញការដោះស្រាយរវាងគូភាគីប៉ុណ្ណោះទេ តែក៏អាចធ្វើការដាក់ចេញនូវលិខិតស្តីពីសន្ទានកម្មផងដែរ។ បន្ថែមពីនេះ មានលក្ខណៈខុសគ្នាមួយទៀតគឺ ចំនួនគណៈកម្មការចូលរួមដោះស្រាយ (担当委員)។

ចំពោះការផ្សះផ្សា មានគណៈកម្មការផ្នែកច្បាប់ ឬផ្នែកបច្ចេកទេសតែម្នាក់គត់ទទួលខុសត្រូវក្នុងការចូលរួមផ្សះផ្សា។ ផ្ទុយមកវិញ ចំពោះសន្ទានកម្ម មានគណៈកម្មការសរុបចំនួនបីនាក់ រួមមានគណៈកម្មការផ្នែកច្បាប់មួយរូប និងផ្នែកបច្ចេកទេសពីររូប ឬមួយក៏គណៈកម្មការផ្នែកច្បាប់មួយរូប ផ្នែកបច្ចេកទេសមួយរូប និងផ្នែកទូទៅមួយរូប។[៥៥]

២.៤.៤. មជ្ឈត្តកម្ម(仲裁 Arbitration)

មជ្ឈត្តកម្ម មិនត្រឹមតែជាការដោះស្រាយបានដោយការចរចានោះទេ គឺជាប្រព័ន្ធមួយដែលតម្រូវអោយជនទី៣ដែលចូលរួមដោះស្រាយនោះធ្វើការដាក់ចេញនូវសេចក្តីសម្រេចស្តីពីមជ្ឈត្តកម្ម (仲裁判断) ជំនួស

---

[៥៤] ក្រសួងដែនដី និងដឹកជញ្ជូន, ភាពខុសគ្នារវាងការផ្សះផ្សា សន្ទានកម្ម និងមជ្ឈត្តកម្ម(លម្អិត), ទំព័រទី១ (国土交通省、「あっせん、調停及び仲裁の違い（詳細）」, គេហទំព័រ https://www.mlit.go.jp/common/000005438.pdf, ដកស្រង់ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤

[៥៥] គេហទំព័រ https://www.mlit.go.jp/common/000005438.pdf, ទំព័រទី១, ដកស្រង់ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤

អោយសាលដីការបស់តុលាការ។[៦០] សរុបមកវិញគឺ សេចក្តីសម្រេចស្តីពីមជ្ឈត្តកម្មដែលចេញដោយមជ្ឈត្តករ មានអានុភាពដូចគ្នាទៅនឹងសាលដីការរបស់តុលាការ។[៦១]

[៦០] គេហទំព័រ https://www.mlit.go.jp/common/000005438.pdf, ដកស្រង់ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤, ទំព័រទី២

[៦១] គេហទំព័រ នាយកដ្ឋានប៉ាតង់(ជប៉ុន) https://www.jpo.go.jp/support/ipr/kyusai/funsokaiketsu.html, ដកស្រង់ថ្ងៃ៦ ខែឧសភា ឆ្នាំ២០២៤

# ជំពូកទី៣
# ដំណើរការនៃការដោះស្រាយ
# វិវាទរដ្ឋបាល

# ជំពូកទី៣
# ដំណើរការនៃការដោះស្រាយវិវាទរដ្ឋបាល

## ៣.១. ករណីប្រទេសកម្ពុជា

៣.១.១. ដំណើរការចរចា

ដំណើរការចរចាមិនមានប្រើវិធានច្បាប់ ឬលក្ខន្តិកៈណាមួយអោយជាក់លាក់ច្បាស់លាស់សម្រាប់ណែនាំអំពីដំណើរការនេះឡើយ។ ប៉ុន្តែ គេអាចស្វែងយល់បានកាន់តែប្រសើរតាមរយៈដំណាក់កាលចំនួនប្រាំដូចជា៖

❖ **ដំណាក់កាលត្រៀម**

ក្នុងដំណាក់កាលនេះភាគី និងមេធាវីត្រូវពិនិត្យរឿងក្តីមួយចំនួន ព្រមទាំងធ្វើការសន្និដ្ឋានមុននឹងចាប់ផ្តើមចរចា។ ដំបូង គឺមេធាវីត្រូវធ្វើការស្រាវជ្រាវ និងពិនិត្យមើលអង្គហេតុទាំងអស់ ឬឯកសារដែលពាក់ព័ន្ធនឹងភស្តុតាង ដូចជាកិច្ចសន្យាការជួបសម្ភាសន៍ជាមួយមនុស្សដែលពាក់ព័ន្ធនឹងរឿងហេតុ ហើយនឹងព្យាយាមយល់ពីអង្គហេតុ។ បន្ទាប់មក ធ្វើការវិភាគច្បាប់ និងព្យាយាមបង្កើតអំណះអំណាងផ្លូវច្បាប់ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ បន្ទាប់មកទៀត មេធាវីត្រូវធ្វើការសួរសំណួរជាមូលដ្ឋានបន្ថែមទៀតដូចជា អាជីវកម្ម សម្ព័ន្ធភាព ការភ័យព្រួយ បំណងប្រាថ្នា និងគោលដៅ ដើម្បីស្វែងយល់ពីផលប្រយោជន៍ និងគោលដៅរបស់កូនក្តីដូចជា សុវត្ថិភាពរាងកាយ ការរក្សាកេរ្តិ៍ ការបន្តការងារ ការសង្គ្រោះមុខមាត់ ការសរបញ្ជាក់ឱ្យឃើញថាកូនក្តីរបស់ខ្លួនជាអ្នកត្រូវជាដើម។

❖ **ដំណាក់កាលចាប់ផ្តើម**

ដំណាក់កាលនេះ មេធាវីត្រូវធ្វើការទំនាក់ទំនងគ្នាទៅវិញទៅមក ដើម្បីពិភាក្សាអំពីបែបបទចរចា ដូចជា "គួរឬទេ" ក្នុងន័យនេះគឺ "តើគួរមានការចរចាដែលឬទេ?" និងតើការចរចានេះត្រូវធ្វើឡើងនៅពេលណា គឺជាការកំណត់ពេលវេលាជាក់លាក់មួយ ប្រសិនបើភាគីម្ខាងយល់ថាការចរចាត្រូវធ្វើឡើងជាបន្ទាន់ ដើម្បីឱ្យភាគីម្ខាងត្រូវប្រឈមមុខការបើកចំហរជាសាធារណៈ។ នៅកន្លែងណា ត្រូវកំណត់ទីតាំងចរចាដោយអព្យាក្រឹត្យដូចជាការិយាល័យមេធាវី មជ្ឈមណ្ឌលតុលាការជាដើម ដើម្បីកុំឱ្យភាគីម្ខាងទៀតមានប្រៀបជាងក្នុងការកំណត់ទីតាំងតែម្ខាង និងរក្សាសន្តិសុខរបស់ភាគីទាំងសងខាង។ របៀបដែលអាចធ្វើការចរចាគ្នាមានដូចជា ការចរចាជាលក្ខណៈ តាមអ៊ីមែល តាមទូរស័ព្ទ និងការចរចាមុខគ្នាដោយផ្ទាល់។

❖ **ដំណាក់កាលព័ត៌មាន**

ក្នុងដំណាក់កាលនេះ មេធាវីភាគីទាំងសងខាងត្រូវចាប់ផ្ដើមផ្ដល់ព័ត៌មានគ្នាទៅវិញទៅមក។ ដោយរៀបរាប់ពីអង្គហេតុតាមការយល់ឃើញរបស់កូនក្ដីរៀងៗខ្លួន រួចបន្តពិនិត្យឡើងវិញដោយសង្ខេបលើលក្ខខណ្ឌច្បាប់ និងផ្ដល់សំណើរដោះស្រាយជាលាយលក្ខណ៍អក្សរ តាមរយៈអ៊ីមែល ឬលិខិត ឬការឆ្លើយឆ្លងគ្នាតាមរយៈទូរស័ព្ទ។ ប៉ុន្តែ ដើម្បីធ្វើឱ្យចំណុចនេះមានលក្ខណៈសាមញ្ញ នោះការចរចានឹងប្រព្រឹត្តទៅដោយការពិភាក្សាផ្ទាល់ទល់មុខគ្នា។ នៅពេលពិភាក្សាអំពីអង្គហេតុ និងអង្គច្បាប់ ភាគីត្រូវផ្ដល់ហេតុផលដែលមិនលម្អៀងចំពោះដំហរដោះស្រាយរបស់ខ្លួន។ នៅដំណាក់កាលនេះមេធាវីត្រូវដើរតួនាទីឱ្យមានសមភាពរវាងការព្យាយាមដឹងព័ត៌មានឱ្យបានច្រើនបំផុតពាក់ព័ន្ធនឹងផលប្រយោជន៍។ នៅក្នុងដំណើរការចរចាទាំងមូលប្រការដែលសំខាន់ គឺការសួរសំណួរទៅភាគីម្ខាងទៀត ត្រូវជំរុញពួកគេឱ្យពន្យល់អំពីជំហររបស់ពួកគេ ចំពោះអ្វីៗគ្រប់យ៉ាងតាំងពីទំនួលខុសត្រូវរហូតដល់ការខូចខាតនានា។ ជាការសំខាន់ត្រូវព្យាយាមរក្សាភាពវិជ្ជមានជានិច្ចទោះបីជាបញ្ហាហាក់ដូចជាមិនមានភាពអនុគ្រោះចំពោះកូនក្ដីរបស់អ្នកពីដំបូងមក ពោលគឺព្យាយាមប្រើប្រាស់ប្រយោគវិជ្ជមានជំនួសឱ្យការគំរាមកំហែង ឬពាក្យពេចន៍ដែលមានភាពអវិជ្ជមាន។ ការព្យាយាមធ្វើឱ្យភាគីម្ខាងទៀតបន្តការនិយាយនៅក្នុងកំឡុងពេលចរចា គឺជាប្រការដ៏មានសារៈប្រយោជន៍ ប្រសិនបើភាគីម្ខាងនោះនិយាយកាន់តែច្រើនគាត់អាចបញ្ចេញព័ត៌មានកាន់តែបានច្រើន។

❖ **ដំណាក់កាលបែងចែក / ផ្អែកលើផលប្រយោជន៍**

បន្ទាប់ពីភាគីវិវាទមានឱកាសពន្យល់អំពីការយល់ដឹងរបស់ខ្លួនចំពោះអង្គហេតុ ការវិភាគរបស់ខ្លួនលើអង្គច្បាប់ព្រមទាំងជំហរ និងផលប្រយោជន៍របស់ពួកគេរួចមក ដំណាក់កាលបែងចែកផ្អែកលើផលប្រយោជន៍ក៏ចាប់ផ្ដើម។ នេះគឺជាដំណាក់កាលដែលភាគីទាំងពីរស្វែងរកដំណោះស្រាយផ្អែកលើផលប្រយោជន៍ដែលអាចមានជាមុនសិន ហើយបើមិនមានលទ្ធភាពណាមួយនោះទេ ទើបបន្តទៅរកដំណោះស្រាយបែបបែងចែក។

❖ **ដំណាក់កាលបញ្ចប់**

នៅពេលមានការព្រមព្រៀងធ្វើការចរចា គឺត្រូវសរសេរជាលាយលក្ខណ៍អក្សរភ្លាមៗ ដើម្បីបង្ការកុំឱ្យភាគីម្ខាងទៀតធ្វើការពន្យាពេល។ ភាគីត្រូវត្រៀមខ្លួនជានិច្ចក្នុងការសរសេរចូលនូវលក្ខខណ្ឌព្រមព្រៀង ព្រមទាំងចុះហត្ថលេខា។ បន្ទាប់មក ត្រូវសរសេរលក្ខខណ្ឌច្បាស់លាស់ដើម្បីឱ្យរឿងក្ដីមានដំណើរការរលូន និងឆាប់ចប់ជាស្ថាពរ។

៣.១.២. ដំណើរការសន្ទានកម្ម

ជាទូទៅ ទម្រង់មួយនេះកើតឡើងបន្ទាប់ភាគីវិវាទចរចាគ្នានៅមិនទាន់សម្រេច ឬមិនអាចដោះស្រាយបាន។ ដំណើរការដោះស្រាយវិវាទបែបនេះមានលក្ខណៈស្រដៀងទៅនឹងការផ្សះផ្សានៅក្នុងតុលាការ។ ជាទូទៅដំណើរការនៃការអនុវត្តមានចំនួនប្រាំពីរដូចជា៖

❖ **ការផ្តួចផ្តើមសន្ទានកម្ម**

ជាដំណាក់ដំបូងនៅពេល ភាគីមានខស្តីពីដំណោះស្រាយវិវាទ នៅក្នុងកិច្ចសន្យាដែលមានស្រាប់របស់ពួកគេដោយរើសយកមធ្យោបាយសន្ទាកម្ម។ ភាគីសម្រេចចិត្តធ្វើសន្ទានកម្ម បន្ទាប់ពីវិវាទកើតឡើង ឬតុលាការបានបង្គាប់ ឬណែនាំឱ្យធ្វើសន្ទានកម្ម។ ដំណើរការនេះត្រូវមានការព្រមព្រៀងទាំងពីភាគីទាំងសងខាង ហើយសន្ទានកម្មមិនអាចប្រព្រឹត្តទៅបានឡើយប្រសិនបើមិនធ្វើដូច្នេះ។

❖ **ការជ្រើសរើសសន្ទានការី**

ប្រសិនបើ ភាគីមិនបានតាំងមជ្ឈមណ្ឌលសន្ទានកម្មជាក់លាក់ណាមួយនោះទេ ពួកគេអាចជ្រើសរើសសន្ទានការីដែលខ្លួនចូលចិត្ត និងរបៀបដែលខ្លួនចូលចិត្ត។ គេក៏អាចធ្វើសន្ទានកម្មដែលមាន សន្ទានការីពីរនាក់ ឬបីនាក់ផងក៏បាន។ ប៉ុន្តែជាទូទៅ គឺគេគួរធ្វើជាមួយសន្ទានការីតែម្នាក់។ មុននឹងជ្រើសរើសសន្ទានការី ភាគីគួរឈ្វេងយល់ ពិចារណាជាមុនសិនថា តើសន្ទានការីនោះមានអព្យាក្រឹតពេញលេញ និងគ្មានទំនាក់ទំនងជាមួយភាគីណាមួយមែនឬទេ? មានចំណេះដឹងអំពីបញ្ហាដែលជាកម្មវត្ថុនៃវិវាទដែរឬទេ? ធ្លាប់មានបទពិសោធន៍នៅក្នុងសន្ទានកម្មឬទេ? ជាមេធាវី ចៅក្រម ឬជាអ្នកគ្មានចំណេះដឹងខាងច្បាប់ឬទេ? ត្រូវបានណែនាំដោយភាគីដទៃដែរឬទេ? ជាអ្នកពូកែបញ្ចុះបញ្ចូលដែរឬទេ?

❖ **ការផ្តល់ព័ត៌មានដល់សន្ទានការី**

ភារកិច្ចដំបូងគេនោះ គឺត្រូវផ្តល់ព័ត៌មានដល់សន្ទានការីអំពីរឿងរ៉ាវដែលបានកើតឡើងនោះជាមុនសិន។ ហើយសន្ទានការីត្រូវតែរក្សាជាសម្ងាត់ មិនត្រូវប្រាប់ទៅភាគីដទៃឡើយ។ ចំពោះករណីស្មុគស្មាញ សន្ទានការីអាចស្នើឱ្យភាគីផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដែលពន្យល់អង្គហេតុ[៦២] ច្បាប់ដែលអនុវត្តបាន និងភស្តុតាងជាឯកសារដទៃទៀត។ សន្ទានការី អាចដឹងពីសាក្សីដែលត្រៀមខ្លួនធ្វើឯកសារដែលពាក់ព័ន្ធនឹងវិវាទឱ្យភាគីនីមួយៗផងដែរ។ ព័ត៌មានមុនសន្ទានកម្មទាំងអស់ នឹងជួយឱ្យសន្ទានការីដឹកនាំកិច្ចប្រជុំសម្រុះសម្រួលកាន់តែមានប្រសិទ្ធភាពថែមទៀត។ ម៉្យាងទៀត សន្ទានការីក៏ត្រូវរើសទីតាំងអព្យាក្រឹតណាមួយសម្រាប់កិច្ចប្រជុំ

[៦២] អង្គហេតុដែលមានការព្រមព្រៀង និងអង្គហេតុដែលមានវិវាទ

សម្រុះសម្រួលផងដែរ។ កន្លែងណាក៏បានឱ្យតែមានផាសុខភាព និងភាពងាយស្រួលសម្រាប់គូភាគី ហើយផ្តល់ដល់អ្នកចូលរួមនូវភាពឯកជន។

❖ **ការបើកកិច្ចប្រជុំ**

នៅពេលបើកប្រជុំភាគីវិវាទត្រូវជួបជាមួយសន្ធានការីដោយផ្ទាល់ មិនចាំបាច់មានមេធាវីមកជាមួយក៏ដំណើរការនោះមានលក្ខណៈក្រៅផ្លូវការ (ក្នុងរឿងក្តីដែលតូចតាច ឬសាមញ្ញ)។ ប៉ុន្តែនៅក្នុងរឿងក្តីដែលស្មុគស្មាញត្រូវតែមានវត្តមានមេធាវីចូលរួម។ ជាទូទៅ សន្ធានការីច្រើនតែជួបជាមួយភាគីទាំងពីរព្រមគ្នា ដើម្បីអាចធ្វើការសន្សំសំចៃពេលវេលា និងកាត់បន្ថយអារម្មណ៍សង្ស័យ ឬភាពលម្អៀងនៅពេលចាប់ផ្តើម។

សន្ធានការីតែងចាប់ផ្តើមណែនាំអ្នកចូលរួមឱ្យស្គាល់គ្នាទៅវិញទៅមក ព្រមទាំងពិនិត្យមើលដំណើរការ និងវិធានសម្រាប់កិច្ចប្រជុំ។ នៅក្នុងអំឡុងពេលប្រជុំ សន្ធានការី ព្យាយាមពន្យល់នូវតួនាទី និងនិយាយអំពីការសម្រុះសម្រួលដោះស្រាយវិវាទ ដល់ភាគីជារឿយៗ និងធានាឱ្យភាគីមានការទុកចិត្តមកលើខ្លួនដែលជាអ្នកសម្របសម្រួលវិវាទ ព្រមទាំងបញ្ជាក់អំពីភស្តុតាង និងវិធានច្បាប់នានាដល់ភាគី។ ក្នុងនោះផងដែល ភាគីទាំងពីរក៏ត្រូវបញ្ចេញមតិយោបល់រៀងៗខ្លួន ដើម្បីធ្វើការឈ្វេងយល់ពីគ្នាទៅវិញទៅមក។ ហើយមេធាវីរបស់ភាគីនីមួយៗគួរឡើងបញ្ចេញមតិ ដើម្បីធានាថាការឆ្លើយឆ្លងមានភាពងាយស្រួល និងព័ត៌មានមានភាពច្បាស់លាស់មានប្រសិទ្ធភាព និងមិនមានការចោទប្រកាន់។

ក្រោយពីភាគីនីមួយបញ្ចប់ការនិយាយបកស្រាយនូវមតិរបស់ខ្លួន សន្ធានការីអាចមានការសួរជាសំណួរខ្លះៗដើម្បីបំភ្លឺបញ្ហា និងធ្វើការកត់ត្រាឱ្យលម្អិតអំពីវិវាទនោះ ដើម្បីធានាថាខ្លួនពិតជាយល់ទាំងស្រុងនូវវិវាទនោះផងដែរ។ បន្ទាប់មក សន្ធានាការីនឹងផ្តល់ពេលវេលាសម្រាកដល់ភាគី។

❖ **កិច្ចប្រជុំដោះស្រាយកិច្ចទូទៅ**

នៅពេលភាគីត្រឡប់ចូលបន្ទប់ប្រជុំវិញ សន្ធានការីនឹងចាប់ផ្តើមកិច្ចប្រជុំដោះស្រាយបញ្ហាទូទៅ។ នេះជាពេលដែលសន្ធានការី ត្រូវព្យាយាមស្វែងរកឱកាសដោះស្រាយ ព្យាមយាមបំភ្លឺផ្នែកដែលមានការព្រមព្រៀងគ្នា និងមិនមានការព្រមព្រៀងគ្នា។ ជាទូទៅ ត្រូវព្យាយាមស្វែងយល់នូវចំណុចដំណោះស្រាយដ៏ល្អសម្រាប់ព្រមព្រៀងគ្នា និងមានអទិភាពផ្តល់នូវប្រយោជន៍រួមរបស់ភាគីវិវាទ។ សន្ធានការីត្រូវស្តាប់ដោយយកចិត្តទុកដាក់ចំពោះអ្វីដែលភាគីបាននិយាយ និងស្វែងរកចំណុចប្រសព្វគ្នាដើម្បីប្រយោជន៍សំខាន់ ដែលអាចតម្រូវបាននូវក្នុងការព្រមព្រៀងដោះស្រាយ។

បន្ទាប់មក សន្ធានការី ត្រូវបកស្រាយឡើងវិញនូវអ្វីដែលភាគីនីមួយបាននិយាយដោយមិនបំភ្លើស ឬកាត់ពាក្យចោល និយាយឡើងវិញនូវពាក្យសម្តីដែលមិនអំណោយផលរបស់ភាគី ដើម្បីជំរុញការពិភាក្សាឱ្យមាន

ទិសដៅកាន់តែអព្យាក្រឹត និងវិជ្ជមាន។ ការបកស្រាយឡើងវិញ អាចជាចំណុចលើកទឹកចិត្តឱ្យភាគីពិចារណា នូវស្ថានភាពរបស់ពួកគេ និងឈានទៅដល់ដំណោះស្រាយ។ ការបកស្រាយនេះមិនមែនជាការដោះស្រាយវិវាទទេ ប៉ុន្តែផ្តល់ជាឱកាសឱ្យឈានចេញពីទស្សនៈ និងពាក្យសម្តីអវិជ្ជមាន ឬមិនអំណោយផលចូលជាជម្រើសក្នុងការរកដំណោះស្រាយជំនួសវិញ។ បើសិនជាអាច សន្ធានការីទុកឱ្យភាគីនីមួយៗជាអ្នកបង្កើត និងស្នើនូវដំណោះស្រាយដោយខ្លួនឯង។ ប៉ុន្តែប្រសិនបើភាគីមិនមានលទ្ធភាព ឬមិនមានឆន្ទៈរកដំណោះស្រាយទេ សន្ធានការីអាចដើរតួសកម្មជាងមុន ហើយអាចស្នើដំណោះស្រាយដោយខ្លួនផ្ទាល់។

❖ **ជំនួបឯកជន**

ប្រសិនបើការសម្រុះសម្រួលនេះជួបនូវការលំបាក អ្នកសម្រុះសម្រួលអាចអញ្ជើញភាគីម្ខាងឱ្យចេញ ទៅក្រៅបន្ទប់ដើម្បីអាចឱ្យអ្នកសម្រុះសម្រួលនិយាយទៅកាន់ភាគីម្ខាងទៀតដោយផ្ទាល់។ បន្ទាប់ពីនិយាយផ្ទាល់ជាមួយភាគីម្ខាងរួចហើយ គេធ្វើការអញ្ជើញគាត់ចេញទៅក្រៅបន្ទប់ម្តងហើយនាំភាគីម្ខាងទៀតចូលមកក្នុងបន្ទប់វិញ។ ការប្រជុំលក្ខណៈឯកជនបែបនេះ អាចជួយអ្នកសម្រុះសម្រួលបាន ដូចជា ធ្វើឱ្យភាគីស្ងប់អារម្មណ៍ចំពោះភាគីដែលមានចរិតខឹងរឹងរូស ពុំអាចគ្រប់គ្រងបានដោយខ្វះការគោរព ឬមិនចេះអត់អោន។ អាចទទួលបានព័ត៌មានថា ភាគីម្ខាងមិនសូវចង់និយាយ ឬមានការខ្មាស់អៀន មិនចង់ពិភាក្សា នៅចំពោះមុខគ្នា។ ព្រមទាំងជួយឱ្យភាគីមួយពិចារណាមើលថា តើការទាមទាររបស់គេមានភាពប្រាកដនិយមឬអត់ ហើយថាតើពួកគេពិតជាចង់ដោះស្រាយបញ្ហាឬអត់ដោយមិនធ្វើឱ្យគេខ្មាស់អៀន ឬប៉ះពាល់ដល់អព្យាក្រឹតភាព។

❖ **ការបិទកិច្ចប្រជុំ**

ក្នុងការបិទកិច្ចប្រជុំ អាចមានលទ្ធផលដូចជា ភាគីទាំងពីរបានឈានការព្រមព្រៀងគ្នាទាំងស្រុង ភាគីមិនបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ប៉ុន្តែនឹងបន្តសន្ធានកម្មនៅពេលក្រោយ ឬភាគីបានឈានដល់ស្ថានភាពជាប់គាំង(ជួលកាលត្រូវបានគេហៅថា ភាពទ័លច្រក)ហើយសន្ធានកម្មត្រូវបានបញ្ចប់។

សម្រាប់បន្តសន្ធានកម្មនៅពេលក្រោយសន្ធាការីត្រូវសង្កត់ធ្ងន់លើការរីកចម្រើនដែលបានបង្កើតឡើង និងផ្តល់សំណើរមួយចំនួនសម្រាប់ការពិចារណា នៅកិច្ចប្រជុំលើកក្រោយ។ កិច្ចប្រជុំលើកក្រោយត្រូវកំណត់បរិច្ឆេទឱ្យបានឆាប់រហ័ស។ ប្រសិនបើសន្ធានកម្មត្រូវបានបញ្ចប់ដោយការជាប់គាំង នោះអាចមកពីភាគីបដិសេធយ៉ាងដាច់អហង្ការក្នុងការពិភាក្សាដោះស្រាយ។ ហើយវិវាទអាចបន្តបានក្នុងដំណើរការ មជ្ឈត្តការ ការចរចាជាឯកជន ព្រមទាំងបណ្តឹងទៅតុលាការ។

៣.១.៣. ដំណើរការមជ្ឈត្តកម្ម

ដំណើរការមជ្ឈត្តការមានដូចជា៖

### ❖ ការផ្តួចផ្តើមមជ្ឈត្តការ

មជ្ឈត្តការអាចផ្តួចផ្តើមឡើងដោយការស្នើឱ្យធ្វើមជ្ឈត្តការស្របតាមកិច្ចព្រមព្រៀងស្តីពីមជ្ឈត្តកម្មដែលមានស្រាប់ ការព្រមព្រៀងឱ្យធ្វើមជ្ឈត្តការនៅពេលវិវាទកើតឡើង និងមជ្ឈត្តការដែលត្រូវបានអនុវត្តតាមបង្គាប់របស់តុលាការ។ ភាគីផ្តួចផ្តើមមជ្ឈត្តការហៅថា "ភាគីប្តឹង" ឯភាគីដែលទទួលសំណើរហៅថា "ភាគីឆ្លើយតប"។

ការដាក់ពាក្យរបស់ភាគី ប្រសិនបើមានកិច្ចព្រមព្រៀងមុនជាស្រាប់ ជាទូទៅគឺផ្អែកនៃកិច្ចសន្យាដើមមានដែលលក្ខណៈជាលាយលក្ខណ៍អក្សរ។ ក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការរបស់ខ្លួន សំណើរ ឬលិខិតជូនដំណឹងត្រូវបែងចែកចំណុចដូចជា ឈ្មោះ និងព័ត៌មានលម្អិតរបស់គូភាគី សេចក្តីបរិយាយអំពីវិវាទ សេចក្តីបញ្ជាក់អំពីការស្វែងរកជំនួយ និងកិច្ចព្រមព្រៀងពាក់ព័ន្ធទាំងអស់ រួមទាំងកិច្ចព្រមព្រៀងមជ្ឈត្តការ។[៦៣] ក្នុងលិខិតបញ្ជាក់អំពីទាមទារការប្តឹងត្រូវមានអង្គហេតុ បញ្ហា និងដំណោះស្រាយដែលខ្លួនចង់បាន។

នៅពេលភាគីប្តឹងដាក់ពាក្យរួចហើយ ភាគីឆ្លើយតបក៏ត្រូវដាក់ពាក្យរបស់ខ្លួនដែរ។ ភាគីឆ្លើយតបត្រូវធ្វើពាក្យដោះសាររបស់ខ្លួនដែលឆ្លើយតបទៅនឹងចំណុចដែលបានលើកឡើងនៅក្នុងបណ្តឹងទាមទារ ព្រមទាំងភ្ជាប់ឯកសារពាក់ព័ន្ធនឹងបណ្តឹងដែលខ្លួនមានផងដែរ។[៦៤] ភាគីឆ្លើយតបមានពេល ៣០ថ្ងៃចាប់ពីពេលទទួលលិខិតជូនដំណឹងជាលើកដំបូងឱ្យធ្វើការដោះសារ និងដាក់បណ្តឹងតប។[៦៥]

### ❖ ការជ្រើសរើសវេទិកាមជ្ឈត្តកម្ម

វេទិកានេះ គឺសំដៅទៅលើវេទិកាមជ្ឈត្តកម្មដែលត្រូវបានបង្កើតឡើងក្រោមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងវេទិកានេះត្រូវមានមជ្ឈត្តករបីរូប ឬច្រើនរូបដែលត្រូវបានជ្រើសតាំងដោយភាគីវិវាទ ឬដោយគណៈកម្មាធិការតែងតាំងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[៦៦] នៅក្នុងវេទិកាមជ្ឈត្តកម្ម ភាគីវិវាទវិវាទមានសិទ្ធិសេរីភាពពេញលេញក្នុងការជ្រើសរើសនូវចំនួនមជ្ឈត្តការក៏ដូចជា ការកំណត់នូវលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលនឹងត្រូវចូលខ្លួនមក

---

[៦៣] វិធានទាំងបីនេះ ក៏រួមបញ្ចូលនូវចំនួន និងជម្រើសមជ្ឈត្តករក្នុងពាក្យរបស់ភាគីប្តឹង។ សមាគមមជ្ឈត្តការអាមេរិក (AAA) មាត្រា២ មជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធាន (UNCITRAL) មាត្រា៤ និងសភាពាណិជ្ជកម្មអន្តជាតិទីក្រុងប៉ារីស (ICC) មាត្រា៣-៤

[៦៤] យោងតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងវិធាន UNCITRAL, មាត្រា១៩

[៦៥] វិធាន AAA, មាត្រា៣, វិធាន ICC, មាត្រា៥

[៦៦] មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ប្រការ២៥.២

ធ្វើការដោះស្រាយវិវាទ ទោះបីជាច្បាប់បានផ្តល់សិទ្ធិសេរីភាពទាំងនេះជូនភាគីវិវាទមែនតែច្បាប់នៅតែបានបញ្ញត្តិលម្អិតលើសិទ្ធិសេរីភាពទាំងអស់នោះផងដែរ។[៦៧]

### ❖ នីតិវិធីមុនសវនការ (វិធាន ទីកន្លែង ភាសា)

គូភាគីវិវាទមានសេរីភាពក្នុងការព្រមព្រៀងយកច្បាប់ណាមួយដែលវេទិកាមជ្ឈត្តកម្មត្រូវយកមកអនុវត្ត ហើយវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តច្បាប់នោះចំពោះខ្លឹមសារនៃវិវាទ។ ក្នុងករណីដែលមិនមានការព្រមព្រៀងគ្នា វេទិកាមជ្ឈត្តកម្មត្រូវកំណត់យកច្បាប់ណាមួយ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្របមកអនុវត្ត។ បញ្ញត្តិក្នុងកិច្ចសន្យា និងទម្លាប់ពាណិជ្ជកម្ម នៅគ្រប់ករណីទាំងអស់ វេទិកាមជ្ឈត្តកម្មត្រូវយកមកពិចារណានូវបញ្ញត្តិនានាដែលមានចែងក្នុងកិច្ចសន្យា ប្រសិនបើមាន រួមទាំងទម្លាប់ពាណិជ្ជកម្មនានាដែលពាក់ព័ន្ធ។[៦៨]

សម្រាប់ទីកន្លែង លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ឬដោយសារកាលៈទេសៈនានានៃសំណុំរឿង។ វេទិកាមជ្ឈត្តកម្មសម្រេចថាទីកន្លែងធ្វើមជ្ឈត្តការផ្សេងទៀតដែលមានលក្ខណៈសមស្របជាទីកន្លែងធ្វើមជ្ឈត្តកម្មទាំងអស់ដែលធ្វើឡើងក្រោមវិធាននេះគឺរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា។[៦៩] ទីកន្លែងធ្វើមជ្ឈត្តការ មិនកំណត់អំពីទីកន្លែង ដែល វេទិកាមជ្ឈត្តកម្មអាចជួបប្រជុំ និងធ្វើសវនាការនោះទេ។[៧០]

គូភាគីមានសេរីភាពក្នុងការយល់ព្រមលើភាសានៃដំណើរការមជ្ឈត្តការ។ប្រសិនបើពួកគេមិនយល់ព្រមទេនោះ វេទិកាមជ្ឈត្តកម្មនឹងធ្វើការកំណត់អំពីភាសានោះ។[៧១]

### ❖ ការធ្វើសេចក្តីសម្រេច

ក្នុងករណីវេទិកានៃមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប មជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីសម្រេចផ្សេងៗត្រូវធ្វើឡើងដោយមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករជាសមាជិកនៃវេទិកាមជ្ឈត្តកម្មទាំងអស់។ ដោយមានការយល់ព្រមជាមុន ពីវេទិកាមជ្ឈត្តកម្ម ប្រធាននៃមជ្ឈត្តកម្មអាចសម្រេចនូវនីតិវិធីតែម្នាក់ឯងបាន។[៧២]

សម្រាប់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើឡើងដោយមានការចូលរួមសហការពីមជ្ឈត្តករទាំងអស់ នឹងតម្រូវអោយធ្វើជាលាយលក្ខណ៍អក្សរ ព្រមទាំងសំអាងហេតុផលក្នុងការសម្រេចរួចចុះហត្ថលេខាដោយមជ្ឈត្តករទាំងអស់។

[៦៧] មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ប្រការ២៧.១

[៦៨] វិធាន ស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា, វិធាន១៧

[៦៩] វិធាន ស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា, វិធាន១៦

[៧០] វិធាន ស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា, វិធាន២៤.៣

[៧១] វិធាន ស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា, វិធាន១៨.១

[៧២] វិធាន ស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា, វិធាន៣២

វេទិកាមជ្ឈត្តកម្ម មិនត្រូវចេញមជ្ឈត្តវិនិច្ឆ័យណាមួយឡើយ ប្រសិនបើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យនោះមិនទាន់ត្រូវបានពិនិត្យ និងឯកភាពដោយអគ្គលេខាធិការដ្ឋាន។[៧៣]

៣.១.៤. ដំណើរការដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋ

នៅប្រទេសកម្ពុជាស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលនៅកៀកនឹងប្រជាជនជាងគេនោះគឺការិយាល័យប្រជាពលរដ្ឋដែលមាននៅគ្រប់អង្គភាពច្រកចេញចូលតែមួយទាំងនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុងស្រុកខណ្ឌ និងជាយន្តការដោះស្រាយមួយដែលមានប្រសិទ្ធភាព មានការគាំទ្រនិងពេញចិត្តពីសំណាក់ប្រជាពលរដ្ឋផងនោះ។ ហេតុនេះហើយយើងខ្ញុំនឹងធ្វើការលើកឡើងអំពីដំណើរការនៃការដោះស្រាយដោយការិយាល័យប្រជាពលរដ្ឋជាបន្តទៅនេះ។

**៣.១.៤.១. ការសម្រុះសម្រួលដោះស្រាយ**

ការសម្រុះសម្រួលដោះស្រាយសំដៅលើការស្វែងរកដំណោះស្រាយណាមួយ ដោយសមស្របតាមអនុលោមច្បាប់ និងវិធានបទដ្ឋានគតិយុត្តិ។

ដំណើរការសម្រុះសម្រួលបណ្ដឹងមាន បីដំណាក់កាលដូចជាៈ

**ក. ដំណាក់កាលមុនសម្រុះសម្រួលដោះស្រាយ**

ជាដំណាក់កាលដែល អ្នកសម្រុះសម្រួល សិក្សាសំណុំរឿង និងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីរៀបចំរបៀបវារៈ ទីកន្លែង និងកាលបរិច្ឆេទសម្រុះសម្រួល។ រៀបចំឯកសារ និងកំណត់ហេតុសម្រាប់បម្រើការក្នុងកិច្ចប្រជុំសម្រុះសម្រួល។[៧៤]

**ខ. ដំណាក់កាលសម្រុះសម្រួលដោះស្រាយ**

ដំណាក់កាលនេះ គឺគេចាប់ផ្ដើមកិច្ចប្រជុំដោយអ្នកសម្រុះសម្រួលណែនាំភាគីពាក់ព័ន្ធបានស្គាល់គ្នារួចនិយាយពីគោលបំណង និងបទញ្ញាវផ្ទៃក្នុង និងគោលការណ៍សំខាន់ៗក្នុងកិច្ចប្រជុំនេះ។ បន្ទាប់មកធ្វើការស្នើឱ្យភាគីអ្នកប្ដឹងនិយាយរៀបរាប់ដំណើររឿងនៃវិវាទ និងភាគីត្រូវប្ដឹងផ្ដល់ចម្លើយរបស់ខ្លួន។ បន្ទាប់ពីស្ដាប់ភាគីទាំងពីររួចមក អាជ្ញាធរដោះស្រាយវិវាទនឹងធ្វើការពិភាក្សាស្វែងរកដំណោះស្រាយ។ នៅពេលមានការព្រមព្រៀងគ្នាហើយអ្នកសម្រុះសម្រួលត្រូវរៀបចំកំណត់ហេតុសម្រុះសម្រួល និងអានកំណត់ហេតុនោះ រួចស្នើឱ្យភាគីវិវាទចុះ

[៧៣] វិធាន ស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា, វិធាន៣៤

[៧៤] សៀវភៅណែនាំ ស្ដីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត, គេហទំព័រ https://www.owso.gov.kh/wp-content/uploads/2019/07/CP_Ombudsman_Complaint-Manual_Final-2.pdf, ដកស្រង់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤

ហត្ថលេខា និងផ្តិតមេដៃយល់ព្រម។ កំណត់ហេតុនោះត្រូវប្រគល់ជូនភាគីវិវាទម្នាក់មួយច្បាប់និងតម្កល់ទុកនៅការិយាល័យប្រជាពលរដ្ឋមួយច្បាប់។[៧៥]

**គ. ដំណាក់កាលក្រោយសម្រុះសម្រួលដោះស្រាយ**

ក្នុងដំណាក់កាលនេះ អ្នកសម្រុះសម្រួលដោះស្រាយបណ្តឹងត្រូវផ្ញើរកំណត់ហេតុសម្រុះសម្រួលទៅប្រធានអង្គភាពនៃអ្នកត្រូវគេប្តឹង ដោយមានភ្ជាប់ដីកាអម។ រាយការណ៍អំពីការសម្រុះសម្រួលដោះស្រាយបណ្តឹងទៅប្រធានប្រឹក្សា និងរៀបចំតារាងលទ្ធផលនៃការសម្រុះសម្រួល និងស៊ើបអង្កេតបណ្តឹង ហើយបិទផ្សាយជាសាធារណៈនៅក្តារព័ត៌មានរបស់ការិយាល័យប្រជាពលរដ្ឋ។[៧៦]

**៣.១.៤.២. ការស៊ើបអង្កេតបណ្តឹង**

សំដៅដល់ដំណើរការស្រាវជ្រាវ ព័ត៌មានដែលទាក់ទងនឹងភស្តុតាងដើម្បីបញ្ជាក់ការពិត ឬមិនពិតនៅក្នុងអង្គហេតុដូចដែលមានក្នុងបណ្តឹង។ ភស្តុតាងទាំងនោះអាចមានជា កិច្ចសន្យាលាយលក្ខណ៍អក្សរ វីដេអូសារសំឡេង រូបថត ឬឯកសារផ្សេងៗទៀតដែលទទួលបានពីសាក្សីជាដើម។[៧៧]

ដំណើរការស៊ើបអង្កេតមានបីដំណាក់កាល ដូចជា ៖

**ក. ដំណាក់កាលមុនស៊ើបអង្កេត**

ក្នុងដំណាក់កាលនេះ ការិយាល័យប្រជាពលរដ្ឋត្រូវសិក្សាសំណុំរឿង និងលិខិតបទដ្ឋាននានាឱ្យច្បាស់លាស់ ដើម្បីកំណត់សមាភាព និងបែងចែកភារកិច្ចដល់អ្នកស៊ើបអង្កេត ព្រមទាំងរៀបចំផែនការ ឯកសារបណ្តឹង បញ្ជីសំណួរ និង កំណត់អ្នកសម្ភាសន៍ និងទីតាំងសម្ភាសន៍។[៧៨]

**ខ. ដំណាក់កាលស៊ើបអង្កេត**

ជាដំណាក់កាល ដែលអ្នកស៊ើបអង្កេតត្រូវអនុវត្តនូវភារកិច្ចរបស់ខ្លួន ក្នុងការប្រមូលភស្តុតាងណាដែលពាក់ព័ន្ធនឹងអង្គហេតុដោយធ្វើការសម្ភាសន៍ អ្នកប្តឹង អ្នកត្រូវគេប្តឹង សាក្សី អ្នកដឹងឮ អ្នកពាក់ព័ន្ធផ្សេងទៀត

[៧៥] សៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត, ទំព័រទី២៧

[៧៦] សៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត, ទំព័រទី២៧

[៧៧] សៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត, ទំព័រទី២៧

[៧៨] សៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត, ទំព័រទី២៩

ដែលគិតថាសំខាន់ក្នុងរឿងក្តី។ បន្ទាប់មកអាចចុះត្រួតពិនិត្យមើលកន្លែងកើតហេតុដើម្បីស្វែងរកភស្តុតាង និងសាកសួរព័ត៌មានបន្ថែមពីប្រជាជននៅទីនោះ។ បន្ទាប់ពីប្រមូលភស្តុតាងបានហើយអ្នកស៊ើបអង្កេតអាចទៅពិភាក្សាជាមួយអ្នកជំនាញសម្រាប់ផ្តល់យោបល់ប្រសិនបើគិតថាចាំបាច់។

ការវិភាគភស្តុតាង គឺតម្រូវអោយមានការពិនិត្យថ្លឹងថ្លែងមើលថាភស្តុតាងដែលបានប្រមូលមកអាចមានភាពច្បាស់លាស់អាចជឿទុកចិត្តបាន ហើយនឹងពាក់ព័ន្ធនឹងអង្គហេតុពិតៗដើម្បីបញ្ជាក់ថាពិតជាមាននៅក្នុងហេតុការណ៍ប្រាកដមែន។[៧៩]

### គ. ដំណាក់កាលក្រោយស៊ើបអង្កេត

ក្នុងដំណាក់កាលនេះ អ្នកស៊ើបអង្កេតត្រូវផ្ញើរបាយការណ៍ ទៅប្រធានអង្គភាពនៃអ្នកត្រូវគេប្តឹងដោយមានភ្ជាប់ដីកាអម។ រាយការណ៍ទៅក្រុមប្រឹក្សា អំពីលទ្ធផលនៃអនុសាសន៍ អំពីវិធានការដោះស្រាយបណ្តឹងដែលបានកំណត់ក្នុងរបាយការណ៍។ រៀបចំតារាងសម្រុះសម្រួល និងការស៊ើបអង្កេតបណ្តឹង បន្ទាប់មកធ្វើការបិទផ្សាយជាសាធារណៈនៅក្តារព័ត៌មានការិយាល័យប្រជាពលរដ្ឋ។ ព្រមទាំងផ្តល់ព័ត៌មានទៅដល់អ្នកប្តឹងតាមរយៈការបិទផ្សាយនោះ ឬតាមអ៊ីមែល ឬទូរស័ព្ទទៅសាមីខ្លួន។[៨០]

## ៣.២. ករណីប្រទេសជប៉ុន

នៅប្រទេសជប៉ុនក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងប្រទេសកម្ពុជាដែរ។ ការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការដែលស្ថិតនៅជិតប្រជាពលរដ្ឋជាងគេនោះគឺ ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា (នៅកម្ពុជា គឺការិយាល័យប្រជាពលរដ្ឋ)។ ចំណែកឯការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយ ការចរចា សន្ទានកម្ម និងមជ្ឈត្តកម្មមានដំណើរការដូចតទៅ។

៣.២.១. ដំណើរការការចរចា

**ដំណាក់កាលមុនចាប់ផ្តើមការចរចា៖** ដោយសារតែការចរចាអាចធ្វើទៅបានដោយមានការណែនាំពីចៅក្រមនោះដំណើរការនៃការចរចាអាចធ្វើទៅបានក្នុងករណីដែលមានចៅក្រមមួយរូបជួយណែនាំ។ ក្នុងករណីដែលមានចៅក្រមបីរូប មានចៅក្រមម្នាក់ជាប្រធាន និងចៅក្រមជាដៃស្តាំមានតួនាទីចូលរួមពិភាក្សាជាមួយប្រធានហើយចៅក្រមជាដៃឆ្វេងពុំសូវមានភារកិច្ចអ្វីប៉ុន្មាននោះទេ។ ប៉ុន្តែគាត់អាចចូលរួមធ្វើការស្តាប់ការពិភាក្សា

[៧៩] សៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ រាជធានី ខេត្ត, ទំព័រទី៣២

[៨០] សៀវភៅណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ រាជធានី ខេត្ត, ទំព័រទី៣៥

នោះ និងសិក្សាបន្ថែមដើម្បីជួយស្វែងរកដំណោះស្រាយបានដែរ។ ជាទូទៅនៅពេលជួបជាមួយនឹងភាគីចៅក្រម ដៃស្តាំ និងចៅក្រមដៃឆ្វេងមិនចូលរួមនោះឡើយ គឺគ្រាន់តែតាមដានដំណើរការតាមការរាយការណ៍ពីចៅក្រមជាប្រធានតែប៉ុណ្ណោះ។

**ដំណាក់កាលចាប់ផ្តើមការចរចា៖** ជាដំបូងមុននឹងចាប់ផ្តើមដំណើរការចរចាចៅក្រមធ្វើការណែនាំពន្យល់អំពីដំណើរការនៃការចរចា និងអត្ថប្រយោជន៍របស់វាជាមុនសិន។ ចៅក្រមធ្វើតួនាទីជាអ្នកជួយសម្របសម្រួលដោះស្រាយតាមវិធីសាស្ត្រ "Anglo Saxon" ឬហៅម្យ៉ាងទៀតហៅថា វិធីសាស្ត្រគ្រប់គ្រងជម្លោះ (Controlled burn)។ ការចរចានេះធ្វើឡើងដោយចៅក្រមជួបជាមួយនឹងគូភាគីម្តងម្នាក់ៗជាលក្ខណៈឯកជន។ គេធ្វើរបៀបនេះក្នុងគោលបំណងចង់អោយភាគីទាំងសងខាងអាចនិយាយពីរឿងរ៉ាវដែលនាំអោយមានវិវាទអោយបានលម្អិតដោយពុំចាំបាច់លាក់បាំង ឬខ្លាចភាគីម្ខាងទៀតមិនពេញចិត្តនឹងការលើកឡើងណាមួយរបស់ខ្លួននោះទេ។

**ដំណាក់កាលដំណើរការការចរចា៖** បន្ទាប់ពីការចរចាលក្ខណៈឯកជនបានបញ្ចប់ចៅក្រមនឹងធ្វើការកោះហៅភាគីទាំងសងខាងមកជួបគ្នាដើម្បីធ្វើការចរចា។ នៅក្នុងជំហាននេះ គូភាគីទទួលបានឱកាសក្នុងការចរចាពីដំណើរដើមហេតុនៃជម្លោះ និងស្ថានភាពនៃជម្លោះជាដើម។ ចៅក្រមធ្វើការស្តាប់នៃការចរចាគ្នារបស់ភាគីដោយយកចិត្តទុកដាក់ និងមិនជ្រៀតជ្រែកចូលរំខានដល់គូភាគីឡើយ។ នៅចំណុចនេះ គូភាគីអាចនឹងឈានទៅដល់ការដោះស្រាយជម្លោះបាន និងអាចឆ្លុះបញ្ចាំងពីកំហុសរៀងៗខ្លួនផងដែរ។

នៅដំណាក់កាលនេះដោយចៅក្រមធ្វើការស្តាប់ដោយយកចិត្តទុកដាក់ និងគ្មានការវាយតម្លៃអវិជ្ជមានណាមួយដល់គូភាគី នោះវាអាចធ្វើអោយគូភាគីមានទំនុកចិត្តលើចៅក្រមក្នុងការធ្វើជាអ្នកជួយសម្រុះសម្រួលវិវាទ។ ចៅក្រមអាចធ្វើការដោះស្រាយដោយពុំចាំបាច់ស្របទៅតាមនីតិវិធីច្បាប់នោះទេ ប៉ុន្តែក្នុងករណីដែលវិវាទរបស់គូភាគីមានទំនាក់ទំនងផ្លូវច្បាប់នោះនីតិវិធីច្បាប់នឹងត្រូវបានយកមកអនុវត្ត។

**ដំណាក់កាលបញ្ចប់ការចរចា៖** បន្ទាប់ពីបញ្ចប់ការចរចារួចរាល់ហើយ ចៅក្រមនឹងធ្វើការផ្តល់ជា មតិយោបល់ប្រឹក្សា ក៏ដូចជាដំណោះស្រាយដែលសមរម្យមួយដល់គូភាគីដើម្បីបញ្ចប់វិវាទនោះដោយសន្តិវិធី និងផ្តល់នូវអត្ថប្រយោជន៍ដល់ភាគីទាំងសងខាង។ ប្រសិនបើគូភាគីព្រមទទួលធ្វើការចរចានោះអ្នកតំណាងនឹងធ្វើការកំណត់កាលបរិច្ឆេទជួបជាមួយនឹងចៅក្រមជាលើដំបូង (ការចរចានេះមានវត្តមានរបស់ចៅក្រមផ្ទាល់ដែលខុសពីការផ្សះផ្សា ដោយចៅក្រមគ្រាន់តែពិភាក្សាជាមួយនឹងគណៈកម្មាធិការ តែមិនជួបជាមួយនឹងគូភាគី)។

ការចរចានេះ នឹងធ្វើឡើងជាច្រើនដងរហូតដល់អាចធ្វើការចរចាបានដោយជោគជ័យ។ ប្រសិនបើគូភាគីមិនព្រម ទទួលយកនូវការផ្សះផ្សានោះទេ គូភាគីនឹងត្រូវបន្តទៅធ្វើការដោះស្រាយនៅតុលាការជាបន្តទៀត។[៨១]

៣.២.២. ដំណើរការសន្ទានកម្ម

ការធ្វើសន្ទានកម្ម មានលក្ខណៈពិសេសត្រង់ការតម្រូវអោយប្រព្រឹត្តទៅដោយអនុវត្តតាមនីតិវិធីច្បាប់ត្រឹមត្រូវ។ ដំណើរការសន្ទានកម្មធ្វើឡើងដោយមានគណៈកម្មាធិការសន្ទានកម្មចូលរួមជាមួយចៅក្រមផងដែរ។ គណៈកម្មាធិការសន្ទានកម្មនេះសំដៅដល់ ចៅក្រមតែម្នាក់ ឬក្រុមសន្ទានការី។

**ដំណាក់កាលមុនចាប់ផ្តើមសន្ទានកម្ម៖** គណៈកម្មាធិការនេះ អាចធ្វើការពិភាក្សាជាមួយនឹងគូភាគី ហើយដំណើរការនេះប្រព្រឹត្តទៅដោយសម្ងាត់។ ការធ្វើសន្ទានកម្មនេះតម្រូវអោយមានការបង់ប្រាក់ប្រសិនបើភាគីស្នើសុំធ្វើសន្ទានកម្ម។ ការបង់ប្រាក់នេះគឺតុលាការកំពូលជាអ្នកកំណត់នៅក្នុងតម្លៃសមរម្យមួយអាស្រ័យទៅតាមច្បាប់ដែលបានកំណត់។ បន្ទាប់មកគណៈកម្មាធិការ ធ្វើការកំណត់កាលបរិច្ឆេទនៃការធ្វើសន្ទានកម្ម ហើយបុគ្គលពាក់ព័ន្ធណាដែលមានការចង់ដឹងឮពីការដោះស្រាយវិវាទនេះក៏អាចធ្វើការចូលរួមបានដោយមានការអនុញ្ញាតពីគណៈកម្មាធិការ។

**ដំណាក់កាលចាប់ផ្តើមសន្ទានកម្ម៖** ការឡើងសវនការលើកដំបូងគណៈកម្មាធិការនឹងធ្វើការរៀបរាប់ពីដំណើរការនៃសន្ទានកម្មដល់ភាគីទាំងសងខាង។ ចំណែកសវនការបន្ទាប់ទៀតនឹងមានការចូលរួមពីសាក្សីភាគីពាក់ព័ន្ធ ព្រមទាំងមានអ្នកជំនាញចូលរួមដើម្បីធ្វើការផ្តល់ជាគំនិតយោបល់បន្ថែមទៀត។ បន្ទាប់ពីធ្វើសវនការច្រើនដងរួចហើយគេនឹងជម្រុញអោយគូភាគីធ្វើការបង្ហាញពីការទាមទារចង់បានរបស់ខ្លួន។

**ដំណាក់កាលធ្វើសន្ទានកម្ម៖** គណៈកម្មាធិការអាចធ្វើការហាមឃាត់នៅរាល់សកម្មភាពឬការទាមទារណាមួយរបស់គូភាគី ប្រសិនបើគណៈកម្មាធិការយល់ថាវាជារឿងដែលពុំត្រឹមត្រូវ ឬការទាមទារនោះហួសកម្រិតដែលធ្វើអោយភាគីម្ខាងទៀតមិនអាចធ្វើទៅបាន។ ការធ្វើសន្ទានកម្មអាចត្រូវចំណាយពេលច្រើនខែថ្ងៃ ដើម្បីដោះស្រាយ ឬគណៈកម្មាធិការអាចបិទបញ្ចប់ការធ្វើសន្ទានកម្មនៅពេលណាដែលសមស្រប។

**ដំណាក់កាលបិទបញ្ចប់សន្ទានកម្ម៖** ការបិទបញ្ចប់នេះ និងធ្វើឡើងប្រសិនបើគណៈកម្មាធិការយល់ឃើញថាការដោះស្រាយតាមសន្ទានកម្មមិនអាចទៅរួច ឬការទាមទាររបស់គូភាគីជាអ្វីដែលពុំអាចទៅរួច។ ក្នុងករណីដែលភាគីមិនព្រមធ្វើការស្រុះស្រួលគ្នានោះតុលាការនឹងធ្វើការដាក់ចេញនូវលិខិតបញ្ចប់វិវាទ។ ពេលនោះភាគីអាចនឹងធ្វើការពិនិត្យ និងពិចារណាពីការដោះស្រាយរបស់គណៈកម្មាធិការឡើងវិញ។

[៨១] (Katja Funken, "Alternative Dispute Resolution in Japan", 15 16), ទំព័រទី១៥-១៦, គេហទំព័រ file:///C:/Users/TRC/Downloads/ssrn-458001.pdf, ដកស្រង់ថ្ងៃ២៦ ខែឧសភា ឆ្នាំ២០២៤

សន្ធានកម្មជាវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានប្រជាប្រិយភាព និងមានប្រសិទ្ធភាពជាងគេនៅជប៉ុន។ ប៉ុន្តែបញ្ហាស្ថិតនៅត្រង់ថាសន្ធានការីគឺពុំមែនជាអ្នកដែលមានជំនាញខាងច្បាប់អ្វីប៉ុន្មាននោះទេ ពួកគាត់គ្រាន់តែជាអ្នកដែលមាននូវចំណេះទូទៅខ្ពស់ និងយល់ពីក្រមសីលធម៌ច្រើនជាដើម។[៩២]

៣.២.៣. ដំណើរការមជ្ឈត្តកម្ម

មជ្ឈត្តកម្ម ប្រព្រឹត្តទៅតាមផ្នែកនីមួយៗដោយឡែកពីគ្នាដែលក្នុងនោះរួមមាន សន្ធានកម្មពាណិជ្ជកម្ម សន្ធានកម្មវិវាទការងារ សន្ធានកម្មវិស័យសាងសង់ និងសន្ធានកម្មបរិស្ថាន នោះការធ្វើសន្ធានកម្មនៃផ្នែកទាំង៤ ប្រភេទនេះក៏មានលក្ខណៈខុសៗគ្នាដែរ។ ហេតុនេះហើយ ច្បាប់ និងគោលការណ៍របស់ផ្នែកទាំងនេះដើរតួនាទីបំពេញបន្ថែមលើការធ្វើមជ្ឈកម្មតាមនីតិវិធីរដ្ឋប្បវេណី។ ដែលមានន័យថា វាជាច្បាប់ពិសេសរបស់ផ្នែកទាំង៤ ហើយនីតិវិធីរដ្ឋប្បវេណីជាច្បាប់ទូទៅ។ ចំណែកឯដំណើរការនៃការធ្វើមជ្ឈត្តកម្មក៏មានការបែងចែកដោយឡែកពីគ្នាតាមផ្នែកនីមួយៗផងដែរ។[៩៣] ចំនួនមជ្ឈត្តករប្រសិនបើគ្មានការព្រមព្រៀងពីភាគីនោះករណីភាគីមានចំនួន ២នាក់ នោះចំនួនមជ្ឈត្តករត្រូវមានចំនួន៣រូប ក្នុងករណីភាគីមានចំនួនចាប់ពី៣នាក់ឡើងទៅតុលាការនឹងធ្វើការកំណត់ចំនួនមជ្ឈត្តករតាមសំណើរបណ្ដឹងរបស់ភាគី។[៩៤]

**ដំណាក់កាលមុនសវនការ៖** បន្ទាប់ពីធ្វើការជ្រើសរើស ភាគីវិវាទមានឱកាសទទួលបាននូវការណែនាំ និងពន្យល់ពីដំណើរនៃការធ្វើមជ្ឈត្តកម្មអោយបានលម្អិត។ ចំពោះទីកន្លែងនៃការដំណើរការមជ្ឈត្តការ អាស្រ័យទៅលើការព្រមព្រៀងគ្នារវាងគូភាគី។ បើគ្មានការព្រមព្រៀងរវាងគូភាគីនោះទេ អាជ្ញាកណ្ដាលមជ្ឈត្តកម្ម នឹងពិចារណាពីស្ថានភាពរបស់គូភាគីទាំងពីរ រួចធ្វើការសម្រេចជ្រើសរើសទីតាំង។ បន្ទាប់មកទៀត អាជ្ញាកណ្ដាលមជ្ឈត្តកម្ម នឹងធ្វើការប្រជុំ និងពិចារណា ស្ដាប់សេចក្ដីថ្លែងការពីភាគីពាក់ព័ន្ធ ឬអ្នកជំនាញ ក៏ដូចជាធ្វើការកំណត់អត្តសញ្ញាណភស្តុតាង ឬឯកសារ។[៩៥]

**ដំណាក់កាលបើកវេទិកាមជ្ឈត្តកម្ម៖** ការចាប់ផ្ដើមដំណើរការមជ្ឈត្តកម្ម ប្រសិនបើគ្មានការព្រមព្រៀងពិសេសណាមួយរវាងគូភាគីទេនោះ នៅពេលដែលភាគីម្ខាងធ្វើការផ្ដល់ព័ត៌មានទាក់ទងនឹងការស្នើធ្វើមជ្ឈត្តកម្មទៅភាគីម្ខាងទៀត គឺពេលនោះហើយដែលនីតិវិធីមជ្ឈត្តកម្មនឹងចាប់ផ្ដើម។[៩៦]

---

[៩២] គេហទំព័រ file:///C:/Users/TRC/Downloads/ssrn-458001.pdf, ទំព័រទី១២, ដកស្រង់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៤

[៩៣] គេហទំព័រ file:///C:/Users/TRC/Downloads/ssrn-458001.pdf, ទំព័រទី២២, ដកស្រង់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៤

[៩៤] ច្បាប់ស្ដីពីមជ្ឈត្តកម្ម(ជប៉ុន), មាត្រា១៦（仲裁法, 16 条）

[៩៥] ច្បាប់ស្ដីពីមជ្ឈត្តកម្ម(ជប៉ុន), មាត្រា២៥-២៨

[៩៦] ច្បាប់ស្ដីពីមជ្ឈត្តកម្ម(ជប៉ុន), មាត្រា២៩

**ដំណាក់កាលជំនុំជម្រះមជ្ឈត្តកម្ម៖** អាជ្ញាកណ្តាលមជ្ឈត្តកម្ម ធ្វើការកោះហៅភាគីទាំងសងខាងចូលសវនាការដើម្បីធ្វើការទាញហេតុផលផ្ទាល់មាត់ដោយតម្រូវអោយគូភាគីធ្វើការលើកឡើងពីភស្តុតាង និងបង្ហាញពីជំហររៀងៗខ្លួន។ ក្នុងករណីដែលភាគីណាម្នាក់ទាមទារអោយមានអ្នកវាយតម្លៃ(鑑定人：Appraiser)[៨៧] នោះដំណើរការមជ្ឈត្តកម្មត្រូវប្រព្រឹត្តទៅតាមការទាមទារស្របជាមួយនឹងការចូលរួមពីអ្នកវាយតម្លៃដែលត្រូវបានជ្រើសរើសនោះ។

**ដំណាក់កាលបញ្ចប់មជ្ឈត្តកម្ម៖** ចំពោះការវិនិច្ឆ័យបញ្ចប់វិវាទនោះត្រូវមានការឯកភាពពីគូភាគីរួចតម្រូវអោយអាជ្ញាកណ្តាលមជ្ឈត្តកម្មដាក់ចេញនូវលិខិតវិនិច្ឆ័យ និងចុះហត្ថលេខា។ នៅក្នុងលិខិតវិនិច្ឆ័យនោះតម្រូវអោយមានសរសេរពីមូលហេតុ(លុះត្រាតែមានការយល់ព្រមពីគូភាគី)ថ្ងៃខែ និងទីកន្លែងធ្វើមជ្ឈត្តកម្មអោយបានច្បាស់លាស់។ បន្ទាប់ពីមានលិខិតច្បាស់លាស់ហើយ ប្រសិនបើគ្មានការជំទាស់ពីភាគីនោះទេវេទិកាមជ្ឈត្តកម្មនឹងត្រូវបិទដោយសេចក្តីសម្រេចរបស់អាជ្ញាកណ្តាលមជ្ឈត្តកម្ម។[៨៨] នៅក្នុងករណីនៅតែមិនពេញចិត្តចំពោះការដោះស្រាយទេ(ដំណោះស្រាយនោះលើសពីសមត្ថភាពខ្លួន ឬជាការទាមទារដែលមិនអាចទៅរួច ឬគិតថាខ្លួនពុំទាន់បានតវ៉ាគ្រប់គ្រាន់ជាដើម)នោះភាគីអាចស្នើសុំធ្វើការលុបចោលលិខិតវិនិច្ឆ័យ ក៏ដូចជាសេចក្តីសម្រេចនោះបាន។

៣.២.៤. ដំណើរការដោះស្រាយដោយភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា

ភ្នាក់ងារនេះមានសមាសភាពដូចជា ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាម្នាក់(ombudsman) ដែលជាអ្នកដែលធ្លាប់ជាមេធាវី ព្រះរាជអាជ្ញា ឬចៅក្រម ឬអ្នកសិក្សាផ្នែកនយោបាយ(អាចជាគ្រូសាកលវិទ្យាល័យ) ដែលមានបទពិសោធន៍ និងអ្នកស៊ើបអង្កេតជំនាញ(専門調査員)ដែលជាអ្នកមានបទពិសោធន៍ និងមានចំណេះដឹងខ្ពស់ខាងផ្នែករដ្ឋបាល និងនៅលេខាធិការដ្ឋាន មាននាយកប្រតិបត្តិ(事務局長)ម្នាក់ដែលជាអ្នកត្រួតពិនិត្យ និងប្រតិបត្តិការដោយមានបុគ្គលិក(職員) និងអ្នកប្រឹក្សា(相談員)។

ប្រសិនបើមានការប្តឹងពីសំណាក់ប្រជាពលរដ្ឋមកភ្នាក់ងារស៊ើបអង្កេតបណ្តឹង អ្នកប្រឹក្សាធ្វើការទទួលពាក្យបណ្តឹង និងរៀបចំខ្លឹមសារនៃបណ្តឹង។ បន្ទាប់មកធ្វើការបញ្ជូនតួនាទីបន្ទាប់ដល់ អ្នកស៊ើបអង្កេតជំនាញ។ អ្នកស៊ើបអង្កេតជំនាញធ្វើការពិនិត្យមើលលើខ្លឹមសារ និងមូលហេតុនៃបណ្តឹងរួច បញ្ជូនព័ត៌មានទៅកាន់ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា។ បន្ទាប់មកភ្នាក់ងារនេះនឹងធ្វើការសាកសួរទៅកាន់ដើមបណ្តឹង។

[៨៧] អ្នកវាយតម្លៃចំនួនមួយឬចាប់ពីពីររូបត្រូវ ជ្រើសរើសដោយអាជ្ញាកណ្តាលមជ្ឈត្តកម្ម មានតួនាទីក្នុងការរាយការណ៍ពីឯកសារដែលបានដាក់ និងលទ្ធផលនៃការចរចារបស់គូភាគី ម៉្យាងទៀតអាចធ្វើការវាយតម្លៃប្រសិនជាចាំបាច់

[៨៨] ច្បាប់ស្តីពីមជ្ឈត្តកម្ម(ជប៉ុន), មាត្រា៣៩-៤០

នៅពេលដែលចាប់ផ្តើមធ្វើការស្រាវជ្រាវ ក៏ដូចជាធ្វើការអង្កេតពីខ្លឹមសារនៃបណ្តឹងរួចគេនឹងធ្វើការស្នើសុំការឆ្លើយតបពីខាងភាគីដែលត្រូវបានប្តឹងនោះ (ជាទូទៅគឺមានស្ថាប័នសាធារណៈដូចជា សាលាខេត្ត ក្រុង ឬអាជ្ញាធរសាធារណៈជាដើម) ដើម្បីអោយមានភាពច្បាស់លាស់ការតវ៉ារបស់ដើមបណ្តឹងពិតជាត្រឹមត្រូវដែរឬទេ ហើយថាតើភាគីដែលត្រូវបានប្តឹងពិតជាមានកំហុសមែនឬយ៉ាងណា ដើម្បីអាចអោយភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាអាចដាក់ចេញនូវការវិនិច្ឆ័យសមរម្យមួយអោយភាគីទាំងសងខាង។ ការធ្វើដូច្នេះមិនត្រឹមតែអាចស្វែងរកការពិតនៃកំហុសនោះទេ តែថែមទាំងអាចរកឃើញមូលហេតុដែលនាំអោយកើតបញ្ហា និងអាចកែប្រែបញ្ហាបានយ៉ាងមានប្រសិទ្ធភាពទៀតផង។[៩៩]

[៩៩] គេហទំព័រ https://www.city.kumamoto.jp/common/UploadFileDsp.aspx?c_id=5&id=28382&sub_id=1&flid=208537, ដកស្រង់ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៤, ទំព័រទី២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីអត្ថបទខាងលើនេះរួចមក យើងអាចយល់ដឹងអំពីបទដ្ឋានគតិយុត្តនៃការគ្រប់គ្រងរដ្ឋបាល ប្រភេទនៃឧប្រាស្រ័យរដ្ឋបាល និងបានយល់អំពីថាតើស្ថាប័នណាមួយ និងអាជ្ញាធរមានសមត្ថកិច្ចណាមួយមានសមត្ថកិច្ចនៅក្នុងការដោះស្រាយជូនប្រជាពលរដ្ឋ ប្រសិនបើមានវិវាទរដ្ឋបាលកើតឡើង ព្រមជាមួយចំណេះដឹងបន្ថែមទាក់ទងនឹងការដោះស្រាយវិវាទរដ្ឋបាលនេះក្រៅប្រព័ន្ធតុលាការមិនថានៅប្រទេសកម្ពុជា ឬប្រទេសជប៉ុននោះទេ។

ម៉្យាងវិញទៀតយើងអាចយល់ដឹងថា ដោយមូលហេតុប្រទេសកម្ពុជាជាប្រទេសមួយដែលធ្លាប់ឆ្លងកាត់នូវសង្គ្រាមរាំរ៉ៃដែលនាំអោយបាត់បង់នូវធនធានមនុស្ស ក៏ដូចជាបាត់បង់នូវឯកសារមានតម្លៃជាច្រើនដូចជាឯកសារច្បាប់ជាដើម ទើបធ្វើអោយប្រទេសមានឧបសគ្គរាំងក្នុងការបង្កើត និងស្វែងរកអត្ថបទច្បាប់នោះមកធ្វើការកែសម្រួលដើម្បីអនុវត្តឡើងវិញក្នុងគោលដៅរក្សាសន្តិភាពនៅក្នុងប្រទេស។ ទោះបីជាយ៉ាងណាក៏ដោយចាប់តាំងពីឆ្នាំ១៩៩៣ មកយើងសង្កេតឃើញថាប្រទេសកម្ពុជាយើងមានការរីកចម្រើនខ្លាំងខាងវិស័យច្បាប់ដោយរាជរដ្ឋាភិបាលបានខិតខំបង្កើតអោយមាននូវច្បាប់នានាជាច្រើនរួមមាន រដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីដែលទទួលមានជំនួយផ្នែកច្បាប់ពីប្រទេសជប៉ុនជាដើម។ ក៏ប៉ុន្តែបើយើងងាកទៅមើលនីតិវិធីនៃការដោះស្រាយវិវាទរដ្ឋបាលវិញឃើញថា ពុំទាន់មាននូវក្រមច្បាប់ស្តីអំពីនីតិវិធីរដ្ឋបាលនោះទេ។

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបានថា ទោះបីជាការសិក្សានេះសិក្សាស្រាវជ្រាវនេះច្បាស់ជាពុំបានគ្រប់ជ្រុងជ្រោយទាំងស្រុងក៏ពិតមែន ប៉ុន្តែវាបានសបង្ហាញអោយឃើញពីលក្ខណៈដូច និងលក្ខណៈខុសគ្នារវាងប្រទេសទាំងពីរបានមួយកម្រិតផងដែរ។ ជាពិសេស បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវអំពីការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការនៅប្រទេសជប៉ុនរួចមកយើងសង្កេតឃើញថា សញ្ញាណទូទៅនៃការដោះស្រាយវិវាទរដ្ឋបាលក្រៅប្រព័ន្ធតុលាការនៅជប៉ុនក៏ពុំសូវមានលក្ខណៈខុសគ្នាអ្វីប៉ុន្មានពីកម្ពុជាឡើយ។ នៅកម្ពុជាយើងក៏មានច្បាប់សារធាតុជាច្រើនដែលត្រូវបានយកមកប្រើប្រាស់ក្នុងការដោះស្រាយវិវាទជូនប្រជាពលរដ្ឋ។ ចំណែកឯការដោះស្រាយវិវាទរដ្ឋបាលរាជរដ្ឋាភិបាលបានខិតខំបង្កើតអោយមាននូវលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងស្ថាប័នដោះស្រាយវិវាទទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើការជួយសម្រុះសម្រួល ក៏ដូចជាពង្រឹងការដោះស្រាយប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់។ ប៉ុន្តែដោយហេតុថា វិវាទរដ្ឋបាលមានច្រើនប្រភេទនិងលក្ខណៈស្មុគស្មាញក្នុងការដោះស្រាយ ការសិក្សាបន្ថែមទៀតពីប្រទេសដែលមាននូវច្បាប់ស្តីពីវិវាទរដ្ឋបាលជាដើមនោះ គឺពិតជាគួរអោយពិចារណាផងដែរ។ ជាក់ស្តែងដូចជា អត្ថន័យនៃវិវាទរដ្ឋបាល ថ្វីត្បិតតែប្រទេសជប៉ុននៅមិនទាន់កំណត់អត្តសញ្ញាណច្បាស់លាស់ណាមួយអំពីអត្ថន័យរបស់វិវាទរដ្ឋបាលក៏ពិតមែន តែនៅ

ពេលដែលមានវិវាទរដ្ឋបាលកើតឡើង គឺមានច្បាប់សារធាតុមួយចំនួនដូចជា ច្បាប់ស្តីពីការត្រួតពិនិត្យបណ្តឹងរដ្ឋបាល ច្បាប់ស្តីពីបណ្តឹងរដ្ឋបាល និងច្បាប់នីតិវិធីរដ្ឋបាលដែលមានចែងពីនីតិវិធីយ៉ាងច្បាស់លាស់សម្រាប់ធ្វើការដោះស្រាយ។ ឯការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការទៀតសោតក៏មានច្បាប់ស្តីពីការជម្រុញការអនុវត្តការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងច្បាប់ស្តីពីមជ្ឈត្តកម្មជាដើម។ ហេតុនេះហើយការសិក្សាស្រាវជ្រាវពីប្រធានបទនេះ និងលើកយកមកធ្វើជាប្រធានបទសារណាអាចអោយយើងខ្ញុំផ្ទាល់ ក៏ដូចជាបងប្អូនអ្នកសិក្សាស្រាវជ្រាវផ្សេងទៀតទទួលបានទស្សនៈថ្មីទាក់ទងនឹងការដោះស្រាយវិវាទរដ្ឋបាលនេះ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីធ្វើការសិក្សាស្រាវជ្រាវរួចមកនាងខ្ញុំយល់ឃើញថា ថ្វីត្បិតតែប្រទេសកម្ពុជាយើងមានលិខិតបទដ្ឋានគតិយុត្តនានា និងនីតិវិធីដោះស្រាយយ៉ាងមានប្រសិទ្ធភាពក៏ពិតមែនប៉ុន្តែយើងក៏គួរតែពិចារណាលើការសិក្សាស្រាវជ្រាវបន្ថែមទៀតពីប្រទេសផ្សេងៗទៀតផងដែរ។

ការសិក្សាស្រាវជ្រាវនេះបង្ហាញជាចម្ងល់អំពីមូលហេតុដែលយើងនៅមិនទាន់មានច្បាប់សារធាតុអំពីនីតិវិធីដោះស្រាយវិវាទរដ្ឋបាលក្នុងនាមជានិស្សិតរដ្ឋបាលមួយរូបប៉ុណ្ណោះ។ ហេតុដូច្នេះហើយ ក្នុងនាមនាងខ្ញុំជានិស្សិតបរិញ្ញាបត្ររដ្ឋបាលសាធារណៈសូមផ្តល់ជាមតិយោបល់មួយចំនួនថ្វីបើអាចចូលរួមបានមួយផ្នែកតូចក៏ពិតមែន ប៉ុន្តែនាងខ្ញុំសង្ឃឹមថាអត្ថបទមួយនេះអាចជួយដល់ការពង្រឹងគុណភាពនៃការអនុវត្តការដោះស្រាយវិវាទរដ្ឋបាលនាពេលអនាគតផងដែរ។ ដែលនាងខ្ញុំសូមធ្វើការសំណូមពរ និងផ្តល់ជាមតិលើកទឹកចិត្តដល់អ្នកសិក្សាស្រាវជ្រាវដូចតទៅ៖

- សូមសំណូមពរឱ្យ មិត្តនិស្សិតរបស់យើងផ្សេងៗទៀតដែលមានចំណាប់អារម្មណ៍ អាចធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀតអំពីវិវាទរដ្ឋបាលនេះ និងធ្វើការប្រៀបធៀបជាមួយនឹងប្រទេសផ្សេងៗទៀតដូចជាប្រទេសបារាំងដែលមាននូវតុលាការរដ្ឋបាល ឬក៏ប្រទេសអាល្លឺម៉ង់ជាដើមដោយសារតែច្បាប់នៃប្រទេសប្រទេសជប៉ុនទទួលរងឥទ្ធិពលមួយផ្នែកធំពីប្រទេសអាល្លឺម៉ង់ផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តីក៏ច្បាប់ពាក់ព័ន្ធនឹងរដ្ឋបាលរបស់ជប៉ុនតែងតែត្រូវបានធ្វើវិសោធនកម្ម និងកែសម្រួលជាបន្តបន្ទាប់។ ដូច្នេះហើយ យើងត្រូវធ្វើការសិក្សាស្រាវជ្រាវជាបន្តទៀតពីអ្វីដែលជាបញ្ហាចម្បងដែលត្រូវដោះស្រាយនៅពេលខាងមុខ។
- សូមសំណូមពរឱ្យ នៅដំណាក់កាលចាប់ផ្តើម ប្រសិនបើប្រទេសកម្ពុជាយើងអាចមាននូវច្បាប់សារធាតុជាក់លាក់ណាមួយស្តីអំពីការដោះស្រាយវិវាទរដ្ឋបាលនោះ នាងខ្ញុំសង្ឃឹមថាវាក៏អាចនឹងនាំអោយសិស្សនិស្សិតផ្នែករដ្ឋបាលសាធារណៈងាយស្រួលក្នុងការយកមកធ្វើជាឯកសារគោលដើម្បីធ្វើការសិក្សារៀនសូត្របន្ថែម។ បន្ថែមពីនេះទៅទៀត វាអាចជំរុញដល់ការអនុវត្តការដោះស្រាយវិវាទរដ្ឋបាលអោយកាន់តែឆាប់រហ័ស មានប្រសិទ្ធភាព គណនេយ្យភាព រក្សាបាននូវនីតិរដ្ឋ ក៏ដូចជាទំនាក់ទំនងល្អរវាងប្រជាពលរដ្ឋ និងអាជ្ញាធរដែលជាមូលហេតុជួយជម្រុញដល់សុខសន្តិភាព និងការអភិវឌ្ឍសង្គមជាតិបានមួយកម្រិតផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

### ក. ខ្មែរ

- រដ្ឋធម្មនុញ្ញ, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣
- ច្បាប់ ស្តីពីការរៀបចំស្ថាប័នតុលាការ, លេខ នស/រកម/០៧៤/០១៥, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ ភូមិបាល, លេខ នស/រកម/០៨០១/១៤, ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១
- ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ចុះថ្ងៃទី១៩ មីនា ឆ្នាំ២០០១
- ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ខណ្ឌ, លេខ នស/រកម/១០១៧/០១៣, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧
- ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ខណ្ឌ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់នេះ, លេខ នស/រកម/០១១៩/០០៤, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩
- ព្រះរាជក្រឹត្យ ស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, លេខ នស/រកត/១១២៣/២៣៨១, ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣
- អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, លេខ ៣៨១ អនក្រ.បក, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣
- អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ២០១៥, លេខ ១០៩ អនក្រ.បក, ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ ៤៧ អនក្រ.បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២
- អនុក្រឹត្យ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ, លេខ ១៨ អនក្រ.បក, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧
- អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, លេខ ១១១ អនក្រ.បក, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

- ប្រកាស ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលសេវាកម្មយុត្តិធម៌, លេខ ០៩០ កយ.ប្រក/១៨, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

ខ. ជប៉ុន

- ច្បាប់ស្ដីពីការត្រួតពិនិត្យបណ្ដឹងរដ្ឋបាល (行政不服審査法)
- ច្បាប់ស្ដីពីបណ្ដឹងរដ្ឋបាល (行政事件訴訟法)
- ច្បាប់នីតិវិធីរដ្ឋបាល (行政手続法)
- ច្បាប់ស្ដីពីការជម្រុញការអនុវត្តការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (裁判外紛争解決手続きの利用の促進に関する法律 )
- ច្បាប់ស្ដីពីមជ្ឈត្តកម្ម (仲裁法)

## ២. សៀវភៅតែងនិពន្ធ និងឯកសារស្រាវជ្រាវ

### ក. ខ្មែរ

- សៀវភៅ នីតិរដ្ឋបាល៖ សិក្ខាប័នសម្រាប់មើលតាមការពន្យល់ដោយបញ្ចាំងLCD, សាយ បូរី, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច, ឆ្នាំ២០០៥
- សៀវភៅ វិវាទរដ្ឋបាល, ឥន យឿន, ឆ្នាំ២០២២
- សៀវភៅ នីតិសាធារណៈ, សាស្ត្រាចារ្យ ហៀង សាង, បោះពុម្ពលើទី១ ឆ្នាំ២០១៧
- សៀវភៅ ស្ដីពីទស្សនាទានសំខាន់ៗដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា, ស៊ីរិន អ៊ែម អូស្មើមីឡឺ, បោះពុម្ពលើកទី២ ឆ្នាំ២០១០
- ឯកសារស្រាវជ្រាវសង្ខេប, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ស៊ូ សោភា, គណៈកម្មការទី១ ព្រឹទ្ធសភា
- ឯកសារស្រាវជ្រាវសង្ខេប, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា, តុប ដារី, គណៈកម្មការទី១ ព្រឹទ្ធសភា
- សៀវភៅណែនាំ ស្ដីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋ រាជធានីខេត្ត, អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ, ឆ្នាំ២០១៩

ខ. ជប៉ុន

- សៀវភៅ នីតិរដ្ឋបាលមូលដ្ឋាន, តូស៊ីយូគី អ៊ីស៊ីកាវ៉ា, ស៊ីហ្ស៊ូអូ ហ្វូជីវ៉ារ៉ា, ហ៊ីរ៉ូយូគី អូនូគី, ណូរីកុ អ៊ូគូប៉ុ, ហ្វូជិ ស៊ីម៉ូអ៊ិ (ជប៉ុន៖ យឺហ៊ីកាគុ, បោះពុម្ពលើកទី៤, ឆ្នាំ២០១៨)（石川敏行、藤原静雄、大貫裕之、大久保規子、下井康史『はじめての行政法』（有斐閣、第 4 版、2018 年））
- សៀវភៅ នីតិរដ្ឋបាលជាក់ស្តែង, កាស្សឹយ៉ា អ៊ីឈិហាស៊ី, ហ៊ីដេណូរី សាកាគីបារ៉ា, តាគី ហុងដា, កាហ្ស៊ូស្សុ អ៊ីណាបា, គេនហ្គូ យ៉ាម៉ាដា, កាហ្ស៊ូអ៊ីឈិ ហ៊ីរ៉ាតា (ជប៉ុន៖ក្រុមហ៊ុនវប្បធម៌ច្បាប់, បោះពុម្ពលើកទី៣, ឆ្នាំ២០២៣)（市橋克哉、榊原秀訓、本多滝夫、稲葉一将、山田健吾、平田和一『アクチュアル行政法』（法律文化社、第 3 版、2023 年））
- សៀវភៅ នីតិរដ្ឋបាល, គេយកុ សាគុរ៉ៃ, ហ៊ីរ៉ូយូគី ហាស៊ីម៉ូតុ (ជប៉ុន៖ កូប៊ុនដូ, បោះពុម្ពលើកទី៦, ឆ្នាំ២០១៩។（恵子桜井、博之橋本『行政法』（弘文堂、第 6 版、2019 年））
- សៀវភៅ ប្រព័ន្ធភ្នាក់ងារស៊ើបអង្កេត, ហាយ៉ាស៊ីយ៉ា រេអ៊ីជិ (ជប៉ុន៖ អ៊ីវ៉ាណាមីស្សុទែន, ឆ្នាំ២០០២)（林屋礼二『オンブズマン制度』（岩波書店 2002 年））
- ឯកសារមូលដ្ឋាន ស្តីពីគណៈកម្មការការពារសិទ្ធមនុស្សនិងទីស្នាក់កាលកណ្តាលស្ថាប័នតុលាការ និងប្រព័ន្ធភ្នាក់ងារស៊ើបអង្កេតបណ្តឹង, លេខាធិការដ្ឋានគណៈកម្មាធិការស្រាវជ្រាវរដ្ឋធម្មនុញ្ញនៃរដ្ឋសភា (ជប៉ុន៖ឯកសារលេខ៤, ឆ្នាំ២០០៤)។ (［衆議院憲法調査会事務局、「人権擁護委員会その他の準司法機関・ オンブズマン制度」に関する 基礎的資料」、2004 年 3 月、衆憲資第 42 号)
- និក្ខេបបទថ្នាក់បណ្ឌិត ស្តីពីការសិក្សាស្រាវជ្រាវអំពីនីតិវិធីដោះស្រាយវិវាទរដ្ឋបាលនៅកម្ពុជា, CHINKET Metta, (សាកលវិទ្យាល័យណាហ្គូយ៉ា)។ (CHINKET Metta、「カンボジアにおける行政紛争処理制度の研究」、（名古屋大学大学院法学研究科博士学位請求論文）

គ. អង់គ្លេស

- National Committee for Sub-National Democratic Development (NCDD) and Japan International Cooperation Agency (JICA), Situation Analysis 3: Capital/Provincial and District/Munipal/Khan Administration Management (NCDD, November 2011), 37; National Committee for Sub-National Democratic Development (NCDD), Result of the IP3 2011 Local Governance Survey (NCDD, 5 February, 2012), 20-21, 22; Khlok Dara, supra note 3, 146, 158, Hem Sras, supra note 3, 167; The NGO Forum on

Cambodia, A study on Land Dispute in Four Provinces of Cambodia: Mapping, Impacts, and Possible Solution (The NGO Forum on Cambodia, November 2015)

## ៣. គេហទំព័រ

### ក. ខ្មែរ

- គេហទំព័រ ការិយាល័យច្រកចេញចូលតែមួយ https://www.owso.gov.kh/en/
- គេហទំព័រ បែបបទនិងនីតិវិធីក្នុងការដោះស្រាយបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានីខេត្ត, https://www.owso.gov.kh/wp-content/uploads/2019/07/CP_Ombudsman_Complaint-Manual_Final-2.pdf
- គេហទំព័រ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ https://gda.interior.gov.kh/wp-content/uploads/2017/12/Binder-Final-Governance.pdf
- គេហទំព័រ ការដោះស្រាយវិវាទក្រៅផ្លូវតុលាការរួមមាន មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ការសម្រុះសម្រួល និងការផ្សះផ្សា DISPUTE RESOLUTIONS (INCLUDING COMMERCIAL ARBITRATION, MEDIATION,AND CONCILIATION) https://uat2.ncdd.gov.kh/storage/app/public/test_library/CAT_1273_1/2012-out-of-Judicial%20dispute%20resolution.pdf
- គេហទំព័រ សៀវភៅណែនាំ ស្ដីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋ រាជធានី ខេត្ត https://www.owso.gov.kh/wp-content/uploads/2019/07/CP_Ombudsman_Complaint-Manual_Final-2.pdf

### ខ. ជប៉ុន

- គេហទំព័រ ឯកសារសំណួរចម្លើយរបស់តុលាការជប៉ុន https://www.courts.go.jp/vc-files/courts/file2/20911003.pdf
- គេហទំព័រ ឯកសារស្ដីពីប្រព័ន្ធពិភាក្សាផ្នែករដ្ឋបាល, នាយកដ្ឋានវាយតម្លៃរដ្ឋបាលនៃក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុង (ជប៉ុន៖ ២០០១)។（総務省行政評価局「行政相談制度」(2001 年 10 月)）https://www.gender.go.jp/kaigi/senmon/kujou/siryo/pdf/ku07-1.pdf,
- គេហទំព័រ ឯកសារអំពីប្រព័ន្ធពិភាក្សារដ្ឋបាលនៃក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុង, ក្រសួងទំនាក់ទំនង និងកិច្ចការផ្ទៃក្នុង។（総務省、「総務省の行政相談制度について」）https://www.gender.go.jp/kaigi/senmon/kujou/houkoku/pdf/hku01s-8.pdf

- គេហទំព័រ ឯកសារស្តីពីភាពខុសគ្នារវាងការផ្សះផ្សា សន្ធានកម្ម និងមជ្ឈត្តកម្ម(លម្អិត), ក្រសួងដែនដី និងដឹកជញ្ជូន។（国土交通省、「あっせん、調停及び仲裁の違い（詳細）」）
https://www.mlit.go.jp/common/000005438.pdf
- គេហទំព័រ ឯកសារស្តីពីការវាយតម្លៃលើការដោះស្រាយវិវាទនៅក្រៅប្រព័ន្ធតុលាការ, ទីភ្នាក់ងារប្រកាសនីយប័ត្រតក្កកម្ម។ (特許庁、「裁判所以外による紛争解決を図る」)
https://www.jpo.go.jp/support/ipr/kyusai/funsokaiketsu.html
- គេហទំព័រ របាយការណ៍ស្តីពីត្រូវបានតែងតាំងជាភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ា, ហារ៉ាដា ស៊ីនសូកិ, ភ្នាក់ស៊ើបអង្កេតបណ្តឹងតវ៉ាគូម៉ាម៉ូតុ,（原田 信輔、熊本オンブズマン、「オンブズマンに就任して」）
https://www.city.kumamoto.jp/common/UploadFileDsp.aspx?c_id=5&id=28382&sub_id=1&flid=208537

## គ. អង់គ្លេស

- គេហទំព័រ Katja Funken, "Alternative Dispute Resolution in Japan",
file:///C:/Users/TRC/Downloads/ssrn-458001.pdf
- គេហទំព័រ Ms. HENG Nida, Parliamentary Institute of Cambodia, Alternative Dispute Resolution: Cambodia and Japan, Nov 2016 https://pcasia.org/pic/wp-content/uploads/simple-file-list/20170523-ADR-in-CambodiaJapan_Eng.pdf

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១.ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ស្តីពីទម្រង់ដ៏សំខាន់នៃដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

**ឧបសម្ព័ន្ធទី២៖** ប្រអប់សំបុត្រសម្រាប់បញ្ចេញមតិយោបល់ និងបណ្តឹងតវ៉ា

**ឧបសម្ព័ន្ធទី៣៖** រចនាសម្ព័ន្ធការិយាល័យប្រជាពលរដ្ឋរាជធានីខេត្ត

**ឧបសម្ព័ន្ធទី៤៖** ក្បាលលិខិតផែនការស៊ើបអង្កេតរបស់ការិយាល័យប្រជាពលរដ្ឋ

## ២.ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ព្រះរាជក្រឹត្យ ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, លេខ នស/រកត/១១២៣/២៣៨១, ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ, លេខ ១៨ អនក្រ.បក, ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, លេខ១១១ អនក្រ.បក, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី, លេខ ៤៧ អនក្រ.បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២

**ឧបសម្ព័ន្ធទី៥៖** ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលសេវាកម្មយុត្តិធម៌, លេខ ០៩០ កយ.ប្រក/១៨, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១៖ ទម្រង់ដ៏សំខាន់នៃដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

| | ការចរចា | សន្ធានកម្ម (Mediation) | ការផ្សះផ្សា (Conciliation) | អាជ្ញាកណ្តាល/មជ្ឈត្តកម្ម (Arbitration) |
|---|---|---|---|---|
| ភាគីចូលរួម | ភាគីក្នុងជម្លោះ | ភាគីក្នុងជម្លោះ+សន្ធានការី(Mediator) | ភាគីក្នុងជម្លោះ + អ្នកផ្សះផ្សា(Conciliator) | ភាគីក្នុងជម្លោះ + អាជ្ញាកណ្តាល/មជ្ឈត្តករ(Arbitrator) |
| តួនាទីរបស់ភាគីទីបី | ភាគីដោះស្រាយជម្លោះរបស់ពួកគេដោយខ្លួនឯង | សន្ធានការីព្យាយាមដើម្បីជួយសម្រួលដល់ដំណោះស្រាយ ពិចារណាពីផលប្រយោជន៍ និងសំណើរបស់ភាគី។ ភាគីទាំងសងខាងសម្រេចចិត្តទៅលើដំណោះស្រាយ។ | អ្នកផ្សះផ្សានាំយកសំណើទៅកាន់ភាគីដើម្បីដោះស្រាយជម្លោះរបស់ពួកគេ។ ភាគីទាំងសងខាងសម្រេច ចិត្តជាដំណោះស្រាយចុងក្រោយដោយមានជំនួយពីអ្នកផ្សះផ្សា។ | អាជ្ញាកណ្តាល/មជ្ឈត្តករបាននាំយកដំណោះស្រាយចំពោះករណីនេះ។ ភាគីទាំងសងខាងត្រូវតែគោរពការសម្រេចចិត្តនោះ។ |
| ការផ្តួចផ្តើមដំណើរ | ការស្ម័គ្រចិត្ត | ការស្ម័គ្រចិត្ត | ការស្ម័គ្រចិត្ត | ការស្ម័គ្រចិត្ត (ឬតម្រូវដោយច្បាប់ ឬកិច្ចព្រមព្រៀងដំបូង) |
| លទ្ធផល | អាស្រ័យលើភាគី | អាស្រ័យលើការសម្រេចចិត្តរបស់ភាគីទាំងសងខាង | អ្នកផ្សះផ្សាស្នើសុំដំណោះស្រាយមួយ ប៉ុន្តែអាស្រ័យលើការទទួលយករបស់ភាគីទាំងសងខាង។ | អាស្រ័យលើការសម្រេចចិត្តរបស់អាជ្ញាកណ្តាល/មជ្ឈត្តករ |
| លទ្ធផលអនុវត្តន៍ | កិច្ចព្រមព្រៀងនេះគឺដូចជាកិច្ចសន្យាមួយ ប៉ុន្តែប្រសិនបើភាគីមួយមិនបានបំពេញតាមកិច្ចព្រមព្រៀង ភាគីម្ខាងផ្សេងទៀតត្រូវចូលទៅកាន់តុលាការ។ | កិច្ចព្រមព្រៀងនេះគឺដូចជាកិច្ចសន្យាមួយប៉ុន្តែប្រសិនបើភាគីមួយមិនបានបំពេញតាមកិច្ចព្រមព្រៀង ភាគីម្ខាងផ្សេងទៀតត្រូវចូលទៅកាន់តុលាការ។ | កិច្ចព្រមព្រៀងនេះគឺដូចជាកិច្ចសន្យាមួយប៉ុន្តែប្រសិនបើភាគីមួយមិនបានបំពេញតាមកិច្ចព្រមព្រៀង ភាគីម្ខាងផ្សេងទៀតត្រូវចូលទៅកាន់តុលាការ។ | សេចក្តីបង្គាប់អាជ្ញាកណ្តាល អាចនឹងត្រូវបានអនុវត្តតាមរយៈតុលាការ ឬ តាមគោលនយោបាយផ្សេងទៀត។ |

## ឧបសម្ព័ន្ធទី២៖ ប្រអប់សំបុត្រសម្រាប់បញ្ចេញមតិយោបល់ និងបណ្តឹងតវ៉ា



## ឧបសម្ព័ន្ធទី៣៖ រចនាសម្ព័ន្ធការិយាល័យប្រជាពលរដ្ឋរាជធានីខេត្ត



# ឧបសម្ព័ន្ធទី៤៖ ក្បាលលិខិតផែនការស៊ើបអង្កេតរបស់ការិយាល័យប្រជាពលរដ្ឋ

**ឧទ្ទេសទី១១ ÷ ផែនការស៊ើបអង្កេត**

*(ក្បាលលិខិតការិយាល័យប្រជាពលរដ្ឋ)*

**ផែនការស៊ើបអង្កេត**

| | |
|---|---|
| លេខសំណុំរឿង | |
| អ្នកប្តឹង | |
| អ្នកត្រូវគេប្តឹង | |

| ល.រ | សកម្មភាព | ពេលវេលា | ថិរវេលា | ទីកន្លែង | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| ១ | ការសិក្សាសំណុំរឿង និងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | |
| ២ | ការរៀបចំបញ្ជីសំណួរ | | | | |
| ៣ | ការប្រមូលឯកសារពាក់ព័ន្ធនឹងអង្គហេតុ | | | | |
| ៤ | ការសម្ភាសអ្នកប្តឹង | | | | |
| ៥ | ការសម្ភាសអ្នកត្រូវគេប្តឹង | | | | |
| ៦ | ការសម្ភាសសាក្សី អ្នកដឹងឮ និងអ្នកពាក់ព័ន្ធ | | | | |
| ៧ | ការចុះពិនិត្យកន្លែងកើតហេតុ | | | | |
| ៨ | ការពិគ្រោះយោបល់ជាមួយជំនាញ | | | | |
| ៩ | ការវិភាគភស្តុតាង | | | | |
| ១០ | ការរៀបចំរបាយការណ៍ស៊ើបអង្កេត | | | | |
| .... | | | | | |

.................... ថ្ងៃទី......... ខែ.............. ឆ្នាំ..........

**អ្នកស៊ើបអង្កេត**

**បានឃើញ និងឯកភាព**

.................... ថ្ងៃទី......... ខែ.............. ឆ្នាំ..........

**ប្រធានការិយាល័យប្រជាពលរដ្ឋ**

# ឧបសម្ព័ន្ធគតិយុត្ត